00348441

1

**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

| | |
|---|---|
| **សំណុំរឿងលេខ:** | ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស(អ.ប.ជ ) |
| **ដាក់ទៅ:** | អង្គបុរេជំនុំជម្រះ |
| **ថ្ងៃដាក់:** | ថ្ងៃទី ៨ ខែ កក្កដា ឆ្នាំ ២០០៩ |
| **ភាគីអ្នកដាក់:** | សហមេធាវីរបស់លោក អៀង សារី |
| **ភាសាដើម:** | អង់គ្លេស |
| **ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ:** | សាធារណៈ |

**ឯកសារទទួល**
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 08 / JUL / 2009
ម៉ោង (Time/Heure): 15:35
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

---

**បណ្តឹងជំទាស់បង្អាក់បំណងរបស់ អៀង សារី ទៅលើអ្នកស៊ើបអង្កេត ក.ស.ច.ស STEPHEN HEDER និងមន្ត្រីច្បាប់ ក.ស.ច.ស DAVID BOYLE ដែលបម្រើការនៅការិយាល័យសហចៅក្រមស៊ើបអង្កេត**

---

**អ្នកដាក់ឯកសារ៖**
**សហមេធាវីរបស់លោក អៀង សារី**
លោក អាង ឧត្តម
លោក Michael G. KARNAVAS

**អ្នកទទួលឯកសារ៖**
**អង្គបុរេជំនុំជម្រះ**
ចៅក្រម ប្រាក់ គឹមសាន
ចៅក្រម ន័យ ធុល
ចៅក្រម ហួត វុទ្ធី
ចៅក្រម Katinka LAHUIS
ចៅក្រម Rowan DOWNING
**សហព្រះរាជអាជ្ញា**
លោកស្រី ជា លាង
លោក Robert PETIT

**ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certifified Date/Date de certification): 10 / JUL / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

## I. សេចក្តីផ្តើម

លោក អៀង សារី តាមរយៈសហមេធាវីរបស់គាត់ (“សហមេធាវីការពារក្តី”) អនុលោមតាមវិធានផ្ទៃក្នុង ៣៤(៥) (“វិធាន”) សូមស្នើដោយគោរពដល់អង្គបុរេជំនុំជម្រះដកសិទ្ធិមន្ត្រីផ្នែកច្បាប់ David Boyle (“មន្ត្រីផ្នែកច្បាប់ Boyle”) និងអ្នកស៊ើបអង្កេត Stephen Heder (“អ្នកស៊ើបអង្កេត Heder”) កុំឱ្យបំពេញកិច្ចការតទៅទៀត ទៅលើសំណុំរឿង ០០២ សម្រាប់ការិយាល័យសហចៅក្រមស៊ើបអង្កេត (“ក.ស.ច.ស”)។ ដូចដែលមានបញ្ជាក់នៅក្នុងសំណើនេះ ទាំងមន្ត្រីផ្នែកច្បាប់ Boyle និងទាំងអ្នកស៊ើបអង្កេត Heder មានការជាប់ពាក់ព័ន្ធនឹងសកម្មភាព ដែលអាចប៉ះពាល់ដល់ភាពអនាគតិរបស់ពួកគាត់នៅក្នុងការអនុវត្តផ្នែកស៊ើបសួរ និងផ្នែកច្បាប់ នៃការស៊ើបអង្កេតរបស់ ក.ស.ច.ស នៅក្នុងសំណុំរឿង ០០២។ ដូច្នេះ សិទ្ធិរបស់ពួកគាត់ត្រូវតែដកហូត ដើម្បីកុំឱ្យពួកគាត់បន្តកិច្ចការសម្រាប់ ក.ស.ច.ស ទោះក្នុងសមត្ថកិច្ចណាក៏ដោយ។

## II. ប្រវត្តិអង្គហេតុ

១. លោក អាង ឧត្តម ត្រូវបានចាត់តាំងឱ្យតំណាងលោក អៀង សារី ក្នុងនាមជាសហមេធាវីកម្ពុជារបស់គាត់នៅថ្ងៃទី ១២ ខែវិច្ឆិកា ឆ្នាំ២០០៧[1]។ នៅថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ២០០៧ លោក Michael G. Karnavas ក៏ត្រូវបានចាត់តាំងឱ្យតំណាងលោក អៀង សារី ផងដែរជា សហមេធាវីបរទេសរបស់គាត់[2]។ ការចាត់តាំងសហមេធាវីទាំងពីរនេះត្រូវបានទទួលស្គាល់ជាអចិន្ត្រៃយ៍ដោយ ក.ស.ច.ស នៅថ្ងៃទី ៧ កុម្ភៈ ២០០៨ ។[3]

២. បន្ទាប់ពីត្រូវចាត់តាំងឱ្យតំណាងលោក អៀង សារី រួចហើយ សហមេធាវីការពារក្តីបានដឹងអំពីទំនាស់ផលប្រយោជន៍ដ៏មានសក្តានុពល ពាក់ព័ន្ធទៅនឹងអ្នកស៊ើបអង្កេត Heder។ ទំនងជាថា

---

[1] *រឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស លិខិតរបស់លោក Rupert Skilbeck ប្រធានអង្គភាពគាំពារការពារក្តីផ្ញើរទៅកាន់របស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី ១២ វិច្ឆិកា ២០០៧។

[2] *រឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស លិខិតរបស់លោក Rupert Skilbeck ប្រធានអង្គភាពគាំពារការពារក្តីផ្ញើរទៅកាន់របស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី ១៤ ធ្នូ ២០០៧។

[3] *រឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស សេចក្តីសម្រេចទទួលស្គាល់មេធាវី ចុះថ្ងៃទី ៧ កុម្ភៈ ២០០៨។

Heder បានធ្វើការឱ្យការិយាល័យសហព្រះរាជអាជ្ញា ក្នុងអំឡុងដំណើរការតាក់តែងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ មុនពេលចូលរួមជាមួយ ក.ស.ច.ស ដើម្បីធ្វើការស៊ើបអង្កេត "ដោយអនាគតិ" ទៅលើការចោទប្រកាន់ដូចគ្នាទាំងនោះដែរ។ ដើម្បីពិនិត្យមើលក្តីកង្វល់របស់ខ្លួន និងក្នុងការព្យាយាមដើម្បីបំពេញកាតព្វកិច្ចវិជ្ជាជីវៈ និងប្រកបដោយក្រមសីលធម៌របស់ខ្លួន សហមេធាវីការពារក្តីបានស្វះស្វែងរកព័ត៌មានបន្ថែមទៀតពី ក.ស.ច.ស អំពីការងារពីមុនរបស់អ្នកស៊ើបអង្កេត Heder ជាមួយ ក.ស.ព និងឥទ្ធិពលដែលអាចមានមកលើកិច្ចការរបស់គាត់ជាមួយ ក.ស.ច.ស[4]។

៣. ក.ស.ច.ស បានឆ្លើយតបក្នុងន័យការពារ ទៅនឹងសំណើដ៏មានតម្លាភាពសុំព័ត៌មាននេះ[5] ដោយអះអាងថា កិច្ចការពីមុនរបស់លោក Heder ជាមួយ ក.ស.ព មុនពេលផ្លាស់ទៅ ក.ស.ច.ស "មិនមានជាបញ្ហាអ្វីឡើយ ទាក់ទិនទៅនឹងឯករាជ្យភាព និងភាពអនាគតិរបស់សហចៅក្រមស៊ើបអង្កេត ហើយមិនមានប៉ះពាល់ទាល់តែសោះ ចំពោះភាពចម្រើនទៅមុខនៃកិច្ចស៊ើបសួរតាមផ្លូវតុលាការ ដែលកំពុងតែប្រព្រឹត្តទៅ"[6]។ ទោះបីជាយ៉ាងណាក៏ដោយ ក.ស.ច.ស បានអះអាងថាអ្នកស៊ើបអង្កេត Heder ត្រូវបានជួលឱ្យមកបំពេញការងារ នៅក្នុង "ខែកក្កដា ឆ្នាំ២០០៦ និងត្រូវបានចាត់តាំងឱ្យបម្រើការនៅការិយាល័យសហចៅក្រមស៊ើបអង្កេត។ ប៉ុន្តែមុនពេលចូលមកកាន់តួនាទីរបស់គាត់ គាត់ត្រូវបានចាត់ឱ្យទៅបម្រើការនៅការិយាល័យសហព្រះរាជអាជ្ញាពីខែកក្កដា ដល់ខែធ្នូ ឆ្នាំ២០០៦"[7]។ មិនមានព័ត៌មានណាមួយឡើយដែលផ្តល់ដោយ ក.ស.ច.ស ឆ្លើយតបទៅនឹងសំណើរបស់សហមេធាវីការពារក្តី ស្តីអំពីប្រភេទពិតប្រាកដនៃកិច្ចការរបស់គាត់ ទាំង

---

[4] *រឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, សំណើសុំព័ត៌មានទាក់ទងនឹងទំនាស់ផលប្រយោជន៍ដ៏មានសក្តានុពល, ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៨ ("សំណើដំបូងពាក់ព័ន្ធនឹង Heder") ។

[5] *សូមមើល រឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, លិខិតមានចំណង ជើងថា "កម្មវត្ថុ៖ សំណើសុំផ្តល់ព័ត៌មានទាក់ទិននឹងករណីទំនាស់ផលប្រយោជន៍ជាយថាហេតុ, ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០០៨ ("សេចក្តីសម្រេចដំបូងពាក់ព័ន្ធនឹង Heder") ។

[6] *ដូចយោងខាងលើ,* ទំព័រ២ ។

[7] *ដូចយោងខាងលើ,* ទំព័រ១ ។

ពេលបម្រើការងារឲ្យ ក.ស.ព និងទាំងពេលបម្រើការងារឲ្យ ក.ស.ច.ស និងអំពីតួនាទីរបស់គាត់ ប្រសិនបើមាន ក្នុងដំណើរការតាក់តែងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ("IS")[8]។

៤. បន្ទាប់ពីការចេញសេចក្តីសម្រេចលើកទីមួយទាក់ទិននឹង Heder សហមេធាវីការពារក្តី ក៏បានដឹងថា មន្ត្រីផ្នែកច្បាប់ដែលបម្រើការឲ្យ ក.ស.ច.ស ឈ្មោះ David Boyle បាននិពន្ធអត្ថបទជាច្រើនដែលទាក់ទងនឹង អ.វ.ត.ក ហើយនៅក្នុងបទអត្ថាធិប្បាយអំពី "ការបង្កើត អ.វ.ត.ក អំពីសារជាតិរបស់ខ្មែរក្រហម ព្រឹត្តការណ៍ជាប្រវត្តិសាស្ត្រនៃរយៈកាលដែលពាក់ព័ន្ធ បុគ្គលដែលត្រូវបានគិតថាទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ សុពលភាពនិងការអនុវត្តព្រះរាជក្រឹត្យលើកលែងទោសនិងអនុគ្រោះទោស ដល់លោក អៀង សារី និងច្បាប់និងនីតិវិធីដែលកំពុងអនុវត្ត មន្ត្រីផ្នែកច្បាប់ Boyle បានផ្តល់គំនិត និងការសន្និដ្ឋានជាច្រើន ដែលទំនងជាគួរឲ្យបារម្ភ ឆ្លុះបញ្ចាំងថា គាត់មានបុរេវិនិច្ឆ័យ និងភាពលំអៀង ដូច្នេះធ្វើឲ្យគាត់មិនមានគុណសម្បត្តិក្នុងការមានតួនាទីណាមួយនៅក្នុង ក.ស.ច.ស បានឡើយ"[9]។ ដូច្នេះ សហមេធាវីការពារក្តីបានស្វះស្វែងរកព័ត៌មានបន្ថែមទៀតអំពីការប្រកាសនិងអត្ថបទសរសេរនានាដែលប្រមូលបាន របស់

---

[8] នៅក្នុងសំណើចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៨ ក្រុមការពារក្តីបានស្នើសុំប្រភេទព័ត៌មានផ្សេងៗគ្នាជាច្រើនពី ក.ស.ច.ស។ ព័ត៌មានទាំងនេះមាន៖ ១. តើលោក ហេដ័រ ធ្លាប់ជាសមាជិកនៃការិយាល័យសហព្រះរាជអាជ្ញាឬទេ? បើសិនជាមាន៖ ក. តើកាលបរិច្ឆេទពិតប្រាកដនៃថ្ងៃធ្វើការរបស់គាត់នៅពេលណា? ខ.តើប្រភេទការងារពិតប្រាកដរបស់គាត់ធ្វើអ្វីនៅពេលនោះ? គ. តើគាត់ធ្លាប់ចូលរួមក្នុងសមត្ថកិច្ចណាមួយក្នុងការស៊ើបអង្កេត ឬ ដំណើរការតាក់តែងសេចក្តីសន្និដ្ឋានបញ្ជូនរឿង ឲ្យស៊ើបសួរ (ត្រួតពិនិត្យ ឬវិភាគឯកសារ, សម្ភាសសាក្សី, ចូលរួមក្នុងដំណាក់កាលប្រមូលផ្តុំគំនិត ជាអាទិ៍)? ឃ. តើលោក ហេដ័រ បានលាតត្រដាងដល់ការិយាល័យសហចៅក្រមស៊ើបអង្កេតពីប្រភេទនៃការងារពីមុនរបស់គាត់ មុនពេលដែលគាត់ចាប់ផ្តើមធ្វើការងារជាមួយការិយាល័យសហចៅក្រមស៊ើបអង្កេត? ង. តើការិយាល័យសហចៅក្រមស៊ើបអង្កេត បានស្នើឲ្យលោក ហេដ័រ សរសេរជាលាយលក្ខណ៍អក្សររំលឹកការចងចាំនូវប្រភេទនៃការងាររបស់គាត់ជាមួយការិយាល័យសហព្រះរាជអាជ្ញាឬទេ? ច. តើការទទួលខុសត្រូវរបស់លោក ហេដ័រ ពីមុន និងបច្ចុប្បន្ន មានអ្វីខ្លះ? ៣. តើការិយាល័យសហចៅក្រមស៊ើបអង្កេតធ្លាប់ពិចារណាថាតើ ការងាររបស់លោក ហេដ័រ ដែលធ្វើជាមួយនឹងការិយាល័យសហចៅក្រមស៊ើបអង្កេត ធ្វើឲ្យមានទំនាស់ផលប្រយោជន៍ជាក់ស្តែង ឬដោយវិចារណញ្ញាណ ដែរឬទេ?

[9] *រឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, សំណើសុំព័ត៌មានទាក់ទងនឹងភាពលំអៀងដែលឃើញច្បាស់ និងទំនាស់ផលប្រយោជន៍ដ៏មានសក្តានុពល នៃមន្ត្រីផ្នែកច្បាប់របស់ ក.ស.ច.ស ដេវីដ បយល៍ (David Boyle), ចុះថ្ងៃទី៤ ខែមីនា ឆ្នាំ២០០៨, កថាខណ្ឌ១-២ ("សំណើពាក់ព័ន្ធនឹង Boyle")។

00348445



លោក Boyle ទៅលើបញ្ហាផ្នែកច្បាប់ដ៏ច្រើនដែល អ.វ.ត.ក បានប្រឈម និងប៉ះពាល់ដោយផ្ទាល់ដល់លោកអៀង សារី[10]។

៥. ទោះបីជាបញ្ហានេះមានសារសំខាន់យ៉ាងណាក៏ដោយ ទោះបីជាឥទ្ធិពលនៃតួនាទីរបស់លោក Boyle ដែលកំពុងតែបន្តក្នុងការផ្តល់យោបល់ដល់សហចៅក្រមស៊ើបអង្កេត ("ស.ច.ស") អាចប៉ះពាល់ទៅលើភាពយុត្តិធម៌នៃសេចក្តីសម្រេចតាមផ្លូវតុលាការរបស់ ក.ស.ច.ស យ៉ាងណាក៏ដោយ ក៏មិនមានចម្លើយតបពី ក.ស.ច.ស ទៅនឹងសំណើទាក់ទិននឹង Boyle ឱ្យបានឆាប់ៗឡើយ។

---

[10] សហមេធាវីការពារក្តី ទាមទារឱ្យ ក.ស.ច.ស ផ្តល់ព័ត៌មានដូចខាងក្រោម៖ ក. បញ្ជីនៃអត្ថបទឯកសារទាំងអស់ ឯកសារស្តីពីគោលជំហរ ជំពូកក្នុងសៀវភៅ លិខិតសរសេរទៅកាន់នាយកសារព័ត៌មានជាអាទិ៍ ដែលរៀបរៀងសរសេរដោយមន្ត្រីផ្នែកច្បាប់ ដេវីដ បយល៍ ទៅលើអ្វីដែលទាក់ទងនឹង អ.វ.ត.ក ខ្មែរក្រហម ច្បាប់និងនីតិវិធី ដែលទាក់ទងទៅនឹងការស៊ើបអង្កេត និង/ឬ សវនាការ ដែលរំពឹងថានឹងធ្វើឡើងដោយ អ.វ.ត.ក. ក៏ដូចជាអ្វីៗដែលអាចទាក់ទងទៅនឹងភាពសមស្របទៅនឹងយុត្តិធម៌ និងអនាគតិ ក្នុងការបំពេញមុខងាររបស់គាត់ក្នុងនាមជាមន្ត្រីផ្នែកច្បាប់។ ខ. បញ្ជីឯកសារនៃសិក្ខាសាលា ការបណ្តុះបណ្តាល ការបង្រៀន សិក្ខាសាលា និងកិច្ចប្រជុំ ដែលលោកមន្ត្រីផ្នែកច្បាប់ បានចូលរួម ដោយ ដេវីដ បយល៍ ដែលទាក់ទងទៅនឹង អ.វ.ត.ក. ខ្មែរក្រហម ច្បាប់និងនីតិវិធីទាក់ទងទៅនឹងការស៊ើបអង្កេត និង/ឬ សវនាការទាំងឡាយណាដែលរំពឹងថាធ្វើឡើងនៅ អ.វ.ត.ក. ដែលត្រូវបានយកមកពិភាក្សានោះ។ គ. សំណៅអនុស្សរណៈផ្ទៃក្នុងដែលរៀបរៀង ឬ ចូលរួមធ្វើដោយមន្ត្រីផ្នែកច្បាប់ ដេវីដ ប៊ីល ពាក់ព័ន្ធនឹងចារិករបស់ អ.វ.ត.ក ច្បាប់ និង នីតិវិធីជាធរមានដែលអនុវត្តដោយ អ.វ.ត.ក ការបន្ធូរបន្ថយទោស និងការលើកលែងទោសដែលបានផ្តល់ជូនលោក អៀង សារី ។ ឃ. ការពិពណ៌នាលំអិតអំពីការចូលរួមរបស់មន្ត្រីផ្នែកច្បាប់ ដេវីដ បយល៍ នៅក្នុងសេចក្តីព្រាងដីកាសម្រេចឱ្យឃុំខ្លួនបណ្តោះអាសន្ន ដែលបានរួមបញ្ចូលប៉ុន្តែមិនកំណត់តែបញ្ហាលើកលែងទោស និង អនុគ្រោះទោសដល់លោក អៀង សារី ប៉ុណ្ណោះទេ ជាពិសេសដោយហេតុថា បញ្ហានេះត្រូវបានសម្រេចដោយមិនបានជូនដំណឹងដល់លោក អៀង សារី ឱ្យបានត្រឹមត្រូវ និង គ្រប់គ្រាន់ ឬ ឱកាសទទួលបាននូវការពិគ្រោះយោបល់អំពីបញ្ហា និងដាក់សេចក្តីសន្និដ្ឋានដែលបានជូនដំណឹងតាមរយៈសហមេធាវីរបស់គាត់ ។ ង. ការពិពណ៌នាលំអិតនូវអ្វីដែល ក.ស.ច.ស ស្គាល់ថាជាស្នាដៃនិពន្ធ និង គោលជំហរដែលធ្លាប់បានថ្លែងដោយមន្ត្រីផ្នែកច្បាប់ ដេវីដ បយល៍ មុនគាត់ចូលបំរើការងារជាមួយ ក.ស.ច.ស. និងជាពិសេស: i) ថាតើលោក មន្ត្រីផ្នែកច្បាប់ ដេវីដ បយល៍ បានជូនដំណឹងពេញលេញទៅ ក.ស.ច.ស. អំពីស្នាដៃទាំងអស់ ដែលជាប់ទាក់ទងជាមួយ អ.វ.ត.ក. ដែលគាត់បាននិពន្ធដែរឬទេ។ ii) ថាតើសហចៅក្រមស៊ើបអង្កេតបានពិភាក្សាជាមួយមន្ត្រីផ្នែកច្បាប់ ដេវីដ បយល៍ អំពីទស្សនៈរបស់គាត់ ជាពិសេសទស្សនៈទាក់ទងទៅនឹងបញ្ហាការលើកលែងទោស និងការអនុគ្រោះទោសជូនលោក អៀង សារី ដែរឬទេ ហើយថាតើទស្សនៈបែបនេះបានសំដែងយ៉ាងច្បាស់នៅក្នុងស្នាដៃនិពន្ធរបស់គាត់ឬយ៉ាងណា និង iii) ថាតើសហចៅក្រមស៊ើបអង្កេតបានពិភាក្សាជាមួយមន្ត្រីផ្នែកច្បាប់ ដេវីដ ប៊ីល អំពីគោលជំហរ/យោបល់ពីអតីតកាលរបស់គាត់ ហើយថាតើគោលជហរ/យោបល់ដែលបាននិយាយនោះ បង្ហាញពីសញ្ញាណនៃភាពលំអៀង និង/ឬ អត្ថិភាពនៃទំនាស់ផលប្រយោជន៏ដែរឬទេ។ *សូមមើល* សំណើក្នុងរឿងក្តី Boyle, កថាខណ្ឌ៥ ។

សហមេធាវីការពារក្តីបានបង្ហំចិត្តដាស់តឿនដល់ ក.ស.ច.ស អំពី សំណើទាក់ទិននឹង Boyle[11] ហើយចុងក្រោយសហមេធាវីការពារក្តីទទួលបានសេចក្តីសម្រេចដ៏សំខាន់មួយពី ក.ស.ច.ស នៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៨[12]។ នៅក្នុងសេចក្តីសម្រេចនោះ មិនមានការផ្តល់នូវព័ត៌មានដែលត្រូវបានស្នើសុំទាក់ទិននឹងមន្ត្រីផ្នែកច្បាប់ Boyle ឡើយ ប៉ុន្តែផ្ទុយទៅវិញ ក.ស.ច.ស គ្រាន់តែអះអាង (ដោយគ្មានការគាំទ្រពីឯកសារយោងណាមួយឡើយ) ថា “មិនទំនងជាមានមូលដ្ឋានច្បាប់សម្រាប់ការទាមទារដដែលៗបែបនោះឡើយ”។ ការឆ្លើយតបទាក់ទិនទៅនឹង Boyle បានបន្តពន្យល់ទៀតថា “វិធានផ្ទៃក្នុងរបស់ អ.វ.ត.ក មិនមានចែងឲ្យភាគីមួយធ្វើបណ្តឹងជំទាស់អ្នកស៊ើបអង្កេតឡើយ” ហើយថា ចំពោះបណ្តឹងជំទាស់ចៅក្រម “មាននីតិវិធីជាក់លាក់ក្នុងការអនុវត្ត [...] ជាពិសេស ភស្តុតាងដែលគាំទ្រដល់បណ្តឹងនោះត្រូវផ្តល់ដោយភាគីដែលស្នើសុំ មិនមែនផ្តល់ឲ្យដោយចៅក្រមដែលមានបញ្ហានោះទេ”[13]។

៦. ដោយមិនពេញចិត្តទៅនឹងចម្លើយតបរបស់ ក.ស.ច.ស ដែលមិនមានលក្ខណៈគ្រប់គ្រាន់ និងក្នុងន័យការពារខ្លួនបែបនេះ សហមេធាវីការពារក្តីបានប្តឹងឧទ្ធរណ៍ទៅនឹងសេចក្តីសម្រេចនេះ ពីព្រោះវាប្រាកដជាប៉ះពាល់ដល់ការអនុវត្តដំណើរការនីតិវិធីដោយយុត្តិធម៌ និងអនាគតិ។ បណ្តឹងឧទ្ធរណ៍ដែលដាក់នៅថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៨[14] ត្រូវបានឆ្លើយតបដោយ ក.ស.ព នៅថ្ងៃទី២៣

---

[11] *រឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, លិខិតមានចំណងជើងថា “សំណើពាក់ព័ន្ធនឹងការសាកសួរចម្លើយលោក អៀង សារី អំពីស្ថានភាពនៃការឃុំខ្លួនរបស់គាត់ នៅថ្ងៃទី២ ខែឧសភា ឆ្នាំ២០០៨, ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០០៩ ។

[12] *រឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, លិខិតមានចំណងជើងថា “សំណើសុំព័ត៌មានទាក់ទងនឹងភាពលំអៀងដែលឃើញច្បាស់ និងទំនាស់ផលប្រយោជន៍ ពាក់ព័ន្ធនឹង MM S. Heder និង D. Boyle”, ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៨ (“សេចក្តីសម្រេចពាក់ព័ន្ធនឹង Boyle”) ។

[13] *ដូចយោងទំព័រខាងលើ។*

[14] *រឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ០៨), បណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់ ក.ស.ច.ស លើសំណើរបស់មេធាវីសុំព័ត៌មានទាក់ទងនឹងភាពលំអៀងដែលឃើញច្បាស់ និងអត្ថិភាពដ៏មានសក្តានុពល នៃទំនាស់ផលប្រយោជន៍នៃមន្ត្រីផ្នែកច្បាប់របស់ ក.ស.ច.ស ដេវីដ បយល៍ (David Boyle), ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៨ (“បណ្តឹងឧទ្ធរណ៍ពាក់ព័ន្ធនឹង Boyle”) ។

ខែមិថុនា ឆ្នាំ២០០៨[15]។ អង្គបុរេជំនុំជម្រះបានបដិសេធបណ្តឹងឧទ្ធរណ៍ទាក់ទិនទៅនឹង Boyle ថាមិនអាចទទួលយកបាន[16] ដោយមិនបានធ្វើការសម្រេចលើអង្គសេចក្តីចំពោះថាតើសំណើសុំផ្តល់ព័ត៌មានអំពីមន្ត្រីផ្នែកច្បាប់ Boyle របស់សហមេធាវីការពារក្តី មានភាពត្រឹមត្រូវតាមកាលៈទេសៈដែរឬយ៉ាងណានោះទេ។ មូលដ្ឋានអង្គច្បាប់របស់អង្គបុរេជំនុំជម្រះ ក្នុងការប្រកាសថាបណ្តឹងឧទ្ធរណ៍ មិនអាចទទួលយកបាននោះ គឺមិនមានលក្ខណៈច្បាស់លាស់ឡើយ។ វាបង្ហាញឱ្យឃើញថា អង្គបុរេជំនុំជម្រះមិនបានពិចារណាថា កម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍ទាក់ទិនទៅនឹង Boyle នេះ គឺស្ថិតនៅក្នុងប្រភេទ ដែលមានចែងនៅក្នុងវិធាន៧៤ ។

៧. ទោះបីជាយ៉ាងណាក៏ដោយ អង្គបុរេជំនុំជម្រះក៏បានអះអាងផងដែរថា មិនមានបញ្ហាទាក់ទិនទៅនឹងការរំលោភលើសមភាពនៃមធ្យោបាយក្នុងការតទល់ក្តីគ្នា រវាង ក.ស.ព និង មេធាវីការពារក្តី កើតឡើងដោយសារការប្រកាសថាបណ្តឹងឧទ្ធរណ៍មិនអាចទទួលយកបាននោះទេ[17]។ ទោះបីជាតាមវិធាន៧៤(២) ក.ស.ព មានសិទ្ធិធ្វើបណ្តឹងឧទ្ធរណ៍ទៅលើ "គ្រប់ដីកាទាំងអស់របស់សហចៅក្រមស៊ើបអង្កេត" ចំណែកឯសហមេធាវីការពារក្តីអាចធ្វើបណ្តឹងឧទ្ធរណ៍បានតែទៅលើដីកាជាក់លាក់មួយចំនួនដូច ដែលមានបញ្ជាក់នៅក្នុងវិធាន៧៤(៣) តែប៉ុណ្ណោះ យ៉ាងនេះក៏ដោយ ក៏វាមិនប៉ះពាល់ដល់សមភាពនៃមធ្យោបាយនៃការតទល់ក្តីគ្នាឡើយ ចំពោះអង្គបុរេជំនុំជម្រះ ដោយសារសេចក្តីសម្រេចទាក់ទិនទៅនឹង Boyle មិនមែនជាដីកា[18] ហើយដូច្នេះអាចសន្និដ្ឋានបានថា ទាំង ក.ស.ព និងសហមេធាវីការពារក្តីមិនមានសិទ្ធិក្នុងការប្តឹងឧទ្ធរណ៍លើសេចក្តីសម្រេចនេះឡើយ[19]។

---

[15] *រឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ០៨), ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងសារណារបស់ អៀង សារី ស្តីពីបញ្ហាទំនាស់ផលប្រយោជន៍ នៃអ្នកស៊ើបអង្កេត ក.ស.ច.ស មួយរូប, ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៨ ("ចម្លើយតបរបស់ ក.ស.ព ពាក់ព័ន្ធនឹង Boyle")

[16] *រឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ០៨), សាលដីកាស្តីពីបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ចំពោះលិខិតដែលពាក់ព័ន្ធនឹងសំណើសុំព័ត៌មានអំពីមន្ត្រីច្បាប់ លោក ដេវីឌ ប៊យល៍, ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៨, ទំព័រ៥ ("សាលដីកាបណ្តឹងឧទ្ធរណ៍ពាក់ព័ន្ធនឹង Boyle")។

[17] *ដូចយោងខាងលើ* ។

[18] *ដូចយោងខាងលើ*, កថាខណ្ឌ១៨ ។

[19] ការបកប្រែដែលមានលក្ខណៈចង្អៀតចង្អល់នៃពាក្យ "order" ក្នុងវិធាន ៧៤(៣) ដោយអង្គបុរេជំនុំជម្រះ ផ្ទុយគ្នាគួឱ្យកត់សម្គាល់ទៅនឹងការបកប្រែទូលំទូលាយចំពោះពាក្យដូចគ្នានេះនៅក្នុងសេចក្តីសម្រេចលើកមុនៗ។ នៅពេលត្រូវបានប្រឈមនឹងសំនួរថាតើសេចក្តីសម្រេចមួយក្នុងទំរង់ជាលិខិតចេញដោយ ក.ស.ច.ស ដែលហាមឃាត់ទំនាក់ទំនងរវាងលោក អៀង សារី

00348448



ទោះបីជាសំអាងលើផ្លូវច្បាប់បែបណាក៏ដោយ ដើម្បីប្រកាសអំពីភាពមិនអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍ ធ្វើអោយសហមេធាវីការពារក្តីមិនផ្លូវណាផ្សេងដើម្បីប្តឹងឧទ្ធរណ៍ ឬសុំឱ្យកែប្រែសេចក្តីសម្រេចរបស់ ក.ស.ច.ស ទាក់ទិនទៅនឹង Boyle ឡើយ។

៨. នៅចុងឆ្នាំ២០០៨ សហមេធាវីការពារក្តីបានកត់សំគាល់ថា នៅក្នុងសំណើមួយសុំបោះពុម្ពសៀវភៅ ដែលធ្វើនៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៣ ក្រោមចំណងជើងថា "អំពើប្រល័យពូជសាសន៍ និងការប្រល័យជាតិសាសន៍ឯងនៅកម្ពុជា (Genocide and Auto-Genocide in Cambodia)៖ លិទ្ធិកុម្មុយនីស្តនិយម, ជាតិនិយម និង អំពើមនុស្សឃាត ឆ្នាំ១៩៧៥ ដល់១៩៧៨" អ្នកស៊ើបអង្កេត Heder បាននិយាយយោងទៅកាន់គុណវុឌ្ឍិ របស់គាត់ថាបាន "ស្រាវជ្រាវអំពីបក្សកុម្មុយនីស្តកម្ពុជា អស់រយៈពេល៣០ឆ្នាំ ក្នុងមុខងារជាអ្នកសារព័ត៌មាន ភ្នាក់ងារស៊ើបការណ៍សម្ងាត់ អ្នកតស៊ូមតិសិទ្ធិមនុស្ស ប្រវត្តិវិទូ មន្ត្រីអង្គការសហប្រជាជាតិ អ្នកស្រាវជ្រាវផ្នែកច្បាប់ និងជាអ្នកវិទ្យាសាស្ត្រផ្នែកនយោបាយ" មុនចូលបម្រើការងារជាអ្នកស៊ើបអង្កេត នៅការិយាល័យសហចៅក្រមស៊ើបអង្កេត[20]។ ដូច្នេះ សហមេធាវីការពារក្តីបានស្នើសុំ "ព័ត៌មានទាំងឡាយណាដែលមាននៅ ក.ស.ច.ស ស្តីអំពី ៖

---

និងប្រពន្ធរបស់គាត់ អាចជាដីកាមួយ "ទាក់ទងនឹងការឃុំខ្លួនបណ្តោះអាសន្ន ឬការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការ" ក្រោមវិធាន ៧៤(៣)(ច) អង្គបុរេជំនុំជម្រះសំអាងទៅលើប្រសិទ្ធភាពនៃសេចក្តីសម្រេចជាជាងឈ្មោះផ្លូវការដើម្បីបង្កើតថាវាជា "ដីកាបង្គាប់ឱ្យដាក់នៅដាច់ដោយឡែកពីគ្នា" ហើយដូច្នេះអាចទទួលយកបាន។ *សូមមើល រឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ០៥) សេចក្តីសម្រេចស្តីពីភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍របស់ អៀង សារី អំពីសិទ្ធិចូលជួប, ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០០៨ ។

[20] *រឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, សំណើសុំព័ត៌មានទាក់ទងនឹងអត្ថិភាពដ៏មានឥទ្ធិពលនៃទំនាស់ផលប្រយោជន៍នៃអ្នកស៊ើបអង្កេតរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត Stephen Heder, ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០០៩, កថាខណ្ឌ១ ("សំណើលើកទីពីរពាក់ព័ន្ធនឹង Heder")។ ដូចមានចែងនៅក្នុងនោះ សហមេធាវីការពារក្តីត្រូវបានផ្តល់ជូននូវឯកសារតាមរយៈប្រភពសម្ងាត់ ដែលមើលទៅមានភាពត្រឹមត្រូវបញ្ជាក់ថាអ្នកស៊ើបអង្កេត Heder កាលពីថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៣ បានដាក់សំណើសៀវភៅមួយក្បាលមានចំណងជើងថា៖ "*Genocide and Auto-Genocide in Cambodia: Communism, Nationalism and Murder, 1975-1978* " អ្នកស៊ើបអង្កេត Heder បានយោងទៅលើសម្ថភាពរបស់គាត់ ដែលបាន "សិក្សាស្រាវជ្រាវ ប.ក.ក អស់រយៈពេល៣០ឆ្នាំ ជាអ្នកសាព័ត៌មាន ភ្នាក់ងារស៊ើបការណ៍សម្ងាត់ សកម្មជនសិទ្ធិមនុស្ស ប្រវត្តិវិទូ មន្ត្រី អ.ស.ប អ្នកប្រាជ្ញច្បាប់ និងជាអ្នកវិទ្យាសាស្ត្រនយោបាយ ដែលទាំងអស់នេះជាស្នាដៃវិជ្ជាជីវៈថ្មីៗរបស់ខ្ញុំ"។

ក. ការងារពីមុនរបស់អ្នកស៊ើបអង្កេត Heder ជាភ្នាក់ងារស៊ើបការណ៍សម្ងាត់ រួមទាំងសកម្មភាព និងតួនាទីពិតប្រាកដរបស់ Heder នៅក្នុងមុខតំណែងនេះ ក៏ដូចជាកិច្ចការផ្សេងទៀតដែលអាចពាក់ព័ន្ធទៅនឹងបញ្ហានៃសម្បទារបស់លោក Heder ដែលត្រូវមានភាពយុត្តិធម៌និងភាពអនាគតិ ក្នុងការបំពេញមុខងាររបស់គាត់ជាអ្នកស៊ើបអង្កេត និង

ខ. ថាតើការងារពីមុនជាភ្នាក់ងារស៊ើបការណ៍សម្ងាត់ ត្រូវបានលាតត្រដាងដែរឬទេជូនការិយាល័យសហព្រះរាជអាជ្ញា ដែលអ្នកស៊ើបអង្កេត Heder នេះបានបម្រើការងារពីដើមដំបូង និងក្រោយមកបម្រើការនៅ ក.ស.ច.ស នៅពេលដែលអ្នកស៊ើបអង្កេត Heder ផ្ទេរភារកិច្ចមកកាន់ការិយាល័យសហចៅក្រមស៊ើបអង្កេតនេះ"[21]។

៩. នៅក្នុងចម្លើយតប ដែលមានលក្ខណៈយឺតយ៉ាវរបស់ខ្លួនទៅនឹងសំណើទីពីរទាក់ទិនទៅនឹង Heder ក.ស.ច.ស ជាថ្មីម្តងទៀតបង្ហាញលក្ខណៈក្នុងន័យការពារខ្លួន ដោយប្រកាសអំពីកង្វះខាតមូលដ្ឋានច្បាប់នៅក្នុងប្រភេទនៃសំណើនេះ[22]។ ប៉ុន្តែ ក.ស.ច.ស បានអះអាងថា យើងមិនដឹងអំពីព័ត៌មាន ឬឯកសារណាមួយដែលអាចឆ្លើយតបទៅនឹងការចោទប្រកាន់នានាដែលមាននៅក្នុងសំណើសុំរបស់លោកនោះទេ"[23]។ ប៉ុន្តែចំណោទដែលកំពុងស្វែងរកចម្លើយនេះគឺថា តើ ក.ស.ច.ស ពិតជាបានលើកបញ្ហានេះទៅលោក Heder ដែរឬទេ ហើយបើមានធ្វើមែន តើមានអ្វីឆ្លើយតបពីលោក Heder ដែរឬទេ?

## III. **ការអង្កេតបឋម**

## ក. **ភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍**

---

[21] *ដូចយោងទំព័រខាងលើ,* កថាខណ្ឌ៥ ។

[22] *រឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, លិខិតមានចំណងជើងថា "សំណើសុំផ្តល់ព័ត៌មានទាក់ទិននឹងលោក ស្ទីវហ្វិន ហេដឺ (Stephen Heder), ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៩ ("សេចក្តីសម្រេចលើកទីពីរពាក់ព័ន្ធនឹង Heder") ។

[23] *ដូចយោងទំព័រខាងលើ ។.*

១០. ដូចដែលបានចែងនៅក្នុងវិធាន ៣៤(៥) "ពាក្យបណ្ដឹងជំទាស់ចំពោះសហចៅក្រមស៊ើបអង្កេត ត្រូវដាក់ជូនអង្គបុរេជំនុំជម្រះ"។ ដូចដែលបានបញ្ជាក់ខាងក្រោម វិធានទាំងឡាយ ដែលមានជាធរមានចំពោះសហចៅក្រមស៊ើបអង្កេត នៅពេលអនុវត្តកិច្ចការស៊ើបអង្កេត ឬកិច្ចការតុលាការ ត្រូវតែអនុវត្តដោយស្មើភាពគ្នាចំពោះបុគ្គលិកនៅក្នុង ក.ស.ច.ស ដែលកំពុងជួយកិច្ចការទាំងនេះ ឬអនុវត្តកិច្ចការទាំងនេះក្នុងនាម ក.ស.ច.ស ។ ដូច្នេះពាក្យបណ្ដឹងជំទាស់អ្នកស៊ើបអង្កេត ឬមន្ត្រីផ្នែកច្បាប់ ដែលស្ថិតនៅក្នុងការជួលមកបម្រើការឱ្យ ក.ស.ច.ស ក៏អាចទទួលយកបានផងដែរក្រោមវិធាន ៣៤(៥)។ ទោះថាអង្គបុរេជំនុំជម្រះ ព្រមទទួល ឬមិនព្រមទទួល ថាអ្នកស៊ើបអង្កេត Heder ឬមន្ត្រីផ្នែកច្បាប់ Boyle មិនបានបំពេញកិច្ចការប្រកបដោយភាពអនាគតិដែលតម្រូវឱ្យមាននោះ វាគឺជាបញ្ហាខ្លឹមសារ ហើយមិនប៉ះពាល់ដល់ភាពអាចទទួលយកបាននៃពាក្យបណ្ដឹងនោះឡើយ។

១១. ពាក្យបណ្ដឹងជំទាស់នោះក៏ត្រូវបានដាក់ជូន "នៅពេលដែលភាគីបានដឹងអំពីមូលហេតុនោះ ភ្លាមដែរ" ដូចដែលតម្រូវដោយវិធាន ៣៤(៣)។ កាតព្វកិច្ចនេះ ស្ថិតនៅក្រោមលក្ខខណ្ឌនៃបទប្បញ្ញត្តិដូចគ្នា ដែលតម្រូវភាគីឱ្យ "ផ្ដល់ភស្តុតាងបញ្ជាក់" ចំពោះគ្រប់បណ្ដឹងជំទាស់ទាំងអស់។ ពាក្យសុំប្ដឹងជំទាស់ ដាច់ខាតមិនត្រូវសំអាងតែទៅលើពាក្យចចាមអារ៉ាមនៃកត្តាដែលប៉ះពាល់ដល់អនាគតិប៉ុណ្ណោះទេ។ នៅពេលទទួលបានព័ត៌មានពាក់ព័ន្ធភ្លាម ដែលធ្វើឱ្យមានការសង្ស័យទាក់ទិនទៅនឹងភាពអនាគតិរបស់មន្ត្រីផ្នែកច្បាប់ Boyle និងអ្នកស៊ើបអង្កេត Heder សហមេធាវីការពារក្ដីបានដាក់សំណើម្ដងហើយម្ដងទៀតជាបន្តបន្ទាប់សុំឱ្យ ក.ស.ច.ស ផ្ដល់ព័ត៌មានទាក់ទិនទៅនឹងព័ត៌មានទាំងនេះ។ ទោះបីជាយ៉ាងណាក៏ដោយ ដូចដែលបានឃើញពីប្រវត្តិអង្គហេតុខាងលើ ក.ស.ច.ស មិនសូវយកចិត្តទុកដាក់ក្នុងការឆ្លើយតបទៅនឹងសំណើរបស់សហមេធាវីការពារក្ដីឡើយ។ ចម្លើយតបចុងក្រោយពី ក.ស.ច.ស ត្រូវបានចេញនៅថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៩ ប៉ុណ្ណោះ[24] ជិតបួនខែបន្ទាប់ពីសំណើសុំនោះត្រូវបានដាក់ជូន។ វាមិនអាចទៅរួចឡើយដើម្បីដាក់ពាក្យសុំនេះអោយបានឆាប់រហ័សជាងពេលបច្ចុប្បន្ននេះឡើយ។ សហមេធាវីការពារក្ដីត្រូវបានតម្រូវឱ្យស្វះស្វែងរកព័ត៌មានដោយខ្លួនឯង ជាជាងទទួលព័ត៌មានពី ក.ស.ច.ស ។ ម្យ៉ាងវិញទៀត ដោយសារតែវាជា

---

[24] *សូមមើល* សេចក្ដីសម្រេចលើកទីពីរពាក់ព័ន្ធនឹង Heder ។

បញ្ហារួមដែលប៉ះពាល់អ្នកទាំងពីរនេះគឺអ្នកស៊ើបអង្កេត Heder និងមន្ត្រីផ្នែកច្បាប់ Boyle ហើយដោយសារផលប្រយោជន៍សន្សំសំចៃសេដ្ឋកិច្ចតុលាការ សហមេធាវីការពារក្តីបានយកចិត្តទុកដាក់ក្នុងការដាក់នូវពាក្យសុំរួមគ្នានេះអោយបានឆាប់តាមតែកាលៈទេសៈជាក់ស្តែង ។ ពាក្យបណ្តឹងនេះក៏ត្រូវបានដាក់ "មុនដីកាដំណោះស្រាយ" ផងដែរ ដូចដែលតម្រូវដោយវិធាន ៣៤(៤)(ខ)។

## ខ. សំណើសុំឱ្យមានសវនាការស្តួរដេញដោលផ្ទាល់មាត់

១២. ការដាក់ពាក្យបណ្តឹងនេះស្ថិតក្រោមវិធាន ៣៤(៥)។ នៅក្នុងលក្ខណៈស្រដៀងគ្នានឹងការដាក់បណ្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ ក្រោមវិធាន ៧៤(៣) នីតិវិធីសម្រាប់កិច្ចដំណើរការនីតិវិធីទាក់ទិនទៅនឹងពាក្យបណ្តឹងនេះត្រូវបានចែងនៅក្នុងវិធាន៧៧[25]។ ក្រោម វិធាន ៧៧(៣) ការរំពឹងទុកចំពោះបណ្តឹងឧទ្ធរណ៍ និងពាក្យសុំទាំងអស់ទៅអង្គបុរេជំនុំជម្រះ គឺថា នឹងមានសវនាការស្តួរដេញដោលផ្ទាល់មាត់[26]។ អង្គបុរេជំនុំជម្រះជាច្រើនលើកច្រើនសារ បានយល់ព្រមតាមសំណើសុំឱ្យមានសវនាការស្តួរដេញដោលផ្ទាល់មាត់ នៅក្នុងបណ្តឹងឧទ្ធរណ៍អំពីការខ្វែងគំនិតគ្នារវាងភាគីនានា[27]។ នៅពេលដែលអង្គបុរេជំនុំជម្រះប្រឈមនឹងបណ្តឹងជិតចិត្តមួយទៀតរបស់ក្រុមមេធាវីការពារក្តី នួន ជា[28] អង្គបុរេជំនុំជម្រះបានចេញសេចក្តីសម្រេចរបស់ខ្លួនលើបណ្តឹងនោះ ដោយមិន

---

[25] វិធាននេះ មានចំណងជើងថា "នីតិវិធីសម្រាប់បណ្តឹងឧទ្ធរណ៍ និងពាក្យសុំទៅអង្គជំនុំជម្រះ" (គូសបញ្ជាក់បន្ថែម) ។

[26] *រឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ១៨), បណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអំពីការរំលោភបំពានការសម្ងាត់នៃកិច្ចស៊ើបសួរ និងសំណើសុំដាក់កាលបរិច្ឆេទដាក់ឯកសារជាបន្ទាន់ និង សវនាការដេញដោលផ្ទាល់មាត់ជាសាធារណៈ, ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០០៩, កថាខណ្ឌ១០ ("បណ្តឹងឧទ្ធរណ៍ពាក់ព័ន្ធនឹងភាពសម្ងាត់")។

[27] *រឿងក្តី ខៀវ សំផន* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ១១), សេចក្តីសម្រេចលើពាក្យសុំឱ្យមានសវនាការជាសាធារណៈ របស់លោក ខៀវ សំផន, ចុះថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០០៨។ *រឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ១៧), សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា ដើម្បីកំណត់លើបណ្តឹងឧទ្ធរណ៍ដោយផ្អែកលើមូលដ្ឋាននៃសារណាជាលាយលក្ខណ៍អក្សរតែប៉ុណ្ណោះ និងដីកាកំណត់កាលបរិច្ឆេទសវនាការ, ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៩, ("សេចក្តីសម្រេចលើសារណាជាលាយលក្ខណ៍អក្សរ")។

[28] *រឿងក្តី នួន ជា* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ០១), ពាក្យបណ្តឹងជិតចិត្តជាបន្ទាន់ចំពោះចៅក្រម ន័យ ធុល, ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០០៨។

មានការបើកសវនាការសួរដេញដោលផ្ទាល់មាត់ឡើយ[29]។ នីតិវិធីនេះអាចត្រូវបានធ្វើការពន្យល់មួយផ្នែកដែលថា ក្រុមមេធាវីការពារក្តី នួន ជា មិនបានស្នើឱ្យមានសវនាការសួរដេញដោលផ្ទាល់មាត់ឡើយ។

១៣. នៅក្នុងករណីថ្មីនេះ សហមេធាវីការពារក្តី សូមស្នើថា ការសន្មតទុកជាមុនគួរផ្តេកផ្តួលទៅលើការអោយមានសវនាការសួរដេញដោលផ្ទាល់មាត់ ដោយសារមូលហេតុដូចខាងក្រោម ៖

ក. ពាក្យបណ្តឹងនេះលើកឡើងនូវបញ្ហាស្មុគស្មាញជាច្រើន ដែលពីមុនមិនត្រូវ បានលើកឡើងនៅចំពោះមុខអង្គបុរេជំនុំជម្រះឡើយ ដូចជា វិសាលភាពនៃកាតព្វកិច្ចនៃភាពអនាគតិរបស់បុគ្គលិក ក.ស.ច.ស ។

ខ. ពាក្យបណ្តឹងនេះប៉ះពាល់យ៉ាងច្បាស់ និងដោយគ្មានមន្ទិលឡើយទៅលើកេរ្តិ៍ដំណែលរបស់ អ.វ.ត.ក ក្នុងការធ្វើជាគំរូដូចដែលគេរំពឹងទុកទៅលើកិច្ចដំណើរការនីតិវិធីតុលាការប្រកបដោយតម្លាភាពនិងយុត្តិធម៌។

១៤. សហមេធាវីការពារក្តី សូមស្នើថា សវនាការសួរដេញដោលផ្ទាល់មាត់ត្រូវធ្វើឡើងបានឆាប់ៗតាមដែលអង្គបុរេជំនុំជម្រះអាចធ្វើទៅបាន។ សវនាការនេះគួរតែមាននៅគ្រាដំបូងបន្ទាប់ពីមានសេចក្តីសន្និដ្ឋាននៃចម្លើយតបទៅនឹងពាក្យបណ្តឹងនេះពី ក.ស.ព និងដើមបណ្តឹងរដ្ឋប្បវេណី។ យោងទៅលើការកំណត់ពេលវេលា ដែលរៀបចំដោយអង្គបុរេជំនុំជម្រះ និងការមិនមានសំណើសុំពន្យារពេលវេលាពីភាគីនានានោះ សវនាការនេះគួរតែធ្វើឡើងក្នុងអំឡុងសប្តាហ៍ ថ្ងៃទី២៧-៣១ ខែកក្កដា ឆ្នាំ២០០៨[30]។

## IV. សេចក្តីសន្និដ្ឋានរួម

---

[29] *រឿងក្តី នួន ជា* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ០១), សេចក្តីសម្រេចជាសាធារណៈ ស្តីពីបណ្តឹងជិតចិត្តជាបន្ទាន់របស់សហមេធាវីជនត្រូវចោទ នួន ជា ចំពោះលោកចៅក្រម ន៉ីយ ធុល, ចុះថ្ងៃទី ៤ ខែកុម្ភៈ ឆ្នាំ២០០៨, ("សេចក្តីសម្រេចលើបណ្តឹងជិតចិត្តពាក់ព័ន្ធនឹងចៅក្រម ន៉ីយ ធុល")។

[30] យោងតាមអង្គបុរេជំនុំជម្រះ ខ្លួននឹងបើកសវនាការដេញដោលផ្ទាល់មាត់ក្នុងកំឡុងពេលសប្តាហ៍ថ្ងៃទី២៧-៣១ ខែកក្កដា ឆ្នាំ២០០៨។ *សូមមើល រឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, អនុស្សារណៈ អន្តរការិយាល័យ ចុះថ្ងៃទី ១៩ ធ្នូ ២០០៨។

១៥. សហមេធាវីការពារក្ដីនឹងបង្ហាញ ៖

ក. កាតព្វកិច្ចនៃភាពអនាគតិដែលអនុវត្តលើចៅក្រម ត្រូវអនុវត្តដោយស្មើភាពគ្នាចំពោះមន្ត្រីផ្នែកច្បាប់ឬអ្នកស៊ើបអង្កេត ដែលបម្រើការឱ្យចៅក្រមដោយផ្ទាល់ ("អ្នកស៊ើបអង្កេត ក.ស.ច.ស")។

ខ. ប្រព័ន្ធនៃបណ្ដឹងជំទាស់ចៅក្រមក្រោមវិធាន ៣៤(២) ចំពោះកង្វះខាតភាពអនាគតិ ត្រូវអនុវត្តដោយស្មើភាពគ្នាចំពោះអ្នកផ្ដល់យោបល់ផ្នែកច្បាប់ ឬអ្នកស៊ើបអង្កេត ដែលបម្រើការឱ្យចៅក្រមដោយផ្ទាល់។

គ. សៀវភៅដែលនិពន្ធដោយ អ្នកស៊ើបអង្កេត Heder ស្ដីអំពីខ្មែរក្រហម និងការងារពីមុនរបស់គាត់ជាមួយ ក.ស.ព និងជាភ្នាក់ងារស៊ើបការណ៍សម្ងាត់ឱ្យទីភ្នាក់ងារមួយដែលមិនមានឈ្មោះ ប៉ះពាល់យ៉ាងពិតប្រាកដដល់ភាពអនាគតិរបស់គាត់ និងតម្រូវឱ្យមានការប្ដឹងជំទាស់គាត់។

ឃ. អត្ថបទស្រាវជ្រាវពីមុន និងបាឋកថានានា ដែលលើកឡើងអំពីបញ្ហាវិវាទជាច្រើន ដែលប៉ះពាល់ដល់ អ.វ.ត.ក របស់ David Boyle ប៉ះពាល់យ៉ាងពិតប្រាកដដល់ភាពអនាគតិរបស់គាត់ និងតម្រូវឱ្យមានការប្ដឹងជំទាស់គាត់។

## V. ច្បាប់

### ក. ករណីយកិច្ចនៃភាពអនាគតិនិងភាពឯករាជ្យ ក្រោមច្បាប់កម្ពុជានិងច្បាប់អន្តរជាតិ

១៦. មាត្រា ១២៨ នៃរដ្ឋធម្មនុញ្ញកម្ពុជា[31] ផ្ដល់អំណាចឱ្យចៅក្រមមានភាពអនាគតិ និងភាពឯករាជ្យ ៖ "អំណាចតុលាការត្រូវតែជាអំណាចឯករាជ្យមួយ។ ចៅក្រមត្រូវធានា និងប្រកាន់ភាពអនាគតិ និងការពារសិទ្ធិ និងសេរីភាពរបស់ប្រជាពលរដ្ឋ"។ គោលគំនិតជាមូលដ្ឋាននេះ ត្រូវបានឆ្លុះបញ្ចាំងនៅ

---

[31] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ កែប្រែដោយព្រះរាជក្រម ចុះថ្ងៃទី៨ ខែមីនា ឆ្នាំ១៩៩៩ ប្រកាសឱ្យប្រើមាត្រាបានវិសោធនកម្មមានដូចជាមាត្រា ១១, ១២, ១៣, ១៨, ២២, ២៤, ២៦, ២៨, ៣០, ៣៤, ៥១, ៩០, ៩១, ៩៣ និងមាត្រាផ្សេងទៀតពីជំពូក៨ ដល់ជំពូក១៤ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានអនុម័តដោយសភាជាតិនៅថ្ងៃទី ៤ ខែមីនា ឆ្នាំ១៩៩៩ ("រដ្ឋធម្មនុញ្ញកម្ពុជា") ។

ក្នុងមាត្រា ៣ នៃកិច្ចព្រមព្រៀង ដែលចែងថា ចៅក្រម អ.វ.ត.ក ទាំងអស់ "ត្រូវជាបុគ្គលដែលមានចរិតលក្ខណៈ និងស្មារតីខ្ពស់ មិនលំអៀង និងសុចរិត [...] [និង] "ត្រូវឯករាជ្យក្នុងការបំពេញមុខងាររបស់ខ្លួន និងមិនត្រូវទទួលយក ឬស្វែងរកការណែនាំពីរដ្ឋាភិបាល ឬប្រភពណាមួយផ្សេងទៀតឡើយ"[32]។ មាត្រា ២(១) នៃក្រមសីលធម៌វិជ្ជាជីវៈតុលាការរបស់ អ.វ.ត.ក ក៏បានកំណត់ថា "ចៅក្រមត្រូវតែមិនលំអៀង និងធានាឱ្យមានភាពអនាគតិនៅក្នុងការអនុវត្តភារកិច្ចរបស់ខ្លួន[33]។ ការធានាដូចគ្នាដ៏សំខាន់នេះដែរ ត្រូវបានចែង នៅក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ[34] អនុសញ្ញាអឺរុបស្តីពីសិទ្ធិមនុស្ស ("អនុសញ្ញាអឺរុប")[35] អនុសញ្ញាអាមេរិកស្តីពីសិទ្ធិមនុស្ស[36] និងធម្មនុញ្ញអាហ្វ្រិកស្តីពីសិទ្ធិមនុស្ស និងសិទ្ធិប្រជាជន[37]។ ក្រមសីលធម៌វិជ្ជាជីវៈតុលាការរបស់ អ.វ.ត.ក កំណត់ថា "ចៅក្រមត្រូវតែមិនលំអៀង និងធានាឱ្យមានភាពអនាគតិនៅក្នុងការ

---

[32] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ, ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣, មាត្រា៣(៣) ។

[33] ក្រមសីលធ៌មចៅក្រម អ.វ.ត.ក ។ អនុម័តនៅកិច្ចប្រជុំពេញអង្គនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៨ និងត្រូវបានវិសោធនកម្មនៅកិច្ចប្រជុំពេញអង្គនៃ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០០៨ ។

[34] មាត្រា១៤(១)៖ "ជនគ្រប់រូបត្រូវមានសិទ្ធិឱ្យសាលាក្តីមានសមត្ថកិច្ច ឯករាជ្យ និងមិនលំអៀង ដែលបង្កើតឡើងដោយច្បាប់ជំនុំជម្រះរឿងក្តីរបស់ខ្លួន ដោយសមធ៌ម និងជាសាធារណៈ"។

[35] មាត្រា៦(១)៖ "ជនគ្រប់រូបត្រូវមានសិទ្ធិទទួលបានសវនាការជាសាធារណៈមិនលំអៀង ក្នុងពេលមួយសមហេតុផលដោយ*សាលាក្តីឯករាជ្យ មិនលំអៀង* ដែលបង្កើតឡើងដោយច្បាប់"។ (គូសបញ្ជាក់បន្ថែម)

[36] មាត្រា៨(១)៖ "ជនគ្រប់រូបត្រូវមានសិទ្ធិមានសវនាការមួយ ប្រកបដោយការធានាដ៏សមគួរ និងស្ថិតក្នុងពេលវេលាមួយដ៏សមហេតុផល ដោយតុលាការមានសមត្ថកិច្ច ឯករាជ្យ និងមិនលំអៀង"។ *ជាឧទាហរណ៍ សូមមើល រឿងក្តី Herrera-Ulloa តទល់ Costarica,* តុលាកាសិទ្ធិមនុស្សអន្តរអាមេរិក, សេចក្តីសម្រេច ចុះថ្ងៃទី២ ខែកក្កដា ឆ្នាំ២០០៤, កថាខណ្ឌ១៧១៖ "បុគ្គលណាដែលកំពុងត្រូវជំនុំជម្រះត្រូវទទួលបាននូវការធានាថាចៅក្រម ឬតុលាការដែលជំនុំជម្រះរឿងក្តីរបស់ខ្លួន ត្រូវតែនាំមកនូវភាពសត្យានុម័តបំផុត។ តាមវិធីនេះ តុលាការជម្រុញឱ្យភាគីទាំងឡាយនៃរឿងក្តី និងពលរដ្ឋនៃសង្គមប្រជាធិប្បតេយ្យមានការទុកចិត្ត និងការជឿជាក់ដ៏ចាំបាច់"។

[37] មាត្រា៧(១)៖ "បុគ្គលគ្រប់រូបត្រូវមានសិទ្ធិឱ្យគេជំនុំជម្រះរឿងក្តីរបស់ខ្លួន។ សិទ្ធិនេះរួមមាន៖ [...] (ឃ) សិទ្ធិត្រូវបានជំនុំជម្រះក្នុងពេលវេលាសមរម្យដោយតុលាការ ឬអង្គជំនុំជម្រះដែលឥតលំអៀង។" *ជាឧទាហរណ៍ សូមមើល រឿងក្តីគម្រោងសិទ្ធិធម្មនុញ្ញ តទល់ Nigeria,* គណៈកម្មការអាហ្វ្រិកស្តីពីសិទ្ធិមនុស្សនិងសិទ្ធិពលរដ្ឋ, 87/93 (1995), សេចក្តីសម្រេច, កថាខណ្ឌ១៤។ "ដោយមិនគិតពីលក្ខណៈនៃបុគ្គលជាសមាជិកម្នាក់ៗនៃតុលាការបែបនេះ គ្រាន់តែសមាសភាពរបស់តុលាការអាចបង្ហាញឱ្យគេឃើញមាននូវភាពឥតលំអៀងបានរួចទៅហើយ បើសិនណាជាមិនមានកង្វះនូវភាពឥតលំអៀងជាក់ស្តែងទេនោះ។ ដូច្នេះចំនុចនេះវារំលោភលើមាត្រា ៧.១(ឃ) ហើយ"។

អនុវត្តភារកិច្ចរបស់ខ្លួន”[38]។ ជាក់ស្តែង គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិបានបញ្ជាក់ថា ការធានាឱ្យមានភាពឯករាជ្យ និងភាពអនាគតិ “គឺជាសិទ្ធិដាច់ខាតដែលមិនអាចមានករណីលើកលែងបានឡើយ”[39]។

## ខ. បណ្តឹងជំទាស់ចិត្ត

១៧. វិធាន ៣៤(២) ចែងថា ៖

> “ភាគីអាចធ្វើបណ្តឹងជំទាស់ចិត្តចំពោះសហចៅក្រមស៊ើបអង្កេត ឬ ចៅក្រមនៃអង្គបុរេជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូង ឬ អង្គជំនុំជម្រះតុលាការកំពូល ក្នុងករណីណាមួយដែលចៅក្រមរូបនោះ មាន ឬ ធ្លាប់មានផលប្រយោជន៍ផ្ទាល់ខ្លួន ឬ ហិរញ្ញវត្ថុ ឬ មានការពាក់ព័ន្ធ ដែលអាចធ្វើឱ្យប៉ះពាល់យ៉ាងពិតប្រាកដដល់ភាពអនាគតិ របស់ចៅក្រមរូបនោះឬ អាចបង្កើតឱ្យមានភាពលំអៀង”។

១៨. វិធាន ៣៤(២) មានខ្លឹមសារ និងស្មារតី មិនខុសពីវិធានជាធរមានដែលអនុវត្តនៅតុលាការព្រហ្មទណ្ឌអន្តរជាតិនានា ពោលគឺ តុលាការ ICTY[40] តុលាការ ICTR[41] និងតុលាការ SCSL[42]

---

[38] មាត្រា២(១)។ ក្រមសីលធម៌ចៅក្រម អ.វ.ត.ក, ចុះថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០០៨។

[39] *រឿងក្តី* *Gonzalez del Rio* *តទល់* *Peru,* លេខទំនាក់ទំនង 263/1987, U.N. Doc. CCPR/C/46/D/263/1987, ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៩២ ។

[40] *សូមមើល* វិធាននៃនីតិវិធី និងភស្តុតាង ICTY, វិធាន១៥(ក)។ “ចៅក្រមនឹងមិនអនុញ្ញាតឱ្យចូលរួមក្នុងការជំនុំជម្រះ ឬឧទ្ធរណ៍ ក្នុងករណីណាដែលពិនិត្យទៅឃើញថា គាត់មានឬធ្លាប់មានជាប់ទាក់ទិននិងប្រយោជន៍ផ្ទាល់ខ្លួន ដែលអាចធ្វើឱ្យប៉ះពាល់ដល់អព្យាក្រិតភាព នៃការកាត់ក្តី។ ក្នុងកាលៈទេសៈនោះគាត់ត្រូវដកខ្លួន [...]”។

[41] *សូមមើល* វិធាននៃនីតិវិធី និងភស្តុតាង ICTR, វិធាន១៥(ក)។ “ចៅក្រមនឹងមិនអនុញ្ញាតឱ្យចូលរួមក្នុងការជំនុំជម្រះ ឬឧទ្ធរណ៍ ក្នុងករណីណាដែលពិនិត្យទៅឃើញថា គាត់មានឬធ្លាប់មានជាប់ទាក់ទិននិងប្រយោជន៍ផ្ទាល់ខ្លួន ដែលអាចធ្វើឱ្យប៉ះពាល់ដល់អព្យាក្រិតភាព នៃការកាត់ក្តី។ ក្នុងកាលៈទេសៈនោះគាត់ត្រូវដកខ្លួនពីរឿងក្តីនោះ”។

[42] *សូមមើល* វិធាននៃនីតិវិធី និងភស្តុតាង SCSL, វិធាន១៥(ក)។ “ចៅក្រមនឹងមិនអនុញ្ញាតឱ្យចូលរួមក្នុងការជំនុំជម្រះ ឬឧទ្ធរណ៍ ក្នុងករណីណាដែលពិនិត្យទៅឃើញថាមានមូលដ្ឋានច្បាស់លាស់ណាមួយនៃមន្ទិលសមហេតុផលលើអព្យាក្រិតភាពរបស់គាត់”។

និងតុលាការ ICC[43] (ហៅកាត់រួមថា "តុលាការអន្តរជាតិ")។ ថ្វីបើមានភាពខុសគ្នាបន្តិចបន្តួចនៅក្នុងភាសាដែលយកមកប្រើក្តី ក៏ព្រួយបារម្ភជាសំខាន់អំពីវិធានទាំងនេះគឺដូចគ្នាទៅនឹងក្តីព្រួយបារម្ភនៃយុត្តិសាស្ត្រនៃសិទ្ធិមនុស្សដែលពាក់ព័ន្ធដែលបញ្ជាក់ខាងលើ ពោលគឺថា ចៅក្រមត្រូវតែមាន និងត្រូវតែបង្ហាញឱ្យឃើញថាមានភាពឯករាជ្យ និងភាពអនាគតិ។ ផ្អែកលើក្តីព្រួយបារម្ភនេះ តុលាការអន្តរជាតិជាច្រើនមានភាពស៊ីសង្វាក់គ្នា ក្នុងការបញ្ចូលលក្ខណៈវិនិច្ឆ័យរបស់ខ្លួនចំពោះភាពលំអៀង[44]។

១៩. អនុលោមតាមវិធាន ៣៤(៣) ភាគីដែលធ្វើបណ្តឹងជំទាស់ "ត្រូវបង្ហាញឱ្យច្បាស់លាស់អំពីមូលហេតុនៃបណ្តឹង និងត្រូវមានភស្តុតាងបញ្ជាក់ផងដែរ" ហើយ "ពាក្យបណ្តឹងត្រូវធ្វើឡើងឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន នៅពេលណាដែលភាគីបានដឹងអំពីមូលហេតុនោះ"។

២០. ក្រោមមាត្រា ៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា "ចៅក្រមស៊ើបអង្កេតអាចត្រូវបាន ជំនួសដោយចៅក្រមស៊ើបអង្កេតម្នាក់ទៀត តាមរយៈសេចក្តីសម្រេចរបស់ប្រធានតុលាការ ដើម្បីជាផលប្រយោជន៍នៃការអនុវត្តដ៏ល្អនៃយុត្តិធម៌។ សេចក្តីសម្រេចនោះត្រូវធ្វើឡើងដោយពាក្យសុំដែលមាន

---

[43] *សូមមើល* វិធាននៃនីតិវិធី និងភស្តុតាងរបស់តុលាការ ICC, វិធាន៣៤(១)។ "មូលហេតុនៃបណ្តឹងជំទាស់ចៅក្រម [....] *ក្នុងចំណោមបញ្ហាផ្សេងទៀត* ត្រូវមានដូចខាងក្រោម៖ (ក) ផលប្រយោជន៍ផ្ទាល់ខ្លួនក្នុងរឿងក្តីនោះ ដែលរួមមាន សហព័ទ្ធ, ឪពុកម្តាយឬគ្រួសារជិតស្និទ្ធផ្សេងទៀត ទំនាក់ទំនងវិជ្ជាជីវៈឬផ្ទាល់ខ្លួន ឬទំនាក់ទំនងរបៀបជាអ្នកដឹកនាំឬអ្នកក្រោមបង្គាប់ជាមួយនឹងភាគីទាំងឡាយ [...] (គ) ការមានតួនាទីមុនពេលកាន់ការងារក្នុងការិយាល័យ ក្នុងកំឡុងពេលដែលគាត់ឬនាងអាចត្រូវបានគិតថាបានចូលរួមជាយោបល់ទៅលើរឿងក្តីដែលកំពុងមានបញ្ហា ទៅលើភាគីទាំងឡាយ ឬទៅលើអ្នកតំណាងផ្នែកច្បាប់របស់ពួកគេ ដែលជាសក្សានុម័ត អាចប៉ះពាល់ដល់អព្យាក្រឹតភាពចាំបាច់របស់បុគ្គលពាក់ព័ន្ធ។ (ឃ) ការសំដែងមតិ តាមរយៈទំនាក់ទំនងសារព័ត៌មាន ជាលាយលក្ខណ៍អក្សរ ឬក្នុងសកម្មភាពសាធារណៈផ្សេងៗ ដែលជាសក្សានុម័តអាចប៉ះពាល់មិនល្អដល់អព្យាក្រឹតភាពចាំបាច់របស់បុគ្គលពាក់ព័ន្ធ"។

[44] *សូមមើល រឿងក្តីរដ្ឋអាជ្ញា តទល់ Milan Lukić និង Sredoje Lukić*, IT-98-32/1-T, សេចក្តីសម្រេចលើបណ្តឹងជំទាស់ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០០៩, កថាខណ្ឌ២។ សូមមើលផងដែរ *រឿងក្តីរដ្ឋអាជ្ញា តទល់ Vidoje Blagojevic* , IT-02-60-R, សេចក្តីសម្រេចលើបណ្តឹងជំទាស់ ចុះថ្ងៃទី២ ខែកក្កដា ឆ្នាំ២០០៨, កថាខណ្ឌ២។ *រឿងក្តីរដ្ឋអាជ្ញា តទល់ Vojislav Sesej*, សេចក្តីសម្រេចលើបណ្តឹងជំទាស់ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០៧, កថាខណ្ឌ៤។ *រឿងក្តីរដ្ឋអាជ្ញា តទល់ Florence Hartmann* របាយការណ៍ស្តីពីសេចក្តីសម្រេចលើបណ្តឹងជំទាស់របស់មេធាវីការពារក្តីចំពោះសមាជិកពីររូបនៃអង្គជំនុំជម្រះ និងមន្ត្រីផ្នែកច្បាប់ជាន់ខ្ពស់, ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០០៩, កថាខណ្ឌ២៤។ *រឿងក្តីរដ្ឋអាជ្ញា តទល់ Eliézer Niyitegeka*, ICTR-96-14-A, សេចក្តីសម្រេច ចុះថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០០៤, កថាខណ្ឌ៤៥។

សំអាងហេតុរបស់ព្រះរាជអាជ្ញា ដែលធ្វើឡើងដោយការផ្តើមគំនិតផ្ទាល់ខ្លួន ឬតាមរយៈពាក្យប្តឹងរបស់ភាគីដែលពាក់ព័ន្ធ"។ មូលហេតុនៃការប្តឹងជំទាស់ចៅក្រម រួមទាំងចៅក្រមស៊ើបអង្កេតផងដែរ[45] ត្រូវបានចែងនៅក្នុងមាត្រា ៥៥៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ៖

"ចៅក្រមទាំងឡាយអាចត្រូវបានប្តឹងជំទាស់ ដោយមូលហេតុដូចខាងក្រោមនេះ ៖

- កាលណាចៅក្រម ឬសហព័ទ្ធរបស់ចៅក្រម ឬអតីតសហព័ទ្ធរបស់ចៅក្រម ជាភាគីណាមួយក្នុងរឿងក្តី
- កាលណាចៅក្រមជាញាតិលោហិតរហូតដល់ថ្នាក់ទី៦ ឬញាតិពន្ធ រហូតដល់ថ្នាក់ទី៣ ឬអតីតញាតិពន្ធរហូតដល់ថ្នាក់ទី៣ របស់ភាគី ណាមួយ
- កាលណាចៅក្រមជាអ្នកអាណាព្យាបាលរបស់ភាគីណាមួយ
- កាលណាចៅក្រមដែលទទួលបន្ទុករឿងក្តី ធ្លាប់ ឬកំពុងមានវិវាទនៅតុលាការជាមួយភាគីណាមួយ
- កាលណាចៅក្រមបានធ្វើជាសាក្សី ឬអ្នកជំនាញក្នុងរឿងក្តី
- កាលណាចៅក្រមជា ឬធ្លាប់ជាអ្នកតំណាង ឬជាអ្នកជំនួយឱ្យភាគី ចំពោះរឿងក្តី ឬ
- កាលណាចៅក្រមបានចូលរួមក្នុងការសម្រេចសេចក្តី ក្នុងនាមជា មជ្ឈត្តករចំពោះរឿងក្តី ឬបានចូលរួមក្នុងការសម្រេចសេចក្តីនៅ សាលាដំបូងដែលបានប្តឹងឧបាស្រ័យ ឬការជំនុំជម្រះនៃបណ្តឹងឧទ្ធរណ៍ ដែលបានឧបាស្រ័យ ឬបង្ហាញមតិយោបល់ណែនាំផ្នែកច្បាប់ ចំពោះរឿងក្តី។

## VI. **ឧឡារិករណ៍**

### ក. **ការតព្វកិច្ចអនាគតិរបស់ចៅក្រម ត្រូវអនុវត្តដោយស្មើភាពគ្នា ចំពោះមន្ត្រីផ្នែកច្បាប់ ឬអ្នកស៊ើបអង្កេត ដែលបម្រើការឱ្យសហចៅក្រមស៊ើបអង្កេតដោយផ្ទាល់**

---

[45] មាត្រា ៥៥៦ យោងទៅលើ "មូលហេតុនៃការប្តឹងជំទាស់ចៅក្រមអាសនៈ"។ ទោះជាយ៉ាងណាក៏ដោយ មាត្រា ៥៣ ដែលផ្តល់មូលហេតុសម្រាប់ប្តឹងជំទាស់ចៅក្រមអាសនៈ យោងស្មើគ្នាទៅលើមាត្រា ៥៥៦ ជាមូលហេតុដែលបណ្តឹងជំទាស់ចៅក្រមស៊ើបអង្កេតអាចត្រូវបានធ្វើ។

២១. តាមច្បាប់និងភាពឡូស៊ិក កាតព្វកិច្ចដើម្បីអោយចៅក្រមមានភាពអនាគតិត្រូវតែអនុវត្តដូចគ្នាចំពោះបុគ្គលដែលបម្រើការយ៉ាងជិតស្និទ្ធជាមួយសហចៅក្រមស៊ើបអង្កេត និងអនុវត្តភារកិច្ចរបស់ខ្លួនជាចៅក្រម។

២២. ក្រោមមាត្រា ៥(១) នៃកិច្ចព្រមព្រៀងរវាង អង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ក.ស.ច.ស ត្រូវបានផ្តល់អំណាចផ្តាច់មុខក្នុងកិច្ចការស៊ើបអង្កេតមុនការជំនុំជម្រះក្តី[46]។ ក្រុមមេធាវីការពារក្តីត្រូវបានហាមឃាត់មិនឱ្យអនុវត្តកិច្ចស៊ើបអង្កេត ដោយខ្លួនឯងឡើយ ហើយត្រូវបញ្ជូនសំណើទាំងអស់ទៅ ក.ស.ច.ស[47]។ វិធាន ៥៥(៥) បញ្ជាក់ថា អំណាចដ៏ទូលំទូលាយដែល ក.ស.ច.ស មាន គឺនាំទៅរក "ការបង្ហាញការពិត" ទាក់ទិនទៅនឹងអង្គហេតុណាដែលមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។

២៣. សហចៅក្រមស៊ើបអង្កេតមិនតម្រូវឱ្យដឹកនាំគ្រប់កិច្ចស៊ើបសួរទាំងអស់ ដោយខ្លួនឯងឡើយ។ ក្រោមវិធាន ៦២(១) សហចៅក្រមស៊ើបអង្កេតអាចផ្ទេរអំណាចទៅអោយនគរបាលយុត្តិធម៌ ឬអ្នកស៊ើបអង្កេតដើម្បីបំពេញកិច្ចស៊ើបសួរជំនួសអោយខ្លួន តាមរយៈដីកាចាត់ឱ្យស៊ើបសួរជំនួស។ ក្នុងករណីបែបនេះ ក្រោមវិធាន ៦២(៣) អ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស ៖ (ក) តម្រូវឱ្យធ្វើកំណត់ហេតុជាលាយលក្ខណ៍អក្សរអំពីការស៊ើបសួរ និងលទ្ធផលនៃការស៊ើបសួររបស់ខ្លួន"។ (ខ) អាចស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ស្របតាមវិធាន ៥៩(៦)។ (គ) "អាចឆែកឆេរ និងចាប់យកភស្តុតាង"។

---

[46] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ, ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣, មាត្រា៥(១) ("កិច្ចព្រមព្រៀង")។

[47] ក.ស.ច.ស បានគូសបញ្ជាក់តួនាទីរបស់ភាគីទាក់ទិនទៅនឹងការស៊ើបអង្កេតរបស់ អ.វ.ត.ក៖ "នៅចំពោះមុខតុលាការនេះ អំណាចក្នុងការអនុវត្តកិច្ចស៊ើបសួរត្រូវបានផ្តល់ទៅឱ្យសហចៅក្រមស៊ើបអង្កេតឯករាជ្យតែពីររូប <u>ប៉ុណ្ណោះ</u> ហើយមិនផ្តល់អំណាចនេះទៅឱ្យភាគីទាំងឡាយឡើយ។ <u>មិនមានបទប្បញ្ញត្តិផ្តល់សិទ្ធិឱ្យភាគីអនុវត្តកិច្ច ស៊ើបសួរជំនួសសហចៅក្រមស៊ើបអង្កេតឡើយ</u> ដែលអាចជាករណីនៅក្នុងប្រព័ន្ធនីតិវិធីដទៃទៀត [...] សមត្ថភាព របស់ភាគីក្នុងការជ្រៀតជ្រែកគឺត្រូវបានកំណត់ត្រឹមការស៊ើបសួរបឋម ដែលជាការចាំបាច់បំផុតសម្រាប់ការអនុវត្តសិទ្ធិ របស់ខ្លួនក្នុងការស្នើសុំឱ្យមានកិច្ចស៊ើបសួរ"។ រឿងក្តីនួន ជា ០០២/១៩-០៩-២០០៧-អវតក/កសចស អនុស្សរណៈ របស់ ក.ស.ច.ស ទៅកាន់សហមេធាវីការពារក្តី ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៨ ទំព័រ២ (គូសបញ្ជាក់បន្ថែម)

២៤. ករណីយកិច្ចរបស់ អ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស នៅ អ.វ.ត.ក មាន៖

១. ដោយមានជំនួយការពីមន្ត្រីវិភាគ និងមន្ត្រីច្បាប់ ត្រូវបំពេញកិច្ចស្រាវជ្រាវ និងវិភាគព័ត៌មាន ចម្លើយសាក្សី និងឯកសារជាភស្តុតាងដែលប្រមូលបានក្នុងពេលស៊ើបសួរ

២. កំណត់បង្ហាញនូវចន្លោះប្រហោងនៃភស្តុតាងដែលប្រមូលបាន ការចាំបាច់នាពេលអនាគតសម្រាប់ការស៊ើបសួរ (រួមមានទាំងប្រភពនៃភស្តុតាងដើម្បីធ្វើការស្រាវជ្រាវរុករក) អង្គការឧក្រិដ្ឋកម្ម និងរចនាសម្ព័ន្ធនៃសកម្មភាពឧក្រិដ្ឋ ក៏ដូចជារចនាសម្ព័ន្ធនៃបញ្ជាការយោធា និងនយោបាយ

៣. អនុលោមទៅតាមដីកាចាត់អោយស៊ើបសួរជំនួស រៀបចំ និងបំពេញបេសកកម្មដល់ទីកន្លែង ជាពិសេសដើម្បីធ្វើការស្តាប់យកចម្លើយសាក្សីពាក់ព័ន្ធ និងឯកសារជាភស្តុតាង

៤. ធានាអោយមានការគ្រប់គ្រង និងការពារសមរម្យនូវព័ត៌មាន និងភស្តុតាងដែលប្រមូលបាន ដាក់សេចក្តីសន្និដ្ឋាននៃបេសកកម្មពីមុនដែលត្រឹមត្រូវអំពីលទ្ធផល និងព័ត៌មានបានមកពីកិច្ចស៊ើបសួរ ក៏ដូចជាធានាអោយមានការបញ្ចប់នូវរាល់ដំណាក់កាលភស្តុតាង និងរដ្ឋបាលផ្សេងៗទាំងអស់ដែលទំនុកបំរុងដល់បេសកកម្ម

៥. ត្រៀមរៀបចំនូវរូបភាព តារាងដែលចាំបាច់ និងឧបករណ៍បង្ហាញរូបភាពដើម្បីធ្វើបទបង្ហាញនូវទិន្នន័យតាមបែបសោតទស្សន៍

៦. ធ្វើជាជំនួយដល់សហចៅក្រមស៊ើបអង្កេត និងក្រុមស្រាវជ្រាវផ្នែកច្បាប់ ក្នុងការវាយតម្លៃព័ត៌មាន ជ្រើសរើសធាតុផ្សំសំខាន់ៗ និងព័ត៌មានថ្មីៗដែលទាក់ទងជាមួយនឹងព័ត៌មានដែលមានស្រាប់ ធ្វើការចងក្រងព័ត៌មាន និងវិភាគនូវការរកឃើញ។

៧. បំពេញភារកិច្ចផ្សេងទៀតដែលសហចៅក្រមស៊ើបអង្កេត និងមេក្រុមស៊ើបអង្កេតយល់ថាចាំបាច់[48]។

២៥. ក្នុងការបំពេញកិច្ចស៊ើបសួរជំនួសទាំងនេះ អ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស ក្នុងលក្ខណៈដូចគ្នាទៅនឹងសហចៅក្រមស៊ើបអង្កេតខ្លួនឯងដែរ ត្រូវមានកាតព្វកិច្ច "អនុវត្តការស៊ើបសួរដោយភាពអនាគតិ ទោះបីជាភស្តុតាងដែលនឹងរកបាននោះជាភស្តុតាងដាក់បន្ទុក ឬភស្តុតាងដោះបន្ទុកក៏

---

[48] *សូមមើល* អ្នកស៊ើបអង្កេត L-3, ដំណឹងជ្រើសរើសបុគ្គលិក Vacancy Announcement Number: 08-LEG-DESA-419528-S-Phnom-Penh ចុះថ្ងៃទី ៣ តុលា ២០០៨ ។

ដោយ"[49]។ ដូច្នេះ អ្នកស៊ើបអង្កេត របស់ ក.ស.ច.ស ត្រូវតែស្ថិតនៅក្រោមកាតព្វកិច្ចភាពអនាគតិត ទៅទៀត នៅពេលដែលគាត់អនុវត្តកិច្ចស៊ើបសួរណាមួយក្នុងនាម ក.ស.ច.ស។

២៦. បន្ថែមទៅនឹងកាតព្វកិច្ចស៊ើបសួររបស់ខ្លួន សហចៅក្រមស៊ើបអង្កេតក៏មានតួនាទីវិនិច្ឆ័យសេចក្តីផងដែរក្នុងអំឡុងដំណាក់កាលស៊ើបសួរ។ នៅក្នុងលក្ខណៈនេះ ពួកគាត់ដើរតួដូច ជាចៅក្រមអង្គបុរេជំនុំជម្រះ ឬជាអង្គបុរេជំនុំជម្រះ នៅតុលាការអន្តរជាតិពិសេស Ad hoc នានាផងដែរ ដែលត្រូវសម្រេចសេចក្តីដោយអនាគតិ ទៅលើបណ្តឹងមុនអង្គសេចក្តីនានាទាក់ទងបញ្ហាផ្សេងៗជាច្រើន។ នៅក្នុងសំណុំរឿង ០០២ ក.ស.ច.ស ក្នុងចំណោមពាក្យស្នើសុំផ្សេងៗទៀត បានប្រឈមរួចហើយទៅនឹងពាក្យសុំជាច្រើនទាក់ទងឃុំខ្លួនបណ្តោះអាសន្ន[50] ការអនុវត្តទម្រង់ទទួលខុសត្រូវព្រហ្មទណ្ឌសហកម្មឧក្រិដ្ឋកម្មរួម[51] ផលប៉ះពាល់នៃអំពើពុករលួយនៅ អ.វ.ត.ក ទៅលើភាពយុត្តិធម៌នៃដំណើរការនីតិវិធី[52] អានុភាពនៃព្រះរាជក្រឹត្យលើកលែងទោស អៀង សារី និងការកាត់ទោសពីមុនរបស់គាត់ក្នុងឆ្នាំ១៩៧៩[53] និងភាពអាចទទួលយកបានឬភស្តុតាងដែលទទួលបានដោយការធ្វើទារុណកម្ម[54]។

២៧. ភារកិច្ចរបស់មន្ត្រីផ្នែកច្បាប់ ក្នុងការផ្តល់យោបល់ដល់សហចៅក្រមស៊ើបអង្កេត នៅអ.វ.ត.ក គឺ ៖

១. ការងារប្រតិបត្តិ : ធ្វើការយ៉ាងជិតស្និទ្ធជាមួយអ្នកស៊ើបអង្កេត អ្នកវិភាគ និងបុគ្គលិកផ្នែកច្បាប់ផ្សេងទៀត រួមមានការត្រួតពិនិត្យលើមន្ត្រីផ្នែកច្បាប់អម និង

---

[49] វិធាន ៥៥(៥)។ គូសបញ្ជាក់បន្ថែម ។

[50] *ឧទាហរណ៍ សូមមើល រឿងក្តី អៀង សារី,* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, ពាក្យសុំរបស់លោក អៀង សារី ប្រឆាំងនឹងដីកាបន្តចិរវេលាឃុំខ្លួន, ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៨ ។

[51] *រឿងក្តី អៀង សារី,* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស,ពាក្យស្នើសុំរបស់លោក អៀង សារី ប្រឆាំងនឹងការអនុវត្តន៍នៅ អ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវខាងព្រហ្មទណ្ឌ ដែលគេហៅថា *សហកម្មឧក្រិដ្ឋកម្មរួម* (JCE), ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៨។

[52] *រឿងក្តី នួន ជា,* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, សំណើលើកទី១១ ស្នើសុំបើកកិច្ចស៊ើបសួរ, ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០០៩។

[53] *រឿងក្តី អៀង សារី,* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន, ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៧។

[54] *រឿងក្តី អៀង ធីរិទ្ធ,* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, សំណើរបស់មេធាវីការពារស្នើសុំច្រានចោលភស្តុតាងដែលបានមកដោយការធ្វើទារុណកម្ម" ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៩។

ជំនួយការផ្នែកច្បាប់ និងអ្នកហាត់ការផ្នែកច្បាប់ ដើម្បីវាយតម្លៃបទចោទដែលត្រូវបានលើកឡើង ព្រមទាំងភស្តុតាងដែលត្រូវបានដាក់ដោយភាគីទាំងឡាយ និងការវាយតម្លៃនៃតម្រូវការចំពោះវិធានការស៊ើបសួរបន្ថែម។ ផ្តល់យោបល់ដល់សហចៅក្រមស៊ើបអង្កេត អំពីបទចោទទាំងឡាយណាដែលត្រូវបានគាំទ្រ និងអំពីអត្តសញ្ញាណនៃបុគ្គលណាដែលត្រូវបានចោទប្រកាន់ និងនាំយកទៅជំនុំជម្រះទោស។ ជួយផ្តល់យោបល់ផ្នែកច្បាប់ដល់សហចៅក្រមស៊ើបអង្កេត អ្នកស៊ើបអង្កេត និងអ្នកវិភាគអំពីច្បាប់ និងនីតិវិធីព្រហ្មទណ្ឌកម្ពុជា និងអំពីបញ្ហាច្បាប់ដទៃទៀតដែលកើតមាន។

២. ដំណើរការនីតិវិធីមុនជំនុំជម្រះក្តី : ផ្តល់ការឆ្លើយតបគតិយុត្តិឱ្យបានទាន់ពេលវេលា និងសមស្របទៅនឹងសំណើ និងបណ្តឹងរបស់ភាគីទាំងឡាយ ដែលពាក់ព័ន្ធរួមទាំងការអនុវត្ត និងសហសម្របសម្រួល ការស្រាវជ្រាវផ្នែកច្បាប់ឱ្យបានស៊ីជម្រៅអំពីច្បាប់ និងនីតិវិធីព្រហ្មទណ្ឌកម្ពុជា និងអន្តរជាតិជាធរមាន អំពីបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ និងអំពីបញ្ហាច្បាប់ផ្សេងទៀតដែលកើតមាន។

៣. កិច្ចសហការ : ក្នុងភារកិច្ចដែលត្រូវបានចាត់តាំងជាផ្លូវការ គឺត្រូវសហការ និងធ្វើការយ៉ាងជិតស្និទ្ធជាមួយបុគ្គលិកទាំងអស់នៅក្នុង និងខាងក្រៅ អ.វ.ត.ក ដើម្បីជំរុញស្មារតីក្រុមឱ្យបានរឹងមាំ និងដើម្បីធានានូវការអនុវត្តឱ្យមានប្រសិទ្ធភាពនៃក្របខណ្ឌកូនកាត់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អវតក)។

៤. ការងាររដ្ឋបាល : ជួយក្នុងការបង្កើត និងពង្រាងសំណើទាក់ទិននឹងសេចក្តីណែនាំអនុវត្ត/វិធានផ្ទៃក្នុង និងធ្វើសេចក្តីពង្រាងបទបញ្ជារដ្ឋបាល និងបទដ្ឋានអនុវត្តប្រតិបត្តិរបស់ ក.ស.ច.ស។ ផ្តល់ការជួយគាំទ្រ ក្នុងការបកប្រែក្នុងករណីចាំបាច់ និងជួយកិច្ចការរដ្ឋបាលពាក់ព័ន្ធដទៃទៀតនៅពេលមានការស្នើសុំ[55]។

២៨. មន្ត្រីផ្នែកច្បាប់ គឺតម្រូវអោយផ្តល់សំអាងហេតុផ្នែកច្បាប់ដោយមិនលំអៀង និងសត្យានុម័ត និងផ្តល់ឱវាទដល់សហចៅក្រមស៊ើបអង្កេតអំពីបញ្ហាច្បាប់នានា។ បញ្ហានេះអាចរួមទាំងការធ្វើសេចក្តីពង្រាងអនុស្សរណៈច្បាប់សម្រាប់សហចៅក្រមស៊ើបអង្កេត អំពីបញ្ហាស្មុគស្មាញដែល

---

[55] *សូមមើល* អ្នកផ្តល់ឱវាទផ្នែកច្បាប់ (២ ប៉ុស្តិ៍), សេចក្តីប្រកាសជ្រើសរើសបុគ្គលិកលេខ 07-LEG-DESA-416275-S-PHNOM-PENH ចេញផ្សាយថ្ងៃទី ១៣ ខែវិច្ឆិកា ឆ្នាំ២០០៧។

ហួសពីជំនាញរបស់ពួកគាត់។ មន្ត្រីផ្នែកច្បាប់ ជាភាពឡូស៊ិក ក៏ប្រហែលជា "បាន<u>ផ្តល់ការឆ្លើយតបតាមបែបតុលាការឱ្យបានទាន់ពេលវេលា និងសមស្រប ទៅនឹងសំណើនិងបណ្តឹងរបស់ភាគីទាំងឡាយ"</u>[56]។ ក្នុងប្រព័ន្ធព្រហ្មទណ្ឌជាតិ នៅពេលដែលសហចៅក្រមស៊ើបអង្កេតទាំងពីរ ទំនងជាបានបំពេញការងារផ្តាច់មុខដោយខ្លួនឯង នៅមុនត្រូវបានជ្រើសតាំងឱ្យមកបម្រើការដោយ អ.វ.ត.ក[57] តាមកម្មវត្ថុ និងទំហំនៃរឿងក្តី មានន័យថាសហចៅក្រមស៊ើបអង្កេតត្រូវធ្វើការស្រាវជ្រាវ និងតាក់តែងសេចក្តីសម្រេចរបស់ខ្លួនដោយខ្លួនឯងផ្ទាល់។ ផ្ទុយទៅវិញ ចំនួនជាក់លាក់នៃសេចក្តីសម្រេច និងដីកាសម្រេចដែលចេញដោយចៅក្រមនៅក្នុងដំណើរការនីតិវិធីតុលាការព្រហ្មទណ្ឌអន្តរជាតិ ជាមួយនឹងភាពស្មុគស្មាញនៃបញ្ហាទាំងនេះតម្រូវថា ចៅក្រមត្រូវមានជំនួយពីមន្ត្រីផ្នែកច្បាប់ដែលមានសមត្ថភាពល្អ។ ជាក់ស្តែង នេះគឺជាមូលហេតុតែមួយគត់ក្នុងការមានបុគ្គលិកដ៏ច្រើននៅក្នុង ក.ស.ច.ស ។

២៩. លើសពីនេះទៀត ទោះបីជាមុខតំណែងត្រូវបានកំណត់ថាជាមន្ត្រីផ្នែកច្បាប់ យ៉ាងណាក៏ដោយមានភស្តុតាងបង្ហាញនៅក្នុងការពណ៌នាអំពីការងារដែលត្រូវបំពេញថា ភារកិច្ចស៊ើបសួរនានាស្ថិតនៅក្រោមមុខដំណែងនេះ រួមទាំង "ការវាយតម្លៃអំពីតម្រូវការវិធានការស៊ើបសួរបន្ថែម"។ ដូច្នេះកាតព្វកិច្ចច្បាស់លាស់នៃភាពអនាគតិ ដែលដាក់ទៅលើអ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស ដូចដែល

---

[56] *ដូចយោងទំព័រខាងលើ។*

[57] យោងតាមគេហទំព័រ UNAKRT សហចៅក្រមស៊ើបអង្កេត លោក Marcel Lemonde បានចំណាយពេលនៃជីវិតអាជីពទាំងមូលរបស់គាត់ធ្វើការក្នុងប្រទេសបារាំង។ លោក Lemonde "បានចូលក្នុងផ្នែកតុលាការក្នុងឆ្នាំ១៩៧៦ និងបានមានមុខងារជាចៅក្រមស៊ើបអង្កេតក្នុង Annecy បន្ទាប់មកទៀតនៅ Lyon ដោយធ្វើជា អនុប្រធានតុលាការជាន់ខ្ពស់ក្រុង Lyon ជានាយករងសាលាតុលាការជាតិ ជាចៅក្រមនៅក្នុងតុលាការឧទ្ធរណ៍ Versailles និងជាប្រធានអង្គជំនុំជម្រះឧក្រិដ្ឋកម្មនៃតុលាការឧទ្ធរណ៍ក្នុង Bastia។ តាំងពីខែកុម្ភៈ ឆ្នាំ២០០៥មក គាត់បានធ្វើជាប្រធានក្នុងអង្គជំនុំជម្រះព្រហ្មទណ្ឌនៃតុលាការឧទ្ធរណ៍ក្រុងប៉ារីស។ លោក Lemonde ក៏ជាប្រធានសមាគមន៍ចៅក្រមស៊ើបអង្កេតប្រទេសបារាំង ចាប់ពីឆ្នាំ១៩៨៤ ដល់១៩៨៧"។

ចៅក្រម យូ ប៊ុនឡេង "ធ្លាប់បានបំរើការងារជាចៅក្រមនៅសាលាឧទ្ធរណ៍កម្ពុជា និងត្រូវបានតែងតាំងជាប្រធានសាលាឧទ្ធរណ៍នៅឆ្នាំ ១៩៩៧ ។ ពីមុន គាត់ធ្លាប់បានបំរើការងារនៅក្រសួងយុត្តិធម៌ អស់រយៈពេល ១១ឆ្នាំ ។ មិនមានការបញ្ជាក់ណាមួយថាគាត់ពីមុនធ្លាប់បានបំរើការងារនៅក្នុងច្បាប់អន្តរជាតិឡើយ។" *សូមមើល* កាសែតភ្នំពេញប៉ុស្តិ៍ ចុះថ្ងៃទី ១២ កុម្ភៈ ២០០៨ ក្រោមចំណងជើងថា "សន្ទានុក្រមតុលការ (Tribunal Glossary)" ដែលអាចរកមើលបានតាមគេហទំព័រ៖ http://www.phnompenhpost.com/index.php/component/option,com_myblog/Itemid,149/show,Glossary-Photo-948.html/

ត្រូវបានបញ្ជាក់ខាងលើ[58] តាមភាពឡូស៊ិក នឹងត្រូវអនុវត្តស្មើភាពគ្នាទៅលើមន្ត្រីផ្នែកច្បាប់ដែរ នៅពេលដែលពួកគាត់បំពេញកិច្ចស៊ើបសួរសម្រាប់ ក.ស.ច.ស ។

៣០. ដូច្នេះ ក្នុងខណៈដែលមន្ត្រីផ្នែកច្បាប់មិនមែនជាចៅក្រមជាផ្លូវការ ពួកគាត់អាចអនុវត្តទាំងភារកិច្ចស៊ើបសួរ និងភារកិច្ចវិនិច្ឆ័យសេចក្តី។ មន្ត្រីផ្នែកច្បាប់ដែលបម្រើការឱ្យសហចៅក្រមស៊ើបអង្កេត គឺជា "ក្រុមប្រឹក្សាសម្រាប់ការពិគ្រោះយោបល់ ចំពោះការយល់ឃើញណាដែលមិនច្បាស់លាស់ និងជាអ្នកស្រាវជ្រាវផ្នែកច្បាប់ ដែលស្វែងរកមូលដ្ឋានសំអាងផ្លូវច្បាប់ប្រើប្រាស់ជាឯកសារយោងទាំងឡាយដែលប៉ះពាល់ដល់សេចក្តីសម្រេច។ ក្រឡាបញ្ជីអាចដឹងពីការយល់ឃើញរបស់ចៅក្រមនៅក្នុងលក្ខណៈមួយ ដែលភាគីនៅក្នុងពាក្យបណ្តឹង និងសមាជិកគ្រួសារជិតបំផុតរបស់ [ចៅក្រម] មិនអាចដឹងបាន"[59]។ មន្ត្រីផ្នែកច្បាប់ដែលបម្រើការឱ្យសហចៅក្រមស៊ើបអង្កេត ត្រូវតែមានភាពអនាគតិក្នុងការផ្តល់យោបល់ និងការជួយដែលពួកគាត់ផ្តល់ជូន។ បុរេវិនិច្ឆ័យទៅលើបញ្ហាដែលបានលើកឡើងដោយភាគីទាំងឡាយ ការផ្តល់យោបល់ដែលលំអៀងទៅភាគីម្ខាង ឬការមិនអើពើក្នុងការស្រាវជ្រាវបញ្ហាជាក់លាក់ចេញពីគ្រប់ទស្សនវិស័យទាំងអស់ នេះរំលោភទៅលើភារកិច្ចអនាគតិដែលដាក់មកលើមន្ត្រីផ្នែកច្បាប់។

៣១. ផ្ទុយទៅវិញ ថ្វីបើសហចៅក្រមស៊ើបអង្កេតត្រូវអនុវត្តកិច្ចស៊ើបសួរ ឬតាក់តែងសេចក្តីសម្រេចរបស់ខ្លួនដោយអនាគតិ បុគ្គលិកដែលតាក់តែងសេចក្តីសម្រេច ឬអនុវត្តកិច្ចស៊ើបសួរជំនួសសហចៅក្រមស៊ើបអង្កេតមិនស្ថិតក្រោមកាតព្វកិច្ចបែបនេះទេ ការយល់ឃើញនោះពិតជាមិនសមតាមន័យឡូស៊ិកទាំងស្រុងឡើយ។ សិទ្ធិរបស់ជនត្រូវចោទក្នុងការទទួលបានដំណើរការនីតិវិធីតាមផ្លូវតុលាការប្រកបដោយយុត្តិធម៌ និងមិនលំអៀង នឹងអាស្រ័យទៅលើឱកាសដែលថាអ្នកណាទទួលខុសត្រូវក្នុងការចេញសេចក្តីសម្រេច ឬកិច្ចស៊ើបសួរក្នុងរឿងក្តីនេះ។

**ខ. បណ្តឹងជំទាស់ចៅក្រម អ.វ.ត.ក ក្រោមវិធាន ៣៤(២) ចំពោះកង្វះខាតភាពអនាគតិ ត្រូវអនុវត្តស្មើភាពគ្នាចំពោះមន្ត្រីផ្នែកច្បាប់ ឬអ្នកស៊ើបអង្កេតដែលបម្រើការឱ្យសហចៅក្រមស៊ើបអង្កេតដោយផ្ទាល់**

---

[58] *សូមមើល* វិធាន ៥៥(៥) ។

[59] *រឿងក្តី Hall តទល់ Small Business Administration,* 695 F.2d 175, 179 (5th Cir. 1983) ។

៣២. កាតព្វកិច្ចនៃភាពអនាគតិដែលដាក់មកលើចៅក្រមក្រោមរដ្ឋធម្មនុញ្ញ កិច្ចព្រមព្រៀង និងវិធាននានាត្រូវបានអនុម័តនៅ អ.វ.ត.ក តាមប្រព័ន្ធនៃបណ្តឹងជំទាស់ចិត្ត ដែលមានចែងក្នុងវិធាន ៣៤។

៣៣. ក្នុងការវាយតម្លៃអំពីបណ្តឹងជំទាស់ចិត្ត អង្គជំនុំជម្រះតុលាការកំពូលរបស់តុលាការ ICTY[60] និងអង្គបុរេជំនុំជម្រះ[61] បានយល់ឃើញថា ចៅក្រមនឹងត្រូវចាត់ទុកថាខ្វះភាពឯករាជ្យ និងភាពអនាគតិ ហើយដូច្នេះត្រូវស្ថិតក្រោមការប្តឹងជំទាស់ចិត្ត ប្រសិនបើ "មានភាពលំអៀងពិតប្រាកដកើតឡើង" ("លក្ខណៈវិនិច្ឆ័យពីអត្តនោម័តិ") ឬក៏ "មានការលេចឡើងនូវភាពលំអៀងដែលមិនអាចទទួលយកបាន" (លក្ខណៈវិនិច្ឆ័យពីសត្យានុម័តិ")[62]។ លក្ខណៈវិនិច្ឆ័យពីសត្យានុម័តិ ត្រូវបានបំពេញនៅពេលដែល :

(i) ចៅក្រមជាភាគីមួយរូបនៃរឿងក្តី ឬមានផលប្រយោជន៍នៃកម្មសិទ្ធិ ឬហិរញ្ញវត្ថុនៅក្នុងលទ្ធផលនៃរឿងក្តីនោះ ឬ ប្រសិនបើសេចក្តីសម្រេចរបស់ចៅក្រមនោះនឹងនាំឱ្យមានការជំរុញនូវបុព្វហេតុ ដែលរូបគាត់ជាប់ពាក់ព័ន្ធក្នុងនោះ ជាមួយគ្នានឹងភាគីមួយក្នុងចំណោមភាគីទាំងអស់។ ស្ថិតនៅក្រោមកាលៈទេសៈទាំងនេះ ចៅក្រមនោះត្រូវបានដកសិទ្ធិដោយស្វ័យប្រវត្តិពីរឿងក្តីនោះ ឬ

(ii) កាលៈទេសៈទាំងនោះ នឹងនាំឱ្យអ្នកសង្កេតការណ៍ប្រកបដោយវិចារណញ្ញាណ ដែលទទួលបានព័ត៌មានត្រឹមត្រូវ មានការយល់ដឹងច្បាស់លាស់ពីភាពលំអៀង[63]។

---

[60] *រឿងក្តីរដ្ឋអាជ្ញា តទល់ Furundžija*, IT-95-17/1-A, "សេចក្តីសម្រេច", ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០០ ("សេចក្តីសម្រេចរឿងក្តី *Furundžija*) ។

[61] សេចក្តីសម្រេចបណ្តឹងជំទាស់ចិត្តចៅក្រម ន័យ ថុល, កថាខណ្ឌ២០ ។

[62] សេចក្តីសម្រេចរឿងក្តី *Furundžija*, កថាខណ្ឌ១៨៩ ។

[63] សេចក្តីសម្រេចរឿងក្តី *Furundžija*, កថាខណ្ឌ១៨៩។ *សូមមើលផងដែរ រឿងក្តីរដ្ឋអាជ្ញា តទល់ Karemera និងអ្នកផ្សេងទៀត,* ICTR-98-44-T, "សេចក្តីសម្រេចលើសំណើសុំប្តឹងជំទាស់ចិត្តចៅក្រមជំនុំជម្រះដោយ Karemera" ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០៤ ("សេចក្តីសម្រេចក្នុងរឿងក្តី *Karemera*"), កថាខណ្ឌ ៨។ *រឿងក្តីរដ្ឋអាជ្ញា តទល់ Sesay និងអ្នកផ្សេងទៀត,* SCSL-04-15-A, "សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារ ស្នើសុំប្តឹងជំទាស់ចិត្ត Justice Robertson ពីអង្គជំនុំជម្រះសាលាឧទ្ធរណ៍", ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៤ ("សេចក្តីសម្រេចក្នុងរឿងក្តី Sesay"), កថាខណ្ឌ៤។ *រឿងក្តីរដ្ឋអាជ្ញា តទល់ Blagojević និងអ្នកផ្សេងទៀត,* IT-02-60, "សេចក្តីសម្រេចលើបណ្តឹងរបស់ Blagojević អនុលោមតាមវិធាន ១៥(ខ)", ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៣ ("សេចក្តីសម្រេចក្នុងរឿងក្តី *Blagojević*"), កថាខណ្ឌ ៨។ អ្នកអង្កេតការអព្យាក្រឹតគឺជាបណ្តឹងជំទាស់ចិត្តរបស់ អៀង សារី ទៅលើអ្នកស៊ើបអង្កេត ក.ស.ច.ស STEPHEN HEDER និងមន្ត្រីច្បាប់ DAVID BOYLE

៣៤. ការបង្កើតលក្ខណៈវិនិច្ឆ័យបែបបនេះ គឺស្រដៀងទៅនឹងលក្ខណៈវិនិច្ឆ័យដែលអនុវត្តនៅក្នុងយុត្តាធិការជាច្រើនក្នុងប្រទេស រួមទាំងប្រព័ន្ធកុំម៉ុនឡ (common-law) និងប្រព័ន្ធស៊ីវិលឡ (civil-law)[64] ហើយឆ្លុះបញ្ចាំងទស្សនរបស់ Lord Hewart: "វាមិនគ្រាន់តែមានសារៈសំខាន់ខ្លះៗឡើយ ប៉ុន្តែវាមានសារៈសំខាន់ជាមូលដ្ឋាន ដែលយុត្តិធម៌មិនគួរតែជាអ្វីដែលសម្រេចបានតែប៉ុណ្ណោះទេ *ប៉ុន្តែត្រូវតែបង្ហាញឲ្យឃើញថាមានដំណើរការដោយយុត្តិធម៌យ៉ាងច្បាស់ និងដោយគ្មានមន្ទិល*"[65] ទៀតផង។

៣៥. មូលហេតុនៅខាងក្រោយលក្ខណៈវិនិច្ឆ័យទាំងពីរនេះ គឺថា ភាពអនាគតិនៃដំណើរការតុលាការមានសារៈសំខាន់យ៉ាងខ្លាំង ដែលចៅក្រមអាចត្រូវបានប្តឹងជំទាស់ សូម្បីមានត្រឹមតែ*ការលេចចេញនូវភាពលំអៀង*ក៏ដោយ ។ ហេតុដូច្នេះ "សិទ្ធិមនុស្សជាមូលដ្ឋានដើម្បីទទួលបានការកាត់សេចក្តីនៅចំពោះមុខតុលាការមួយឯករាជ្យ និងមិនលំអៀង" ត្រូវបានចាត់ទុកថាជា "សមាសភាពជាសារវន្ត" នៃការធានានូវការជំនុំជម្រះទោសដោយយុត្តិធម៌[66]។ ដូច្នេះហើយបានជា តុលាការ ICTY បានអះអាងថា វិធានច្បាប់នានារបស់ខ្លួន "ត្រូវតែបកស្រាយឲ្យបានទូលំទូលាយ ដើម្បីអនុញ្ញាតឲ្យមានការលើកឡើងនូវ*មូលហេតុនៃភាពអនាគតិ* [...] ធ្វើជាមូលដ្ឋានសម្រាប់ការប្តឹងជំទាស់"[67]។

---

"អ្នកដែលមានចំណេះដឹងគ្រប់កាលៈទេសៈពាក់ព័ន្ធទាំងអស់ រួមទាំងចំណេះដឹងនៃសុច្ចរិតភាព និងអព្យាក្រឹតភាព ដែលបង្កើតជាផ្នែកមួយនៃចំណេះដឹងមូលដ្ឋាន ហើយអព្យាក្រឹតភាពនេះគឺជាកាតព្វកិច្ចមួយដែលចៅក្រមត្រូវតែប្រកាន់យក"។ សេចក្តីសម្រេចរឿងក្តី *Furundžija*, កថាខណ្ឌ ១៩០ (*quoting R.D.S. v. The Queen* (1997) Can. Sup. Ct., ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ១៩៩៧, កថាខណ្ឌ ១១១)។ *សូមមើលផងដែរ រឿងក្តីរដ្ឋអាជ្ញា តទល់* Brdjanin និង Talic, IT-99-36-T, សេចក្តីសម្រេចលើពាក្យសុំរួមគ្នា ដើម្បីប្តឹងជំទាស់ទៅ Trial Chamber Hearing the Brdjanin-Talic Trial (ចៅក្រមជំនុំជម្រះ), ចុះថ្ងៃទី៣ ខែឧសភា ឆ្នាំ២០០២, កថាខណ្ឌ ១៧។ SCSL បានបង្កើតការសាកល្បងមួយដូចខាងក្រោម៖ "សំនួរដែលសំខាន់នោះគឺថាតើអ្នកអង្កេតការឯករាជ្យ ត្រូវនិយាយ ឬបុគ្គលអព្យាក្រឹត ការអានអត្ថបទទាំងនោះនឹងផ្តល់ឲ្យមាននូវហេតុផលស្របច្បាប់ ក្នុងការភ័យខ្លាចថា [ចៅក្រម] ខ្វះភាពអព្យាក្រឹត"។ សេចក្តីសម្រេចក្នុងរឿងក្តី Sesay កថាខណ្ឌ១៥ ។

[64] *សូមមើល* សេចក្តីសម្រេចរឿងក្តី *Furundžija*, កថាខណ្ឌ ១៨៣-១៨៨ ( *See Furundžija* Judgment, paras. 183–188 (canvassing (i) UK, Australian, Canadian, South African, and US case law and (ii) German, French, Italian, and Swedish criminal codes)

[65] *រឿងក្តី R. តទល់ Sussex Justices, ex parte McCarthy* [1924] 1 K.B. 256, 259 (គូសបញ្ជាក់បន្ថែម) ។ *សូមមើលផងដែរ* សេចក្តីសម្រេចរឿងក្តី *Furundžija*, កថាខណ្ឌ១៩៥។

[66] សេចក្តីសម្រេចរឿងក្តី *Furundžija*, កថាខណ្ឌ ១៧៧ ។

[67] សេចក្តីសម្រេចរឿងក្តី *Karemera* កថាខណ្ឌ ៧ (គូសបញ្ជាក់បន្ថែម) ។

៣៦. ហេតុដូច្នេះ សារៈសំខាន់ជាសារវ័ន្តនៃសិទ្ធិទទួលបានតុលាការមួយឯករាជ្យ និងមិនលំអៀង ផ្តល់អាណត្តិជាប្រយោជន៍ដល់ការអនុវត្តវិធាន ៣៤ នេះអោយបានទូលំទូលាយ ទាក់ទិនទៅនឹងគោលដៅនៃបណ្តឹងជិតចិត្ត ព្រមទាំងមូលហេតុនានានៃភាពអនាគតិដែលអាចត្រូវបានលើកឡើង។ ទោះបីជាពាក្យពេចន៍នៃវិធាន ៣៤(២) ដែលចែងដោយអនុញ្ញាតឲ្យមានត្រឹមតែបណ្តឹងជិតចិត្ត "ចៅក្រម" យ៉ាងណាក៏ដោយ សូមជម្រាបជូនដោយសេចក្តីគោរពថា ពាក្យនេះត្រូវតែមានការអានឲ្យបានទូលំទូលាយ ដើម្បីបញ្ចូលអ្នកទាំងឡាយណាដែលអនុវត្តភារកិច្ចតុលាការក្នុងនាម ក.ស.ច.ស សម្រាប់ហេតុផលសំខាន់ប្រាំ។

៣៧. ទីមួយ វិធាន ៣៤ នៃវិធានផ្ទៃក្នុង មិនអាចយកទៅប្រើប្រាស់ដើម្បីកម្រិតព្រំដែន ដោយមិនសមទំនងទៅលើសិទ្ធិទទួលបានការកាត់សេចក្តីដោយតុលាការឯករាជ្យ និងមិនលំអៀង ដែលត្រូវបានការពារដោយរដ្ឋធម្មនុញ្ញ និងសន្ធិសញ្ញាអន្តរជាតិដែលប្រទេសកម្ពុជាគឺជាភាគីនោះទេ[68]។ វិធាន ៣៤ នៃវិធានផ្ទៃក្នុង កំណត់នូវលក្ខខណ្ឌជាផ្លូវការសម្រាប់ធ្វើបណ្តឹងជិតចិត្ត។ ហេតុនេះ វិធាននេះមិនបានផ្តល់នូវសិទ្ធិបន្ថែមទៀតដល់ភាគីនោះទេ ប៉ុន្តែបានអនុវត្តនូវសិទ្ធិទទួលបាននូវការកាត់សេចក្តីដោយយុត្តិធម៌ ដូចដែលបានកំណត់ក្នុងរដ្ឋធម្មនុញ្ញនិងកិច្ចព្រមព្រៀង។ អង្គបុរេជំនុំជម្រះបានលើកឡើងថា វិធានផ្ទៃក្នុង មានបឋមភាពទៅលើក្រមនីតិវិធីព្រហ្មទណ្ឌ[69]។ ទោះបីជាយ៉ាងណាក៏ដោយពុំមានការកំណត់អំពីលក្ខណៈនៃរដ្ឋធម្មនុញ្ញ ចំពោះវិធានផ្ទៃក្នុងនៅអង្គជំនុំជម្រះវិសាមញ្ញនោះទេ។ ដោយសារតែរដ្ឋធម្មនុញ្ញគឺជា "ច្បាប់កំពូលនៃព្រះរាជាណាចក្រកម្ពុជា"[70] រីឯអង្គជំនុំជម្រះវិសាមញ្ញ "ត្រូវបានបង្កើតឡើងនៅក្នុងរចនាសម្ព័ន្ធតុលាការកម្ពុជាដែលមានស្រាប់"[71] និង "ស្របតាមច្បាប់កម្ពុជា"[72] នោះ រដ្ឋធម្មនុញ្ញមានបឋមភាពទៅលើវិធានផ្ទៃក្នុង យ៉ាងសមហេតុសមផល។ ហេតុដូច្នេះ វិធាន ៣៤ នៃវិធានផ្ទៃក្នុង មិនអាចយកទៅ បកស្រាយដើម្បីរារាំងភាគីមិនឲ្យអនុវត្ត

---

[68] *សូមមើល*មាត្រា១២៨ នៃរដ្ឋធម្មនុញ្ញ ព្រះរាជាណាចក្រកម្ពុជា និងមាត្រា ១៤(១) នៃ ICCPR ដែលត្រូវបានដាក់បញ្ចូលក្នុងប្រព័ន្ធច្បាប់ប្រទេសកម្ពុជាតាមរយៈមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជា ។

[69] សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍មោឃភាពពាក់ព័ន្ធនឹង *Chea* , កថាខណ្ឌ ១៤។

[70] មាត្រា ១៥០, Article 150, រដ្ឋធម្មនុញ្ញកម្ពុជា ។

[71] *រឿងក្តី កាំង ហ្គេកអ៊ាវ ហៅ "ឌុច"*, សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ជ, សេចក្តីសម្រេចលើសំណើសុំដោះលែងឲ្យមានសេរីភាព, កថាខណ្ឌ ១០ ។

[72] *សូមមើល* បុព្វកថា វិធានផ្ទៃក្នុង ។

ដោយស្របច្បាប់នូវសិទ្ធិទទួលបាននូវការកាត់ សេចក្តីដោយយុត្តិធម៌ ដែលត្រូវបានការពារដោយរដ្ឋធម្មនុញ្ញនោះបានឡើយ។

៣៨. ទីពីរ វានឹងមិនសមហេតុសមផលទាល់តែសោះសម្រាប់វិធានផ្ទៃក្នុង ក្នុងការតម្រូវឱ្យសហចៅក្រមស៊ើបអង្កេតមានភាពអនាគតិនៅក្នុងការអនុវត្តនូវមុខងារស៊ើបអង្កេត ឬមុខងារតុលាការរបស់ខ្លួននោះ ប៉ុន្តែមិនតម្រូវឱ្យអ្នកស៊ើបអង្កេត ឬមន្ត្រីច្បាប់នៃការិយាល័យសហចៅក្រមស៊ើបអង្កេត ដែលបានដឹកនាំនូវភារកិច្ចស៊ើបអង្កេតដូចគ្នាក្នុងនាមសហចៅក្រមស៊ើបអង្កេតនោះឱ្យមានភាពអនាគតិដែរនោះ។ ការរាប់បញ្ចូលចៅក្រម ប៉ុន្តែបដិសេធអ្នកស៊ើបអង្កេតនិងមន្ត្រីច្បាប់ពីនីតិវិធីនៃការជិតចិត្តនៅក្នុងវិធាន ៣៤ នៃវិធានផ្ទៃក្នុងនោះ នឹងជាការបំពានទាំងស្រុងក្នុងករណី ដែលពួកគាត់កំពុងតែបំពេញភារកិច្ចដូចគ្នានោះ។ វិធានផ្ទៃក្នុងត្រូវតែយកទៅបកស្រាយតាមវិធី ដែលធ្វើឱ្យពួកគាត់មានភាពស៊ីសង្វាក់គ្នា។ ខណៈដែលវិធានផ្ទៃក្នុងលើកឡើងនូវកាតព្វកិច្ចនៃភាពអនាគតិចំពោះអ្នកស៊ើបអង្កេត នៃការិយាល័យសហចៅក្រមស៊ើបអង្កេត វាត្រូវតែមានវិធីអនុវត្តនូវបទបញ្ញត្តិទាំងនេះ។ ចំណុចនេះត្រូវបានពង្រឹងបន្ថែមទៀត តាមរយៈការអះអាងរបស់អង្គបុរេជំនុំជម្រះ ដែលថាវិធានផ្ទៃក្នុង "បានបង្កើតនូវប្រព័ន្ធច្បាប់នីតិវិធីដែលមានលក្ខណៈឯករាជ្យ"[73]។ ដោយសារ តែជាប្រព័ន្ធដែលមានលក្ខណៈឯករាជ្យដែលត្រូវបានបញ្ចូលទៅក្នុងសារព័ន្ធរបស់វា គេត្រូវតែសន្មតថា វិធានផ្ទៃក្នុងត្រូវបានគេជឿថាមានភាពស៊ីសង្វាក់គ្នា។

៣៩. ទីបី ការកំណត់កាតព្វកិច្ចនៃភាពអនាគតិទៅលើអ្នកស៊ើបអង្កេត ឬមន្ត្រីច្បាប់នៃការិយាល័យសហចៅក្រមស៊ើបអង្កេត ដោយគ្មានការបកស្រាយពីវិធានផ្ទៃក្នុង ក្នុងការផ្តល់នូវយន្តការអនុវត្តដ៏ម៉ឺងម៉ាត់ទេនោះ នឹងធ្វើឱ្យសិទ្ធិក្នុងការទទួលបាននូវតុលាការ ដែលមានភាពឯករាជ្យនិងមិនលម្អៀងក្លាយជាមិនពិតប្រាកដ។ សិទ្ធិនានាត្រូវតែយកទៅបកស្រាយដើម្បីធ្វើឱ្យសិទ្ធិទាំងនោះមានប្រសិទ្ធភាព[74]។

៤០. ទីបួន មានតែការបកស្រាយដ៏ទូលំទូលាយអំពីពាក្យ "ចៅក្រម" នៅក្នុងវិធាន ៣៤ នៃវិធានផ្ទៃក្នុង ដែលជាគោលដៅនៃពាក្យបណ្តឹងជិតចិត្តប៉ុណ្ណោះ នឹងឆ្លុះបញ្ចាំងអំពីកម្មវត្ថុ និងគោលបំណងនៃ

---

[73] សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍មោឃភាពពាក់ព័ន្ធនឹង *Chea* , កថាខណ្ឌ ១៤ ។

[74] *សូមមើល រឿងក្តី Artico តទល់ Italy,* ECHR, ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៨០, កថាខណ្ឌ ៣៣ ។

វិធាននេះបានយ៉ាងសមរម្យ។ កម្មវត្ថុនិងគោលបំណងនៃសន្ធិសញ្ញា អាចយកទៅធ្វើការពិចារណា ដើម្បីជួយដល់ការបកស្រាយសន្ធិសញ្ញា[75]។ មាត្រា ២(២) នៃកិច្ចព្រមព្រៀង បានចែងថា "កិច្ចព្រមព្រៀងនេះត្រូវអនុវត្តតាមអនុសញ្ញាទីក្រុងវីយ៉ែន ស្តីពីច្បាប់សន្ធិសញ្ញា ជាពិសេស មាត្រា ២៦ និង ២៧"។ វិធានផ្ទៃក្នុងត្រូវបានប្រកាសឲ្យប្រើដោយចៅក្រមនៃអង្គជំនុំជម្រះវិសាមញ្ញ មិនមែនដោយរដ្ឋសភាកម្ពុជានោះទេ ដែលហាក់ដូចជាធ្វើតាមបែបបទមួយចំនួននៃសិទ្ធិអំណាច ដែលបានកំណត់ស្របតាមកិច្ចព្រមព្រៀង។ ពុំមានមូលដ្ឋានច្បាប់ផ្សេងទៀតដើម្បីធ្វើយុត្តិកម្ម លើការប្រកាសឲ្យប្រើវិធានទាំងនេះទេ។ ដោយសារតែកិច្ចព្រមព្រៀងនេះ ត្រូវអនុវត្តតាមមាត្រា ៣១ នៃអនុសញ្ញាទីក្រុងវីយ៉ែននោះ វាមានលក្ខណៈសមហេតុសមផលទាំងស្រុង ដែលថា បទបញ្ញត្តិនេះនឹងយកទៅអនុវត្តនៅក្នុងការបកស្រាយវិធានផ្ទៃក្នុងដែលបង្កើតនូវវិសាលភាព នៃកិច្ចព្រមព្រៀង។

៤១. ដូចដែលបានកំណត់នៅក្នុងបុព្វកថា កម្មវត្ថុនិងគោលបំណងនៃវិធានផ្ទៃក្នុងគឺដើម្បីធានាថា នីតិវិធីនៅអង្គជំនុំជម្រះវិសាមញ្ញមានភាពស្របគ្នានឹងនិយាមអន្តរជាតិ ស្តីពីការកាត់សេចក្តីដោយយុត្តិធម៌។ ហេតុដូច្នេះ ដោយស្របទៅនឹងនិយាមអន្តរជាតិទាំងនេះ ក្នុងករណីមានកង្វះភាពអនាគតិរបស់អ្នកណាម្នាក់ដែលបំពេញការងារឲ្យចៅក្រម អាចត្រូវបានបង្ហាញភស្តុតាងថា មានការប៉ះពាល់ដល់ភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធី នៅក្នុងលក្ខណៈដូចគ្នានឹងកង្វះភាពអនាគតិរបស់ចៅក្រមរូបនោះ បទបញ្ញត្តិនេះត្រូវយកទៅធ្វើការបកស្រាយឲ្យបានទូលំទូលាយ ដើម្បីរួមបញ្ចូលនូវការជជែកតវ៉ាបែបនេះ នៅក្នុងក្របខ័ណ្ឌនៃបទបញ្ញត្តិនោះ។

៤២. ទីប្រាំ ដូចដែលបានលើកឡើងពីខាងដើម សិទ្ធិទទួលបាននូវការកាត់សេចក្តីដោយយុត្តិធម៌ ដែលបានកំណត់នៅក្នុងវិធាន ២១ នៃវិធានផ្ទៃក្នុង តម្រូវឲ្យអង្គបុរេជំនុំជម្រះពិនិត្យមើលថាតើ បទបញ្ញត្តិនៃវិធានផ្ទៃក្នុងគួរតែយកទៅបកស្រាយឲ្យបានទូលំទូលាយឬទេ[76]។ ទោះបីជាសេចក្តីសម្រេចនោះ

---

[75] *សូមមើល* មាត្រា ៣១(១), អនុសញ្ញាក្រុង Vienna ស្តីពីច្បាប់ និងសន្ធិសញ្ញា ឆ្នាំ១៩៦៩៖ "សន្ធិសញ្ញាមួយត្រូវបកស្រាយឲ្យត្រឹមត្រូវស្របតាមអត្ថន័យសាមញ្ញរបស់ពាក្យនៅក្នុងអនុសញ្ញានោះស្របតាមបរិបទ និងគោលបំណងរបស់ពួកវា"។

[76] *រឿងក្តី អៀង សារី,* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ក.ស.ច.ស ស្តីពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែ, ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០៨ ។

ពាក់ព័ន្ធនឹងភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍ ច្រើនជាងពាក់ព័ន្ធនឹងការជជែកតវ៉ាផ្ទាល់នៅចំពោះមុខអង្គបុរេជំនុំជម្រះក៏ដោយ ហេតុផលដូចគ្នានេះត្រូវតែអនុវត្តតាម។ បញ្ហាទាំងពីរយ៉ាងគឺទាក់ទិននឹងបញ្ហាដែលអង្គបុរេជំនុំជម្រះ ត្រូវធ្វើការបកស្រាយនូវយុត្តាធិការផ្ទាល់របស់ខ្លួន។ ដូចដែលបានពន្យល់ខាងលើ សិទ្ធិក្នុងការទទួលបាននូវតុលាការដែលមិនលម្អៀង គឺជាសមាសភាពទាំងមូលនៃការធានានូវការកាត់សេចក្តី ដោយយុត្តិធម៌។

៤៣. ដោយបានទទួលស្គាល់នូវផលប៉ះពាល់ នៃកង្វះភាពអនាគតិរបស់បុគ្គលិកតុលាការ តុលាការ ផ្សេងទៀតបានលើកឡើងថា កង្វះភាពអនាគតិរបស់មន្ត្រីច្បាប់អាចនាំឲ្យមាន ការដិតចិត្ត។ ឧទាហរណ៍នៅក្នុងរឿងក្តី *Hamid v. Price Waterhouse* គេបានយល់ឃើញថា "ទោះបីជាចៅក្រមមិនមានហេតុផល ដើម្បីសង្គ្រោះខ្លួនឯងដោយសារតែកាលៈទេសៈផ្ទាល់ខ្លួនក៏ដោយ ទំនាក់ទំនងរបស់មន្ត្រីច្បាប់អាចបណ្តាលឲ្យគេយកភាពអនាគតិនៃសេចក្តីសម្រេចពីអង្គជំនុំជម្រះរបស់ចៅក្រម ដែលមន្ត្រីច្បាប់នោះបានចូលរួម ទៅធ្វើការចោទសួរបានយ៉ាងសមស្រប"[77]។ យុត្តាធិការក្នុងប្រទេសក៏បានចែងអំពីលទ្ធភាព ដែលការជជែកតវ៉ាត្រូវធ្វើឡើងចំពោះមន្ត្រីតុលាការ ក្នុងករណីដែលភាពអនាគតិរបស់ពួកគេចោទជាបញ្ហា ឬនៅក្នុងករណីដែលភាពអនាគតិរបស់ចៅក្រមអាចត្រូវបានជជែកតវ៉ាដោយសារហេតុផលនោះ[78]។ យុត្តិសាស្ត្ររបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ ("ICC") ក៏បានណែនាំ

[77] រឿងក្តី *Hamid តទល់ Price Waterhouse* ។ សូមមើលផងដែររឿងក្តី *King តទល់ Sussex Judges, Ex Parte McCarthy* [1924] 1 KB 256, ជាពិសេសទំព័រ 257-259។ *សូមមើលផងដែររឿងក្តី Onishea តទល់នឹង Hopper,* 126 F.3d នៅទំព័រ1323, 1340 (11th Cir. 1997) ("វាជាការពិតហើយថាការពាក់ព័ន្ធរបស់ក្រឡាបញ្ជីនៅក្នុងសំណុំរឿងមួយ និងទំនាក់ទំនងរវាងភាគីមួយនៃភាគីជាច្រើនអាចបង្កើតជាមូលដ្ឋានផ្សេងៗ។

[78] ច្បាប់នីតិវិធីព្រហ្មទណ្ឌអេស្ប៉ាញបកស្រាយលើប្រធានបទ "ទាក់ទងនឹងការជំទាស់ដែលបានលើកឡើងប្រឆាំងទៅនឹងតុលាការ និងអ្នកជំនួយការសាលាក្តី" (Ley de Enjuiciamiento Criminal (ច្បាប់នីតិវិធីព្រហ្មទណ្ឌអេស្ប៉ាញ), កន្លីទី I, មាតិកាទី III, ជំពូក៤) ហើយចែងថា "ការជំទាស់អាចលើកឡើងប្រឆាំងនឹងក្រឡាបញ្ជីតុលាការក្រុង តុលាការស៊ើបអង្កេតបទឧក្រិដ្ឋ (*juzgados de instrucci€n*), តុលាការជាន់ខ្ពស់(*Audiencias*), និងតុលាការកំពូល," ហើយ "មន្ត្រីតុលាការ," ផងដែរសំអាងទៅលើមូលដ្ឋានប្រាកដច្បាស់ដែលបានរៀបរាប់ក្នុងច្បាប់រៀបចំអង្គការនៃតុលាការ (*សូមមើលយោងខាងលើ*, កន្លីទី I, មាតិកាទី III, ជំពូក I, មាត្រា៥៤ និង ជំពូក IV,មាត្រា៨៤)។ នៅប្រទេស Portugal ចៅក្រមមិនត្រូវបានគេអនុញ្ញាត្តិឲ្យប្រើប្រាស់តួនាទីរបស់ខ្លួននៅក្នុងនីតិវិធីព្រហ្មទណ្ឌទេ "នៅពេលដែលគាត់បានចូលរួមក្នុងនីតិវិធីជាតំណាងឲ្យរដ្ឋអាជ្ញាសាធារណៈ ជាតួអង្គមួយនៃមន្ត្រីនគរបាលយុត្តិធម៌ ជាមេធាវីការពារក្តី ជាស្នាក្តីនៃភាគីដែលមានសិទ្ធិដាក់ពាក្យបណ្តឹងដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន ឬដាក់ពាក្យបណ្តឹងទាមទារសំណងខូចខាត ឬ អ្នកជំនាញ" (C€digo de Processo Penal (ក្រមនីតិវិធីព្រហ្មទណ្ឌ Portuguese), កន្លីទី I, មាតិកាទីI, ជំពូក VI, មាត្រា ៣៩(១)(គ))។ ក្នុងជំពូកដដែលនៃក្រមនីតិវិធីព្រហ្មទណ្ឌ

---

មាត្រា៤៧ បានពន្លាតការរារាំងដូចគ្នានេះរហូតដល់ "អ្នកជំនាញ អ្នកបកប្រែនិងមន្ត្រីតុលាការ" និងមានចែងអំពីដំណើរការសង្ខេបស្តីពីប្តឹងជំទាស់ចិត្តមន្ត្រីទាំងនេះ។ *ក្នុងចំណោម* ទម្រង់ដដែលនេះ នៃការប្តឹងជំទាស់ចិត្តមន្ត្រីតុលាការដោយសំអាងលើមូលដ្ឋានដូចគ្នាចំពោះចៅក្រមផ្ទាល់ ត្រូវបានគេអនុម័ត នៅក្នុងក្រមព្រហ្មទណ្ឌនៃយុត្តាធិការក្នុង South America (រួមទាំង Argentina, Brazil, Paraguay, Colombia, and Bolivia) (Central America (រួមទាំង Costa Rica) ។ Código Procesal Penal (ក្រមនីតិព្រហ្មទណ្ឌ Argentine), កន្តីទីI មាតិកាទីIII ជំពូក៤ (ចំណងជើងថា "ការប្តឹងជំទាស់ចិត្ត និងការទំទាស់") មាត្រា៥៥(១) មាត្រ ៦៣ នៃជំពូកដដែលនេះចែងថា "ក្រឡាបញ្ជី និងអ្នកជំនួយការត្រូវដកខ្លួនចេញដោយខ្លួនឯង និងអាចត្រូវប្តឹងជំទាស់ដោយសំអាងលើមូលដ្ឋានដែលបានចែងក្នុងមាត្រា៥៥...." នៅប្រទេស Brazil ចៅក្រម "អាចមិនមានសិទ្ធិអនុវត្តនូវយុត្តាធិការ" ក្នុងដំណើការនីតិវិធីរឿងក្តីដែលគាត់ឬនាង ឬ ប្តីប្រពន្ធរបស់គាត់ឬនាង ឬ សាច់ញាត្តិរបស់គាត់ឬនាង "បានធ្វើជាតំណាងមេធាវីការពារ ឬ ជាមេធាវី ជាតំណាងផ្នែកផ្តល់ជំនួយរដ្ឋអាជ្ញាសាធារណៈ អាជ្ញាធរនគបាល មន្ត្រីតុលាការ ឬ សាក្សីជំនាញ" *សូមមើល* Código de Processo Penal (ក្រមនីតិវិធីព្រហ្មទណ្ឌ Brazil) កន្តីទីI មាតិកាទីVIII ជំពូកI ( ចំណងជើងថា "វិសមិតភាព និង បណ្តឹងជំទាស់ចិត្ត") មាត្រា២៥២ I & II។ មាត្រាដោយឡែកក្នុងជំពូកV ចែងថា "បទបញ្ញត្តិស្តីពីការសុំដកខ្លួនរបស់ចៅក្រម ត្រូវអនុវត្តចំពោះក្រឡាបញ្ជីនិងមន្ត្រីតុលាការ ទាក់ទងនឹងបញ្ហានេះ"។ *សូមមើលយោងខាងលើ* មាត្រា ២៧៤។ នៅប្រទេស Paraguay ច្បាប់ចែងថា ចៅក្រមគួរត្រូវបានគេលើកលែងទោស ប្រសិនបើពីមុនខ្លួនធ្លាប់បានចូលអន្តរាគមន៍នៅក្នុងដំណើការនីតិវិធីរឿងក្តី "ជាភាគីមួយ ជាអ្នកតំណាងផ្នែកច្បាប់ ជាអ្នកតំណាង ជាមេធាវីការពារក្តី ជាអ្នកជំនាញ ឬជាសាក្សី" គឺត្រូវអនុវត្តស្មើភាពគ្នាចំពោះ "ក្រឡាបញ្ជី និងអ្នកណាដែលផ្តល់ជាជំនួយផ្នែកតុលាការក្នុងនីតិវិធីរឿងក្តី" *សូមមើល* Código Procesal Penal (ក្រមនីតិវិធីព្រហ្មណ្ឌ Paraguay), កន្តីទីមួយ មាតិកាI ជំពូកIV (មានចំណងជើងថា "មូលដ្ឋានសំរាប់ការប្តឹងជំទាស់ចិត្ត និងការប្តឹងជំទាស់") មាត្រា ៥0(៨) & ៥១។ ប្រទេស Colombia និងប្រទេស Bolivia មានជាពិសេសខ មានចែងក្រមបទប្បញ្ញត្តិដូចគ្នា។ *សូមមើល* Código de Procedimiento Penal (ក្រមនីតិវិធីព្រហ្មទណ្ឌ Colombia) កន្តីទីI មាតិកាទីI ជំពូក៧ មាត្រា ៥៦(១២) & ៦៣ ។ Código de Procedimiento Penal (ក្រមនីតិវិធីព្រហ្មទណ្ឌBolivian), ផ្នែកII, កន្តីទីI, មាតិកាទីI, ជំពូក៥, មាត្រា៣១៦ (១) & ៣២២។ ក្រមនីតិវិធីព្រហ្មទណ្ឌ Costa Rica, *សូមមើល* Código Procesal Penal (ក្រមនីតិវិធីព្រហ្មទណ្ឌ), កន្តីទីI, មាតិកាទីI, ជំពូក២ (មានចំណងជើងថា "ការប្តឹងជំទាស់ចិត្ត និងការប្តឹងជំទាស់") មាត្រា៥៥(១)(ក) និង៦០ (មាត្រា៥៥ (១)(ក) តំរូវឲ្យមានការដកខ្លួនចេញពីសវនាការរឿងក្តីប្រសិនបើ "ឋិតនៅក្នុងទិសដៅនីតិវិធីរឿងក្តីដូចគ្នា" ចៅក្រម "បានពាក់ពន្ធ័ជាមន្ត្រីការិយាល័យរដ្ឋបាលសាធារណៈ ជាអ្នកតំណាងផ្នែកច្បាប់ ជាអ្នកចោទប្រកាន់ (*denunciante*) ជាដើមចោទ (*querellente*)," និងមាត្រា ៦០ អនុវត្តវិធានដដែលនេះចំពោះ "ក្រឡាបញ្ជី និងបុគ្គលណាដែលផ្តល់ជាជំនួយខាងផ្នែកតុលាការក្នុងតំណើរការនីតិវិធីនានា")។ ក្រមនីតិវិធីព្រហ្មទណ្ឌ Romanian មានជារួមមូលដ្ឋានប្រហាក់ប្រហែលសម្រាប់ការប្តឹងជំទាស់ចិត្តចៅក្រម ឋិតក្រោមផ្នែកដែលមានចំណងជើងថា "វិសមិតភាព" ។ ចៅក្រម " មានវិសមិតភាពក្នុងការជនុំជម្រះ" ប្រសិនបើក្នុងចំណោមចៅក្រមផ្សេងទៀត គាត់ "មានការជាប់ពាក់ព័ន្ធនឹងការចោទប្រកាន់ពីបទព្រហ្មទណ្ឌ ឬបាន ឬក៏បានធ្វើការគ្រប់គ្រងលើការចោទប្រកាន់នេះ..."។ ក្នុងមាត្រា ៤៩(១) មូលដ្ឋានសំអាងទាំងនេះរួមបញ្ចូលទាំងរដ្ឋអាជ្ញា ជំនួយការចៅក្រមនិង ក្រឡាបញ្ជីតាមផ្នែក ។ *សូមមើល* Codul de Procedura Penala (ក្រមនីតិវិធីព្រហ្មទណ្ឌ Romanian), ផ្នែកទីI មាតិកាទីII ជំពូកII,មាត្រា ៤៨(១)(e) & ៤៩(១) ។

ផងដែរថា សំណើសុំ ជិតចិត្តបុគ្គលិកច្បាប់ត្រូវតែធ្វើការសម្រេចស្រប តាមបទបញ្ញត្តិច្បាប់ដែលពាក់ព័ន្ធនឹងការជិតចិត្តចៅក្រម[79]។

**គ. អ្នកស៊ើបអង្កេត Heder មិនមានភាពអនាគតិ និងត្រូវតែដកហូតសិទ្ធិ**

៤៤. អ្នកស៊ើបអង្កេត Heder ត្រូវបានជ្រើសរើសដោយ UNAKRT កាលពីខែកក្កដា ឆ្នាំ២០០៦។ ទោះបីជា ក.ស.ច.ស តវ៉ាថា Heder ត្រូវបានចាត់តាំងទៅបំរើការឱ្យសហ ចៅក្រមស៊ើបអង្កេតរួចហើយ "ផ្តាច់ចេញពីការិយាល័យសហព្រះរាជអាជ្ញា"[80] ក៏ដោយ ផលប៉ះពាល់ផ្លូវច្បាប់នៃការផ្តាច់ចេញនេះបានកើតមានឡើងយ៉ាងពិតប្រាកដ។ អ្នកស៊ើប អង្កេត Heder ត្រូវបានជួលឱ្យបំរើការងារសម្រាប់រយៈពេល៦ខែ គិតចាប់ពីខែកក្កដា ដល់ខែធ្នូ ឆ្នាំ២០០៦ នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតួនាទីជាអ្នកស៊ើបអង្កេត នៃការិយាល័យសហព្រះរាជអាជ្ញា។ នៅពេលនោះ ទោះបីជាវិធានផ្ទៃក្នុងមិនទាន់បានអនុម័តក៏ដោយ ការិយាល័យសហព្រះរាជអាជ្ញាបាននឹងកំពុងដឹកនាំ "ការស៊ើបអង្កេត បឋមរបស់ខ្លួនដើម្បីកំណត់ថាតើភស្តុតាងបង្ហាញថា ឧក្រិដ្ឋកម្មនានានៅក្នុងយុត្តាធិការ នៃអង្គជំនុំជម្រះវិសាមញ្ញត្រូវបានប្រព្រឹត្តមែនដែរឬទេ និងដើម្បីកំណត់អត្តសញ្ញាណ ជនសង្ស័យព្រមទាំងសាក្សីដែលអាចមានផងដែរ"[81]។

---

[79] *សូមមើលរឿងក្តីរដ្ឋអាជ្ញា តទល់ Thomas Lubanga Dyilo*, ICC-01/04-01/06, សេចក្តីសម្រេចលើបណ្តឹងរដ្ឋអាជ្ញាក្នុងការផ្តាច់ទីប្រឹក្សាផ្នែកច្បាប់ជាន់ខ្ពស់ក្នុងអង្គបុរេចេញពីការផ្តល់ប្រឹក្សាផ្នែកច្បាប់ទាក់ទិននិងសំណុំរឿង ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៦។ អង្គជនុំជម្រះពិចារណាថា បណ្តឹងរបស់រដ្ឋអាជ្ញា ក្នុងការរារាំងមន្ត្រីផ្នែកច្បាប់ជាន់ខ្ពស់មិនឱ្យធ្វើការផ្តល់យោបល់ក្នុងរឿងក្តី *Lubanga* "អាចដូចគ្នានឹងបណ្តឹងជិតចិត្តចៅក្រម ឬ យ៉ាងហោចណាស់ អាចលើកជាបញ្ហាពាក់ពន្ធ័ទៅនឹងបណ្តឹងជិតចិត្តចៅក្រម ដែលមានចែងក្នុងមាត្រា៤១(២) នៃច្បាប់" ទំព័រ២ ។ ជាវិបាក សំណើនេះ ត្រូវបានយោងទៅលើកិច្ចប្រជុំពេញអង្គរបស់ជុំចៅក្រមក្នុងមាត្រា៤១(២)(គ) ។ វាសំខាន់ណាស់ក្នុងការកត់សំគាល់ថា សំណើរបស់រដ្ឋអាជ្ញាសុំឱ្យមានការផ្តាច់ឬការប្តឹងជិតចិត្ត របស់មន្ត្រីច្បាប់ជាន់ខ្ពស់ ហើយមិនមែនជាចៅក្រម ហើយតុលាការព្រហ្មទណ្ឌអន្តរជាតិ ICC អនុវត្តតាមនីតិវិធី ដែលកំណត់ឡើងសំរាប់ការប្តឹងជិតចិត្តចៅក្រម។ ការយោងក្នុងមាត្រា៤១ គឺសម្រាប់តែចៅក្រមប៉ុណ្ណោះ។

[80] *សូមមើល* សេចក្តីសម្រេចទី១ពាក់ព័ន្ធនិង Heder ។

[81] វិធាន៥០ (១)។ វិធានផ្ទៃក្នុង ពុំត្រូវបានគេអនុម័តរហូតដល់ថ្ងៃទី ១២ ខែមិថុនា ឆ្នាំ២០០៧ ។ ទោះជាយ៉ាងណាក៏ដោយ សូម្បីតែមុនកាលបរិច្ឆេទនេះ វាច្បាស់ថា ដោយសា អ.វ.ត.ក គឺជាតុលាការក្នុងស្រុក ហើយនឹងអនុវត្តតាមច្បាប់កម្ពុជា សហព្រះរាជអាជ្ញានឹងទទួលខុសត្រូវចំពោះការផ្តួចផ្តើមការស៊ើបអង្កេតតាមផ្លូវតុលាការ។ សហព្រះរាជអាជ្ញាក៏បានទទួលផលប្រយោជន៍ពីពង្រាងវិធានផ្ទៃក្នុងដែលចេញផ្សាយនៅថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០០៦ ផងដែរ។

៤៥. គោលដៅច្បាស់លាស់ សម្រាប់ការស៊ើបអង្កេតបឋមរបស់ការិយាល័យសហព្រះរាជ អាជ្ញាដែលដឹកនាំដោយ Heder នឹងជាអ្នកទាំងឡាយណាដែលមានឈ្មោះនៅក្នុងសៀវភៅ របស់អ្នកស៊ើបអង្កេត Heder ដែលមានចំណងជើងថា "បេក្ខជនចំនួនប្រាំពីរនាក់: សម្រាប់ការដាក់ឱ្យទទួលខុសត្រូវចំពោះការប្រព្រឹត្តិបទឧក្រិដ្ឋ ក្នុងរបបខ្មែរក្រហម"[82]។ នៅក្នុងសៀវភៅនេះ អ្នកស៊ើបអង្កេត Heder បានដាក់ឈ្មោះមនុស្សចំនួនប្រាំពីរនាក់ រួមមានលោក អៀង សារី ដែលគាត់ជឿថា គួរតែប្រឈមមុខនឹង "ការចោទប្រកាន់" ចំពោះបទឧក្រិដ្ឋរបស់ខ្លួន។ ជាពិសេស អ្នកស៊ើបអង្កេត Heder អះអាងថា លោក អៀង សារី:

- "បានតស៊ូមតិពិតប្រាកដណាស់ ឬបានការពារ បន្ទាប់ពីមានគោលនយោបាយ ប្រហារជីវិតរបស់បក្ស"[83]
- "បានចូលរួមចំណែកដោយបានដឹងដោយផ្ទាល់និងយ៉ាងសំខាន់ ក្នុងនាមជាអ្នក ជួយ និងជាអ្នកជម្រុញឱ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្មនៅទូទាំងប្រទេស"[84]
- "បានជួយសម្រួលឬខកខានមិនបានរារាំងនូវការចាប់ខ្លួនយ៉ាងរាលដាល និងការបញ្ជូនខ្លួនទៅមន្ទីរ ស-២១"[85]
- "បានដឹងអំពីការចាប់ខ្លួននិងការសារភាពរបស់កម្មាភិបាល នៅក្នុងក្រសួងរបស់ គាត់ ព្រមទាំងខកខានមិនបានធ្វើអន្តរាគមរារាំងសកម្មភាពទាំងនេះ"[86]។

៤៦. នៅពេលដែលសិទ្ធិរបស់ អ្នកស៊ើបអង្កេត Heder ក្នុងការធ្វើការទាមទារទាំងនេះ ក្នុងនាមជាប្រជាពលរដ្ឋឯកជនមួយរូបមិនត្រូវបានគេតវ៉ាទេនោះ ស្ថានភាពនេះមានភាពខុសប្លែកគ្នាស្រឡះ នៅពេលដែលគាត់ផ្លាស់ប្តូរទៅជាអ្នកស៊ើបអង្កេតនៃការិយាល័យសហព្រះរាជអាជ្ញា ដែលបានអះអាងថាមានភាពអនាគតិនោះ។ នៅក្នុងការដឹកនាំកិច្ចស៊ើបសួរបឋម អ្នកស៊ើបអង្កេតនៃការិយាល័យសហព្រះរាជអាជ្ញា ត្រូវបានតម្រូវឱ្យកំណត់ "ថាតើភស្តុតាងបង្ហាញថា ឧក្រិដ្ឋកម្ម

---

[82] STEPHEN HEDER AND BRIAN TITTMORE, SEVEN CANDIDATES FOR PROSECUTION: ការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនៃរបបខ្មែរក្រហម (២០០៤) ("SEVEN CANDIDATES") ។

[83] *ដូចយោងខាងលើ* ទំព័រ៩០ ។

[84] *ដូចយោងខាងលើ* ។

[85] *ដូចយោងខាងលើ* ។

[86] *ដូចយោងខាងលើ* ទំព័រ៩២ ។

00348473



នានានៅក្នុងយុត្តាធិការនៃអង្គជំនុំជម្រះ វិសាមញ្ញត្រូវបានប្រព្រឹត្តមែនដែរឬទេ និងដើម្បីកំណត់អត្តសញ្ញាណជនសង្ស័យព្រម ទាំងសាក្សីដែលអាចមានផងដែរ"[87]។ ដើម្បីអនុវត្តនូវភារកិច្ចនេះ អ្នកស៊ើបអង្កេតនៃ ការិយាល័យសហព្រះរាជអាជ្ញា ត្រូវតែដឹកនាំការស៊ើបអង្កេតបឋមរបស់ខ្លួនប្រកបដោយភាពអនាគតិ។ ពួកគាត់មិនត្រូវធ្វើការវិនិច្ឆ័យជាមុនអំពីឧក្រិដ្ឋកម្មនានា ដែលពួកគាត់ជឿថាបានកើតមានឡើង ឬក៏អំពីអ្នកណាដែលពួកគាត់ជឿថាត្រូវទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទាំងនោះទេ។

៤៧. សារៈសំខាន់នៃភាពអនាគតិនេះ បានលេចធ្លោឡើងតាមរយៈផលប៉ះពាល់ទៅលើសេរីភាពរបស់ជនដែលមានឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរផង និងទៅលើទំហំនៃអង្គហេតុដែលត្រូវបានកំណត់នៅក្នុងដីកានោះផង។ នៅពេលដែលជនសង្ស័យត្រូវបានកំណត់ឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ដែលបានដាក់ជូនទៅការិយាល័យសហចៅក្រមស៊ើបអង្កេតភ្លាមនោះ ជនជាប់សង្ស័យត្រូវទទួលខុសត្រូវក្នុងការបើកកិច្ចស៊ើបសួរដោយការិយាល័យសហចៅក្រមស៊ើបអង្កេត[88] រួចហើយត្រូវបានឃុំខ្លួនបណ្តោះអាសន្ន[89]។ ក.ស.ច.ស "អាចបើកកិច្ចស៊ើបសួរចំពោះ បុគ្គលផ្សេងទៀតដែលមិនមានឈ្មោះក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ[90]។ សេចក្តីសម្រេចអំពីការឃុំខ្លួនជនត្រូវចោទជាបណ្តោះអាសន្ន ត្រូវធ្វើដោយការិយាល័យសហចៅក្រមស៊ើបអង្កេត មិនមែនដោយការិយាល័យសហព្រះរាជអាជ្ញានោះទេ។ ទោះបីជាយ៉ាងណាក៏ដោយ ការកំណត់របស់ ក.ស.ច.ស ថាតើ "មានមូលហេតុ ដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ថា ជននោះធ្លាប់បានប្រព្រឹត្តបទល្មើសមួយឬច្រើន ដូចមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម"[91] នឹងត្រូវបានគេសំអាងលើភស្តុតាងដែលបានដាក់ដោយការិយាល័យសហព្រះរាជអាជ្ញា ដើម្បីគាំទ្រដល់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរយ៉ាងពិតប្រាកដ និងយ៉ាងទូលំទូលាយ បើមិនទាំងស្រុងទេនោះ។

---

[87] វិធាន៥០(១) ។

[88] វិធាន៥៥ (៤) ។

[89] វិធាន៦៣ (១)(ក) ។

[90] ខាងលើ ។

[91] វិធាន៦៣ (៣)(a) ។

៤៨. លើសពីនេះទៀត វិសាលភាពនៃការស៊ើបអង្កេតរបស់ ក.ស.ច.ស ត្រូវបានកម្រិតឱ្យ ធ្វើការស៊ើបអង្កេតលើអង្គហេតុ ដែលបានកំណត់ដោយការិយាល័យសហព្រះរាជអាជ្ញា ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម[92]។ ហេតុដូច្នេះ ការិយាល័យសហព្រះរាជអាជ្ញាមានការត្រួតពិនិត្យដែលគ្របដណ្តប់ទៅលើការណែនាំ ហើយនិងគោលដៅពិតប្រាកដនៃការស៊ើបអង្កេតរបស់ ក.ស.ច.ស។ នៅពេលដែលបញ្ហាទាំងនេះអាចជោគជ័យឬបរាជ័យនោះ វាសំខាន់ណាស់ ដែលការិយាល័យសហព្រះរាជអាជ្ញាត្រូវតែមានភាពអនាគតិឱ្យបានពេញលេញ នៅក្នុងការអនុវត្តការស៊ើបអង្កេតបឋមរបស់ខ្លួន។ គេបានលើកឡើងដាច់ដោយឡែកថា អ្នកស៊ើបអង្កេត Heder មិនធ្វើបានដល់និយាមនៃភាពអនាគតិដែលបានតម្រូវនេះ នៅក្នុងការតាក់តែងសេចក្តីព្រាងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ នៅក្នុងការិយាល័យសហព្រះរាជអាជ្ញានោះទេ។

៤៩. សារៈសំខាន់នៃភាពអនាគតិនៅក្នុងចំណោមអ្នកស៊ើបអង្កេត នៃការិយាល័យសហព្រះរាជ អាជ្ញាត្រូវបានធ្វើឱ្យលេចធ្លោឡើងតាមរយៈហេតុការណ៍ដែលធនធានស៊ើបអង្កេត ដែលសមស្របចំពោះការិយាល័យសហព្រះរាជអាជ្ញាដែលបង្ហាញឱ្យឃើញថា ត្រូវបានកម្រិតយ៉ាងម៉ឹងម៉ាត់នៅពេលដែលអ្នកស៊ើបអង្កេត Heder ត្រូវបានជួលឱ្យធ្វើការងារនៅក្នុងការិយាល័យនោះ។ អ្នកស៊ើបអង្កេត Heder និយាយភាសាខ្មែរបានយ៉ាងស្ទាត់ជំនាញ[93] ហើយក៏ជានាយករងនៃផ្នែក ព័ត៌មាន/អប់រំ អាជ្ញាធរបណ្តោះអាសន្ននៃអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា UNTAC នៅឆ្នាំ១៩៩៣ មុនពេលចូលរួមនៅ ក.ស.ច.ស/ក.ស.ព[94]។ ផ្អែកតាមជំនាញផ្នែកភាសារបស់គាត់ និងបទពិសោធន៍នៅក្នុងប្រទេសកម្ពុជា វាជាឡូស៊ិក និងសមហេតុផលដើម្បីសន្និដ្ឋានថា អ្នកស៊ើបអង្កេត Heder បានដើរតួនាទីលើសលុប នៅក្នុងការសម្រេចអំពីភាពគោលដៅនៃការស៊ើបអង្កេតបឋមរបស់ ក.ស.ព ដែលជាគោលដៅដែលគាត់បានធ្វើការជ្រើសរើស មុនរួចទៅហើយ។

---

[92] វិធាន៥៥(២) ។

[93] SEVEN CANDIDATES, សេចក្តីផ្តើម ទំព័រ IX ។

[94] *សូមមើល* អាជ្ញាធរអន្តរកាល របស់អង្គការសហប្រជាជាតិ នៅប្រទេសកម្ពុជា (UNTAC), ច្បាប់បោះឆ្នោតកម្ពុជា ១៩៩២-១៩៩៣, Dr. Stephen Heder, អ្នកប្រមូល ។

00348475



៥០. បន្ទាប់ពីការចូលរួមនៅក្នុងការធ្វើសេចក្តីព្រាងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរសម្រាប់ក.ស.ព របស់គាត់មក អ្នកស៊ើបអង្កេត Heder បានបន្តការងារដោយផ្ទេរទៅ ក.ស.ច.ស ប្រហែលជានៅក្នុងខែធ្នូ ឆ្នាំ២០០៦[95]។ នៅខែកក្កដា ឆ្នាំ២០០៧ បន្ទាប់ពីមានការអនុម័ត វិធានផ្ទៃក្នុង ក.ស.ព បានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរជូនទៅ ក.ស.ច.ស។ ក្នុងនាមជាអ្នកស៊ើបអង្កេតនៃ ក.ស.ច.ស នៅពេលនោះ អ្នកស៊ើបអង្កេត Heder បាន ទទួលខុសត្រូវធ្វើ "កិច្ចស៊ើបសួរដែលនាំទៅរកការបង្ហាញនូវការពិត"[96] ពាក់ព័ន្ធនឹងអង្គហេតុដែលបានកំណត់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ នៅក្នុងការតាម រកនូវការពិតនេះ ក.ស.ច.ស ត្រូវ "ដឹកនាំកិច្ចស៊ើបសួរដោយភាពអនាគតិ ទោះបីជាភស្តុតាងដែលនឹងរកបាននោះជាភស្តុតាងដាក់បន្ទុក ឬភស្តុតាងដោះបន្ទុកក៏ដោយ"[97]។ ហេតុដូច្នេះ អ្នកស៊ើបអង្កេត Heder នាពេលនេះ កំពុងទទួលខុសត្រូវលើការស៊ើបអង្កេត លើការចោទប្រកាន់ដែលគាត់បានធ្វើសេចក្តីព្រាង ខណៈពេលដែលគាត់បំពេញការងារឱ្យ ក.ស.ព។ បញ្ហានេះបានធ្វើឱ្យអ្នកស៊ើបអង្កេត Heder ស្ថិត នៅក្នុងទំនាស់ផលប្រយោជន៍ដែលមិនអាចទទួលយកបាន។ នៅក្នុងការដឹកនាំការស៊ើបអង្កេតសម្រាប់ ក.ស.ច.ស Heder នឹងមានហេតុផលច្បាស់លាស់ក្នុងការរកឃើញ និងក្នុងការធ្វើអទិភាពនូវការកើន ឡើងនូវភស្តុតាងដាក់បន្ទុក ដើម្បីគាំទ្រដល់ការស៊ើបអង្កេតបឋមរបស់គាត់ខណៈពេល គាត់ធ្វើការងារជាមួយ ក.ស.ព។ វាក៏បានរំលោភបំពានដោយផ្ទាល់ចំពោះការបញ្ជាក់អំពីសិទ្ធិរបស់ជនត្រូវចោទដែលថា "កិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះវិសាមញ្ញ ត្រូវតែភាពត្រឹមត្រូវនិងមានការជជែកតទល់គ្នាព្រមទាំង [...] ត្រូវធានានូវ<u>ការបែងចែក</u> រវាងសិទ្ធិអំណាច ទាំងឡាយណាដែលទទួលខុសត្រូវចំពោះការចោទប្រកាន់ និងសិទ្ធិអំណាចទាំងឡាយណាដែលទទួលខុសត្រូវចំពោះការវិនិច្ឆ័យទោស"[98]។

៥១. ទោះបីជាយ៉ាងណាក៏ដោយ យោងតាម ក.ស.ច.ស:

> "នេះមិនមែនជាលក្ខខណ្ឌដែលមិនធម្មតានោះទេ។ ជាការពិត យោងតាមមាត្រាដែលពាក់ព័ន្ធនានានៃវិធានផ្ទៃក្នុង (វិធាន ១៣(៤), ១៤(៥), ១៥, ១៦, ៥០(២), ៥៥(៩) និង ៦២) អ្នកស៊ើប

---

[95] *សូមមើល* សេចក្តីសម្រេចលើកទីមួយពាក់ព័ន្ធនឹង Heder។

[96] វិធាន៥៥ (៥)។

[97] វិធាន៥៥ (៥)។

[98] វិធាន២១ (១)(a)។

អង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញ អាចត្រូវបានធ្វើការប្រៀបធៀបជាមួយនឹងមន្ត្រីនគរបាលយុត្តិធម៌: ក្រៅពីវិធានការបង្គាប់បញ្ជាដែលត្រូវទទួលខុសត្រូវ ដោយមន្ត្រីនគរបាលយុត្តិធម៌តែឯងនោះ ពួកគេទទួលរងនូវដំណើរការទទួលស្គាល់ ដែលអាចប្រៀបធៀបគ្នាបាន ហើយពួកគេមានការកំណត់តួនាទីដូចគ្នានៅក្នុងការស៊ើបអង្កេតបឋម និងនៅក្នុងពេលស៊ើបអង្កេត។ ការអនុវត្តតួនាទីទាំងនេះត្រូវបានត្រួតពិនិត្យ ដោយមន្ត្រីតុលាការដែលពាក់ព័ន្ធ។

បទបញ្ញត្តិនៃវិធានផ្ទៃក្នុងទាំងនេះត្រូវបានដកចេញមកពីច្បាប់កម្ពុជា ត្រង់ចំណុចដែលនគរបាលយុត្តិធម៌ធ្វើការងារនៅក្រោមសិទ្ធិអំណាចរបស់ព្រះរាជអាជ្ញា នៅក្នុងពេលស៊ើបអង្កេតបឋម និងនៅក្រោមសិទ្ធិអំណាចរបស់ចៅក្រមស៊ើបអង្កេត នៅក្នុងដំណាក់កាលស៊ើបអង្កេតរបស់តុលាការ (សូមមើលមាត្រា ៣៧(១) នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា)។

នេះជាការអនុវត្តធម្មតានៅគ្រប់ប្រទេសទាំងអស់ ដោយអនុវត្តនូវប្រព័ន្ធនីតិវិធីប្រៀបធៀប [ទៅនឹង] ការអនុវត្តរបស់ប្រទេសកម្ពុជា (ដូចជា សូមមើល មាត្រា ១៤, ៧៥ និង ១៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌបារាំង។ មាត្រា ៩ និង ៥៦ នៃក្រមស៊ើបអង្កេតព្រហ្មទណ្ឌ បែលហ្ស៊ិក ជាដើម...)។ លើសពីនេះទៀត ច្បាប់ យុត្តិសាស្ត្រដែលពាក់ព័ន្ធបានរំលឹកថា វិធានដែលចែងអំពីភាពអនាគតិនៃមុខងារដែល មានគោលបំណងធានាភាពឯករាជ្យនិងភាពអនាគតិរបស់តុលាការ អនុវត្តតែចំពោះចៅក្រមប៉ុណ្ណោះ មិនអនុវត្តចំពោះអ្នកស៊ើបអង្កេតនោះទេ”[99]។

៥២. ការធ្វើយុត្តិកម្មជាក់ស្តែងរបស់ ក.ស.ច.ស ដើម្បីអនុញ្ញាតិឲ្យអ្នកស៊ើបអង្កេត Heder ផ្ទេរការងារពី ក.ស.ព ទៅ ក.ស.ច.ស នេះ ខណៈដែលប្រាកដជាមានលក្ខណៈងាយស្រួលសម្រាប់ ក.ស.ច.ស មិនធ្វើឲ្យមានការពិនិត្យពិច័យខ្លាំងក្លានោះទេ។ វាអាស្រ័យទៅលើការមើលខុសទៅលើបទបញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌដែលយកមកអនុវត្តនោះផង និងអាស្រ័យទៅលើការខកខានមិនបានយល់អំពីទំនាក់ទំនងរវាងបទបញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ និងវិធានផ្ទៃក្នុងផងដូចដែលបានសរសេរដោយអង្គបុរេជំនុំជម្រះដូច្នោះដែរ។

៥៣. បទបញ្ញត្តិនៃវិធានផ្ទៃក្នុងមួយចំនួន ពិតជាធ្វើឲ្យនគរបាលយុត្តិធម៌ដូចគ្នានឹងអ្នកស៊ើបអង្កេត នៃអង្គជំនុំជម្រះវិសាមញ្ញខ្លាំងណាស់ លើកលែងតែពាក់ព័ន្ធនឹងវិធានការបង្គាប់ បញ្ជាដែលមានតែអ្នក

---

[99] សេចក្តីសម្រេចលើកទីមួយពាក់ព័ន្ធនឹង Heder ទំព័រ២។

បង្កើតឡើងតែប៉ុណ្ណោះដែលអាចអនុវត្តបាន។ បទបញ្ញត្តិទាំងនេះ ក៏បានអនុញ្ញាត ឲ្យទាំង ក.ស.ព ទាំង ក.ស.ច.ស ផ្ទេរសិទ្ធក្នុងការស៊ើបអង្កេតបឋម ឬស៊ើបអង្កេតរបស់តុលាការដល់អ្នកស៊ើបអង្កេតទាំងពីររបស់អង្គជំនុំជម្រះវិសាមញ្ញ ព្រមទាំងនគរបាលយុត្តិធម៌។ ទោះបីជាយ៉ាងណាក៏ដោយ បទបញ្ញត្តិនេះត្រូវតែគិតដល់វិធាន ២១(១)(ក) នៃវិធានផ្ទៃក្នុង ដែលផ្ដល់សិទ្ធិអំណាចក្នុងការបែងចែកដាច់ពីគ្នារវាងអាជ្ញាធរដែលទទួលបន្ទុកចោទប្រកាន់ និងអាជ្ញាធរដែលទទួលបន្ទុកវិនិច្ឆ័យទោស។ នៅពេលដែលមន្ត្រីនគរបាលយុត្តិធម៌បំពេញភារកិច្ចសម្រាប់ចៅក្រមស៊ើបអង្កេតផង សម្រាប់សហព្រះរាជអាជ្ញាផង មន្ត្រីនគរបាលយុត្តិធម៌ដដែលនោះមិនអាចធ្វើកិច្ចការទាំងពីរនោះបានទេ។ ជាលទ្ធផល គួរតែមានការបែងចែកគ្នាទាំងស្រុងរវាងនគរបាលយុត្តិធម៌ ទាំងពីរដែលធ្វើការងារសម្រាប់អាជ្ញាធរទទួលបន្ទុកធ្វើការចោទប្រកាន់ និងធ្វើការងារសម្រាប់អាជ្ញាធរទទួលបន្ទុកធ្វើការវិនិច្ឆ័យទោសឲ្យបានដាច់ដោយឡែកពីគ្នា ដើម្បីធានាដល់ភាពអនាគតិរបស់នគរបាលយុត្តិធម៌ទាំងពីរនោះ។ ការសំអាងរបស់ ក.ស.ច.ស ទៅលើបទបញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលអះអាងថាអនុញ្ញាតឲ្យមន្ត្រីនគរបាលយុត្តិធម៌ដដែលធ្វើការអង្កេតនិងធ្វើការវិនិច្ឆ័យទៅលើករណីតែមួយនោះ ត្រូវបានបរាជ័យ តាមរយៈការធានានៅក្នុងវិធាន ២១(១)(ក) អាស្រ័យដោយឋានៈខ្ពស់ជាង នៃវិធានផ្ទៃក្នុងទៅលើក្រមនីតិវិធីព្រហ្មទណ្ឌ[100]។

៥៤. ក.ស.ច.ស បានលើកឡើងយ៉ាងខ្លាំងក្លាថា សូម្បីតែប្រព័ន្ធយុត្តិធម៌បារាំងក៏មាន “វិធាន ដែលចែងអំពីភាពអនាគតិនៃមុខងារដែលមានគោលបំណងធានាឯករាជ្យភាព និងភាព អនាគតិរបស់តុលាការ”[101] ដែរ។ ជាអកុសលដោយគ្មានការបកស្រាយគាំទ្រណាមួយនោះ ក.ស.ច.ស តវ៉ាថាវិធានទាំងនេះ “អនុវត្តបានតែចំពោះចៅក្រមប៉ុណ្ណោះមិនអនុវត្តចំពោះអ្នកស៊ើបអង្កេតនោះទេ”[102]។ ដោយមិនបានផ្ដល់នូវការពន្យល់ណាមួយពី ក.ស.ច.ស ពាក់ព័ន្ធនឹងវិធានណាមួយដែលបានសំអាងដើម្បីញែកចៅក្រមចេញពីបុគ្គលិកសាមញ្ញរបស់ខ្លួននោះ វាមិនអាចបញ្ជាក់អំពីការអះអាងរបស់ ក.ស.ច.ស បានទេ។ ទោះបីជាយ៉ាងណាក៏ដោយ ដូចដែលបានឃើញនូវបទបញ្ញត្តិដ៏ទូលំទូលាយដែលត្រូវបានសំអាងខាងលើ[103] ការបែងចែងរវាងចៅក្រមនិងមន្ត្រីតុលាការរបស់ចៅក្រមខ្លួននេះ

---

[100] សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍មោឃភាពពាក់ព័ន្ធនឹង *Chea* , កថាខណ្ឌ ១៤ ។

[101] សេចក្ដីសម្រេចលើកទីមួយពាក់ព័ន្ធនឹង Heder ។

[102] *ដូចយោងខាងលើ* ។

[103] *សូមមើល* កថាខ័ណ្ឌ៤០ *ខាងក្រោម* ។

មិនកើតមានឡើងនៅក្នុងប្រព័ន្ធច្បាប់ផ្សេងទៀត ជាច្រើនដែលមានការអភិវឌ្ឍនោះទេ។ ប្រព័ន្ធទាំងនេះបង្ហាញឱ្យឃើញនូវការឯកភាពថា នៅពេលដែលមន្ត្រីនគរបាលយុត្តិធម៌ដឹកនាំភារកិច្ចស៊ើបអង្កេតក្នុងនាមចៅក្រម ពួកគាត់ត្រូវតែបានចាត់ទុកដូចជាចៅក្រម។ វាជាការព្រួយបារម្ភនិងមិនអាចការពារបានដែល ក.ស.ច.ស មិនអនុវត្តតាមភាពឡូស៊ិកនេះ។

៥៥. ថ្មីៗនេះ ក្រុមមេធាវីការពារក្តីក៏បានទទួលព័ត៌មានថា អ្នកស៊ើបអង្កេត Heder បានតំណាង និង/ឬធ្វើការងារជាភ្នាក់ងារស៊ើបការណ៍មួយរូប មុនពេលមកធ្វើការងារជាមួយ ក.ស.ច.ស។ មិនច្បាស់លាស់ថា ភ្នាក់ងារណាមួយដែលបានធ្វើការងារឱ្យនោះទេ ឬនៅពេលណា យូរប៉ុណ្ណា និងនៅក្នុងផ្នែកនយោបាយនិងភូមិសាស្ត្រអ្វីដែលគាត់បានធ្វើនោះទេ។ ព័ត៌មានត្រូវបានស្នើសុំពី ក.ស.ច.ស ពាក់ព័ន្ធនឹងបញ្ហានេះ ប៉ុន្តែមិនត្រូវបានផ្តល់ឱ្យនោះទេ។ ដូចដែលបានពន្យល់ដោយក្រុមមេធាវីការពារក្តីពីមុនមក:

> "ក្នុងនាមជាភ្នាក់ងារស៊ើបការណ៍មួយរូប អ្នកស៊ើបអង្កេត Heder អាចនឹងបានទទួលការ ណែនាំពីរដ្ឋាភិបាលបរទេស។ ដោយបានផ្តល់សញ្ញាតិដល់អ្នកស៊ើបអង្កេត Heder វា ហាក់ដូចជាគាត់ត្រូវបានជួលឱ្យធ្វើការងារ ដោយភ្នាក់ងារស៊ើបការណ៍មជ្ឈឹមសហរដ្ឋអាមេរិក ("សេអ៊ីអា") ដែលជាប្រទេសមួយដែលមានប្រវត្តិដ៏គ្មានរសជាតិនៅអាស៊ីអាគ្នេយ៍។ នៅឆ្នាំ១៩៧០ រដ្ឋាភិបាលសហរដ្ឋអាមេរិកបានធ្វើការទំលាក់គ្រាប់បែកលើ ប្រទេសកម្ពុជាដែលបានធ្វើឱ្យមានអ្នកស្លាប់និងអ្នករបួសរាប់មិនអស់ និងបានធ្វើឱ្យសង្គមកម្ពុជាមានភាពច្របូកច្របល់យ៉ាងខ្លាំង។ នៅក្នុងការស៊ើបអង្កេតប្រឆាំងនឹង លោក អៀង សារី និងអ្នកដទៃទៀត ចំពោះបទឧក្រិដ្ឋដែលបានចោទប្រកាន់ថាបានប្រព្រឹត្តនៅក្នុងអំឡុងពេលនេះ ភស្តុតាងនៃកម្រិតនៃការទម្លាក់គ្រាប់បែកនេះ និងលទ្ធផលរបស់វានឹងត្រូវបានលាតត្រដាង។ ជាការពិត រដ្ឋាភិបាលសហរដ្ឋអាមេរិករក្សាបាននូវផលប្រយោជន៍យ៉ាងរឹងមាំ ក្នុងការបង្រួមនូវតួនាទីរបស់ខ្លួនក្នុងការទម្លាក់គ្រាប់បែកមកលើប្រជាជនកម្ពុជា និងការស៊ើបការណ៍របស់ខ្លួនដែលធ្វើឡើងនៅក្នុងតំបន់។ ក្នុងករណីដែលអ្នកស៊ើបអង្កេតដែលធ្វើការងារឱ្យ ក.ស.ច.ស ត្រូវបានជួលឱ្យធ្វើការងារជាភ្នាក់ងារ ស៊ើបការណ៍ដែលបានទទួលជាផ្លូវការ ឬបាននឹងកំពុងទទួលការណែនាំពីភ្នាក់ងារចារកិច្ច នៃរដ្ឋាភិបាលបរទេសនោះ ចំណុចនេះពិតជានឹងប៉ះពាល់ដល់ឯករាជ្យភាពនិងភាពអនាគតិ ក្នុងការស៊ើបអង្កេត" [104]។

---

[104] សំណើរលើកទីពីរពាក់ព័ន្ធនឹង Heder កថាខ័ណ្ឌ២ ។ ជើងទំព័រ ត្រូវបានលុបចោល។

៥៦. ចម្លើយរបស់ ក.ស.ច.ស ទៅនឹងសំណើសុំព័ត៌មានដ៏បើកចំហរនិងប្រកបដោយតម្លាភាព នេះ គឺដើម្បីអះអាងថា "យើងជ្រើសរើសធ្វើការបង្ហាញថា យើងមិនបានដឹងអំពីព័ត៌មានណាមួយ ឬ ឯកសារណាមួយដែលអាចគាំទ្រដល់ការចោទប្រកាន់ នៅក្នុងសំណើរបស់អ្នកទាល់តែសោះ"[105]។ ពុំមានការចង្អុលបង្ហាញថា អ្នកស៊ើបអង្កេត Heder ទោះបីជាបានចាកចេញពីតួនាទីជាអ្នកស៊ើបអង្កេតនៃ ក.ស.ច.ស កាលពីពាក់កណ្តាលឆ្នាំ២០០៨ ក៏ដោយ តាមការដឹងលឺរបស់មេធាវីការពារក្តី ដែលនៅបន្តបំពេញការងារជាសេវាប្រឹក្សាសម្រាប់ ក.ស.ច.ស ត្រូវបានគេពិគ្រោះយោបល់ស្តីពីសំណើរបស់ក្រុមមេធាវីកាពារក្តីនោះទេ។ ហើយក៏គ្មានការបង្ហាញថា ទម្រង់នៃការស៊ើបអង្កេតណាមួយត្រូវបានធ្វើទៅលើបញ្ហានេះដែរ។ ផ្ទុយទៅវិញ នៅពេលដែលក្រុមមេធាវីការពារក្តីបានលើកឡើងពីមុនពីបញ្ហាសំខាន់ ដែលប៉ះពាល់ដល់ភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធី សហចៅក្រមស៊ើបអង្កេតបង្ហាញឲ្យឃើញនូវការបន្តធ្វើមិនដឹងមិនឮដោយចេតនានិងដោយរីករាយច្រើនជាងលើកឡើងពីបញ្ហាសំខាន់ក្នុងការិយាល័យរបស់ខ្លួន[106]។

៥៧. ទាក់ទងនឹងបុរេវិនិច្ឆ័យរបស់គាត់អំពីការស៊ើបអង្កេតបឋមដូច ដែលបានកំណត់នៅក្នុងសៀវភៅរបស់គាត់ អំពីភាពមិនអាចទៅរួចចំពោះភាពអនាគតិរបស់គាត់នៅពេលធ្វើការអោយ ក.ស.ច.ស ដើម្បីធ្វើការស៊ើបអង្កេតលើការចោទប្រកាន់ដែលគាត់បានធ្វើជាមួយ ក.ស.ព រួចហើយ ព្រមទាំងការងារពីមុនរបស់គាត់ជាភ្នាក់ងារស៊ើបការណ៍សម្ងាត់នោះ អ្នកស៊ើបអង្កេត Heder មិនបានបំពេញតាមនិយាមនៃភាពអនាគតិដែលបានតម្រូវនោះទេ។ ហេតុនេះ គេត្រូវតែដកហូតសិទ្ធិរបស់គាត់ ស្របតាមវិធាន៣៤ នៃវិធានផ្ទៃក្នុង។

## ឃ. មន្ត្រីច្បាប់ Boyle មិនមានភាពអនាគតិទៅលើបញ្ហាច្បាប់ចំពោះ ក.ស.ច.ស នោះទេ

៥៨. នាប៉ុន្មានឆ្នាំចុងក្រោយនេះ មានការកើនឡើងនូវសារព័ត៌មានថ្មីៗជាច្រើនពាក់ព័ន្ធនឹងបញ្ហាយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ។ ដោយមានការផ្តួចផ្តើម តាមរយៈការបង្កើតតុលាការឧក្រិដ្ឋកម្មអន្តរជាតិ

---

[105] សេចក្តីសម្រេចទីពីរពាក់ព័ន្ធនឹង Heder ។

[106] *រឿងក្តី អៀង សារី,* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, (អ.ប.ជ២០), បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរ អំពីការចោទប្រកាន់ជាហូរហែរអំពីអំពើពុករលួយ និងសំណើសុំចាត់ការសវនាការដេញដោលផ្ទាល់មាត់ឲ្យឆាប់រហ័ស, ចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ២០០៩។ កថាខ័ណ្ឌ៣៥។

សម្រាប់អតីតយូហ្គោស្លាវី និងរ៉្វាន់ដា នៅឆ្នាំ១៩៩៣ និង១៩៩៤ ដាច់ដោយឡែកពីគ្នានិងដោយមានការលើកទឹកចិត្តតាមរយៈការបង្កើតតុលាការឧក្រិដ្ឋកម្មអន្តរជាតិ អចិន្ត្រៃយ៍ នៅឆ្នាំ២០០២ និងតុលាការផ្សេងទៀតសម្រាប់ សេរ៉ាឡេអូន កម្ពុជា និងឡេបានន់ មានឱកាសជាច្រើនសម្រាប់ការសិក្សាតាមការចង់បានដើម្បីបង្ហាញទស្សនាទាន ស្តីពីបញ្ហា នៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិនាបច្ចុប្បន្ននេះ។

៥៩. ភាគច្រើននៃអត្ថបទទាំងនេះ គឺជាជំនួយយ៉ាងធំធេងក្នុងការលើកឡើង និងក្នុងបង្ហាញពីការយល់ឃើញអំពីវិស័យច្បាប់នេះប្រកបដោយភាពស្មុគស្មាញនិងដោយវាទប្បដិវាទ។ ជា ការពិតតាមលក្ខន្តិកៈរបស់តុលាការយុត្តិធម៌អន្តរជាតិការជឿជាក់អាចកើតមានឡើងទៅលើ "ការបង្រៀនរបស់អ្នកនិពន្ធអត្ថបទ ដែលប្រកបដោយលក្ខណៈសម្បត្តិខ្ពស់បំផុតរបស់ ប្រជាជាតិផ្សេងៗ ខណៈដែលផ្នែកបន្ទាប់បន្សំទៀតសំដៅដល់ការកំណត់វិធានច្បាប់"[107]។ ភាគច្រើននៃតុលាការអន្តរជាតិដែលត្រូវបានបង្កើតឡើងថ្មីៗទាំងនេះ ក៏បានយោងដល់អត្ថបទសិក្សា នៅក្នុងការសម្រេចសេចក្តីរបស់ខ្លួននៅពេលតុលាការទាំងនេះ ជាញឹកញាប់បំពេញនូវចម្លោះប្រហោងក្នុងលក្ខន្តិកៈ ដ៏ស្មុគស្មាញនិងដែលត្រូវបានព្រាងឡើងយ៉ាងរហ័ស ព្រមទាំងបទដ្ឋាននានារបស់តុលាការទាំងនេះផងដែរ។ អត្ថបទសំខាន់មួយចំនួនដែលត្រូវបានសរសេរសម្រាប់សាព័ត៌មានទាំងនេះ ត្រូវបាននិពន្ធដោយមន្ត្រីច្បាប់ និងមន្ត្រីច្បាប់អមដែលធ្វើការងារឲ្យតុលាការអន្តរជាតិថ្មីទាំងនេះ។ ហេតុនេះ ការព្រួយបារម្ភបានកើនឡើងថា ប្រជាជនដែលផ្តល់ការណែនាំដល់ចៅក្រមទៅលើបញ្ហាច្បាប់ដ៏ស្មុគស្មាញនានា មិនគួរសរសេរជាអត្ថបទសាធារណៈស្តីពីបញ្ហាដូចគ្នាទាំងនេះទេ។ ជាធម្មតា នេះគឺដោយសារតែការណែនាំលើបញ្ហាទាំងនេះ និងការវិនិច្ឆ័យជាមុនលើបញ្ហាទាំងនោះ បានធ្វើឲ្យអ្នកនិពន្ធស្ថិតនៅក្នុងទំនាស់ផលប្រយោជន៍នៅពេលដែលក្រោយមក គាត់ត្រូវបានកំណត់លក្ខខណ្ឌឲ្យចែកចាយនូវការណែនាំដោយមិនលម្អៀង លើបញ្ហាទាំងនេះដល់ចៅក្រមក្នុងករណី ដែលបញ្ហាដូចគ្នាកើតមានឡើងនៅក្នុងបរិបទនៃរឿងក្តី[108]។

---

[107] មាត្រា៣៨ (១)(ឃ)។ លក្ខន្តិកៈនៃតុលាការយុត្តិធម៌អន្តរជាតិ ។

[108] *សូមមើល រឿងក្តីរបស់ កាំង ហ្គេច អ៊ាវ "ឌុច"* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧- អ.វ.ត.ក/ក.ស.ច.ស, (អ.ប.ជ០២), ពាក្យសុំរបស់លោក អៀង សារី សុំដកគុណវុឌ្ឍិសាស្ត្រាចារ្យ **កាសេសេ៊** (Cassese) និងសមាជិកមួយចំនួននៃក្រុមប្រឹក្សានិពន្ធ និងគណៈកម្មាធិការនិពន្ធ និងនៃទានុប្បវត្តិតុលាការ ព្រហ្មទណ្ឌអន្តរជាតិ ពីការដាក់សារណាជាលាយលក្ខណ៍បណ្តឹងជិតចិត្តរបស់ អៀង សារី ទៅលើអ្នកស៊ើបអង្កេត ក.ស.ច.ស STEPHEN HEDER និងមន្ត្រីច្បាប់ DAVID BOYLE

៦០. នៅតុលាការឧក្រិដ្ឋកម្មអន្តរជាតិ នៅក្នុងពេលអះអាងពីការស្តាប់ការដេញដោលនៅក្នុង រឿងក្តី Katanga និង Ngudjolo អង្គបុរេជំនុំជម្រះបានប្រឈមទៅនឹងបញ្ហាដូចគ្នានេះ។ ក្រុមមេធាវីការពារក្តីនៅក្នុងរឿងក្តីនោះ បានធ្វើសេចក្តីសន្និដ្ឋានផ្ទាល់មាត់ទៅលើទម្រង់មួយនៃទម្រង់នៃ ការទទួលខុសត្រូវព្រហ្មទណ្ឌទាំងអស់ ដែលគេហៅថា ការចូលរួមប្រព្រឹត្តមិនផ្ទាល់ ដែលតាមរយៈទម្រង់នោះ កូនក្តីរបស់ពួកគេត្រូវបានចោទប្រកាន់ដោយអយ្យការ[109]។ ទម្រង់នៃការទទួលខុសត្រូវនេះ ត្រូវបានផ្តល់យោបល់យ៉ាងទូលំទូលាយ នៅក្នុងអត្ថបទចំនួនពីរដែលសរសេរដោយ Hector Olasolo ដែលជាមន្ត្រីច្បាប់បំរើការងារឱ្យអង្គបុរេជំនុំជម្រះដដែល[110]។ ដោយបានទទួលស្គាល់ថា ការបន្តធ្វើការងារឱ្យចៅក្រមបានធ្វើឱ្យគាត់ស្ថិតនៅក្នុងទំនាស់ផលប្រយោជន៍ Olasolo “បានស្នើសុំដកខ្លួនជាបណ្តោះអាសន្នចេញពីមុខងារណាក៏ដោយនៅក្នុងរឿងក្តី នេះ រហូតដល់មានសេចក្តីសម្រេចចេញដោយអង្គបុរេជំនុំជម្រះថាតើតម្កល់នូវការចោទ ប្រកាន់ឬទេ”[111]។ សំណើនេះត្រូវបានយល់ព្រមដោយអង្គបុរេជំនុំជម្រះ[112]។

៦១. ជាការពិត វិធានសម្រាប់បុគ្គលិកអង្គការសហប្រជាជាតិទទួលស្គាល់នូវបញ្ហារបស់មន្ត្រី បុគ្គលិកដែលមានដោយបានធ្វើសេចក្តីព្រាងអត្ថបទស្តីពីបញ្ហាមួយចំនួន ក្នុងខណៈដែល ត្រូវបានជួលឱ្យធ្វើការងារក្នុងពេលដំណាលគ្នា ដើម្បីជួយដល់ចៅក្រមក្នុងការសម្រេច អំពីបញ្ហាទាំងនេះ។ ស្របតាមវិធាន ១០១.២ (p) នៃវិធានសម្រាប់បុគ្គលិកអង្គការ សហប្រជាជាតិ:

---

អក្សររបស់ *អ្នកដែលមិនមែនជាភាគីនៃរឿងក្តី* ស្តីពីបញ្ហាសហកម្មឧក្រិដ្ឋកម្មរួម នៅក្នុងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះករណីករណីរបស់ កាំង ហ្កេក អ៊ាវ ហៅ “ឌុច”, ថ្ងៃទី៣ ខែតុលាឆ្នាំ២០០៨។

[109] *រឿងក្តីរដ្ឋអាជ្ញា តទល់ Katanga និង Ngudjolo*, ICC-01/04-01/07-T-46-ENG, ប្រតិចារឹក ចុះ ថ្ងៃទី១១ខែកក្កដា ឆ្នាំ២០០៨, កថាខ័ណ្ឌ២៩-៣៧។

[110] *សូមមើល H"ctor Ol...solo & Ana P"rez Cepeda,* ទស្សនៈទាននៃការគ្រប់គ្រងបទឧក្រិដ្ឋនិង ការអនុវត្តន៍របស់ ICTY ក្នុងរឿងក្តី Stakić ការពិនិត្យច្បាប់ឧក្រិដ្ឋអន្តរជាតិ ទី៤ (២០០៤) ៤៧៥-៥២៦ ។ *Héctor Olásolo,* កាផ្ទុះបញ្ចាំងលើការអនុវត្តន៍នៃទស្សនៈទាននៃការគ្រប់គ្រងឧក្រិដ្ឋកម្ម និងសហកម្មឧក្រិដ្ឋកម្មរួមក្នុងសាលក្រមឧទ្ធរណ៍ Stakic, *ការត្រួតពិនិត្យលើច្បាប់ស្តីពីឧក្រិដ្ឋកម្មអន្តរជាតិ ទី៧ (២០០៧) ១៤៣-១៦១។*

[111] *រឿងក្តីរដ្ឋអាជ្ញា តទល់ Katanga និង Ngudjolo,* ICC-01/04-01/07, ប្រតិចារឹកចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៨, កថាខណ្ឌ២។

[112] *ដូចយោងខាងលើ* ។

00348482



"មន្ត្រីបុគ្គលិកមិនត្រូវពាក់ព័ន្ធនឹងអំពើណាមួយដូចខាងក្រោមនេះទេ ប្រសិនបើអំពើនេះ ទាក់ទិននឹងគោលបំណង សកម្មភាព ឬផលប្រយោជន៍របស់អង្គការសហប្រជាជាតិ លើកលែងតែស្ថិតនៅក្នុងភារកិច្ចជាផ្លូវការធម្មតា ឬដោយមានការយល់ព្រមជាមុន ពីអគ្គលេខាធិការៈ

(i) ចេញសេចក្តីថ្លែងការណ៍ដល់សាព័ត៌មាន វិទ្យុ ឬភ្នាក់ងារព័ត៌មាន សាធារណៈផ្សេងទៀត។

(ii) យល់ព្រមចូលរួមក្នុងការនិយាយ។

(iii) ចូលរួមក្នុងការផលិតខ្សែភាពយន្ត ល្ខោន វិទ្យុ ឬទូរទស្សន៍។

(iv) ដាក់អត្ថបទ សៀវភៅ ឬឯកសារផ្សេងទៀតសម្រាប់ធ្វើការបោះពុម្ពផ្សាយ[113]។

៦២. វាពិតជាហួសពីការតវ៉ាថា អត្ថបទពាក់ព័ន្ធនឹងមុខងាររបស់ អ.វ.ត.ក និងតើត្រូវធ្វើដូចម្តេចដើម្បីដោះស្រាយបញ្ហាច្បាប់មួយចំនួនដែលមានភាពសាំញ៉ាំជាង ដែលខ្លួននឹងជួបប្រទះគឺស្ថិតនៅក្នុងគោលបំណង សកម្មភាព និងផលប្រយោជន៍របស់អង្គការសហប្រជាជាតិ។ ការចូលរួមរបស់អង្គការសហប្រជាជាតិក្នុងការបង្កើត និងក្នុងដំណើរការអង្គជំនុំជម្រះវិសាមញ្ញ ត្រូវបានសំអាងលើសេចក្តីត្រូវការដែលបានគិតទុក ជាមុនដើម្បីធានាថា ការកាត់ទោសខ្មែរក្រហមត្រូវបានធ្វើឡើងដោយយុត្តិធម៌ និងទៅ តាមដំណើរការដែលបានកំណត់ទុក[114]។

៦៣. មន្ត្រីច្បាប់ Boyle បានសរសេរអត្ថបទក្នុងចំនួនដ៏ច្រើនសន្ធឹកសន្ធាប់ដែលទាក់ទងនឹងនឹងបញ្ហាដែលជួបប្រទះដោយអង្គជំនុំជម្រះវិសាមញ្ញ។ បន្ថែមពីលើការរក្សានូវគេហទំព័រ[115] មន្ត្រីច្បាប់ Boyle ក៏ជាអ្នកនិពន្ធ យ៉ាងហោចណាស់នូវលិខិត សុន្ទរកថា និងអត្ថបទ ដូចខាងក្រោមនេះដែរ

---

[113] ឋាន: សិទ្ធិរូបវន្ត និង តួនាទីរបស់បុគ្គលិកអង្គការសហប្រជាជាតិ, ST/SGB/2002/13, ចុះថ្ងៃទី១ ខែវិច្ឆិកាឆ្នាំ២០០២។

[114] សូមមើលជាឧទាហរណ៍ប្រតិចារិកនៃបទអត្ថាធិប្បាយរបស់លោក Hans Correll អគ្គលេខាធិការង សំរាប់កិច្ចការច្បាប់និងអ្នកផ្តល់និវាទផ្នែកច្បាប់របស់អង្គការសហប្រជាជាតិ, ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០០២ ដែលបានរៀបរៀងឡើងវិញក្នុងអត្ថបទរបស់លោកស្រី Helen Jarvis, *Trials and Tribulations: The Last Twists in the Long Quest for Justice for the Cambodian Genocide,* Critical Asian Studies 34:4 (២០០២) ៦០៧, ៦១៧ ("ថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០០២ ប្រតិចារិក")។ ក្នុងសារណានេះលោក Correll ពន្យល់ថា "បទដ្ឋានយុត្តិធម៌អន្តរជាតិគឺ ចាំបាច់សម្រាប់ការបន្តការចូលរួមរបស់អង្គការសហប្រជាជាតិ"។

[115] http://www.ridi.org/boyle/

(i) ការកាត់ទោស អៀង សារី លិខិតជូនទៅកាសែត Phnom Penh Post អត្ថបទចុះផ្សាយសប្តាហ៍នៃថ្ងៃទី ១៣ ដល់ ១៦ ខែតុលា ឆ្នាំ ២000

(ii) សុន្ទរកថា ឆ្នាំ២00៥៖ ការបញ្ចេញសំឡេងរវាងតុលាការឧក្រិដ្ឋកម្ម អន្តរជាតិ និងតុលាការខ្មែរក្រហម: ទីកន្លែងរបស់ជនរងគ្រោះ។

(iii) Boyle David "មួយជំហានទៀត - ការអនុម័តច្បាប់កាត់ទោសខ្មែរ ក្រហម"។ *ការទូតតុលាការ* Revue Internet (ថ្ងៃទី៥ ខែសីហា ឆ្នាំ២00១)។

(iv) "តើយុត្តិធម៌បែបណាសម្រាប់ខ្មែរក្រហម?" Revue Trimestrielle des Droits de l'Homme 773, ឆ្នាំទី១០ លេខ៤០ (ឆ្នាំ១៩៩៩)។

(v) David Boyle "ការបង្កើតនូវការទទួលខុសត្រូវរបស់ថ្នាក់ដឹកនាំខ្មែរ ក្រហម ចំពោះឧក្រិដ្ឋកម្មអន្តរជាតិ" សៀវភៅផែនការប្រចាំឆ្នាំស្តីពីច្បាប់ មនុស្សធម៌អន្តរជាតិ លេខ៥ ឆ្នាំ២00២ សាព័ត៌មាន TMC Asser ឆ្នាំ២00៥។

(vi) David Boyle របាយការណ៍ទំនាក់ទំនង - ប្រទេសកម្ពុជា សៀវភៅ ផែនការប្រចាំឆ្នាំស្តីពីច្បាប់មនុស្សធម៌អន្តរជាតិ លេខ៣ ឆ្នាំ២000 ទំព័រ ៤៣៧-៣៩។

(vii) David Boyle "តុលាការកូនកាត់ទទួលបន្ទុកកាត់ទោសខ្មែរក្រហម" ច្បាប់មូលដ្ឋាន Revue internet, លេខ១ ខែកក្កដា-ធ្នូ ឆ្នាំ២00១។

(viii) David Boyle "សិទ្ធិ ការចូលរួម ការតំណាង ការការពារ និងការ ជួសជុលសំណងរបស់ជនរងគ្រោះ" ការចូលរួមគំនិតអំពីការកាត់ទោស ខ្មែរក្រហម សាព័ត៌មានអំពីយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ (ឆ្នាំ ២00៦) ទំព័រ ៣0៧-៣១៣។

(ix) អង្គជំនុំជម្រះវិសាមញ្ញកម្ពុជា: ប្រព័ន្ធពិសេសតែមួយគត់ (sui generis) ដែលបានបន្សល់ទុកនូវសំណួរជាច្រើនដែលមិនត្រូវបានឆ្លើយតប David Boyle។ បទបង្ហាញតាមរយៈ Powerpoint។

៦៤. អត្ថបទទាំងនេះបានណែនាំយ៉ាងលម្អិតអំពីបញ្ហាសំខាន់មួយចំនួន ដែលនឹងជួបប្រទះដោយ អង្គជំនុំជម្រះវិសាមញ្ញ និងជាដំបូងត្រូវប្រឈមដោយ ក.ស.ច.ស ។ នៅក្នុងអត្ថបទរបស់ កាសែត Phnom Penh Post មន្ត្រីច្បាប់ Boyle បានលើកឡើងអំពីលទ្ធផលនៃព្រះរាជកិច្ចលើកលែងទោស និងអនុគ្រោះទោស ដែលបានផ្តល់ជូនលោក អៀង សារី:

"រឿងក្តីរបស់លោក អៀង សារី គឺជាគំរូនៃបញ្ហាដែលនឹងកើតមានឡើងនៅចំពោះមុខ តុលាការកម្ពុជា។ លោក អៀង សារី ត្រូវបានផ្តល់នូវការអភ័យទោសដែលមានសុពលភាពតាមរដ្ឋធម្មនុញ្ញ និងអភ័យឯកសិទ្ធិចំពោះបទឧក្រិដ្ឋមួយចំនួននិងចំពោះការចោទ ប្រកាន់តាមច្បាប់ឆ្នាំ១៩៩៤។ តើមានវិសាលភាពប៉ុណ្ណាដែលការលើកលែងទោសនិងការ អភ័យទោសដែលមានសុពលភាពតាមរដ្ឋធម្មនុញ្ញនេះ ត្រូវយកមកអនុវត្តនៅចំពោះមុខ សវនាការកាត់ទោសខ្មែរក្រហមនោះ? ចំណុចនេះបានបន្សល់ទុកដល់តុលាការដើម្បីសម្រេច។ រាល់សំណួរទាំងនេះនឹងត្រូវបានលើកឡើងដោយក្រុមមេធាវីការពារក្តី ហើយនឹងត្រូវបានលើកឡើងជាមុន <u>ដើម្បីចៀសវាងកុំឱ្យមេធាវីដើមទេពកោសល្យនឹងពន្យឺតការកាត់សេចក្តីខ្លាំងពេក</u> ដែលនាំឱ្យរយៈពេលបីឆ្នាំនឹងមិនគ្រប់គ្រាន់ដើម្បីបញ្ចប់ទេនោះ។ មានផ្លូវពីរដែលអាចធ្វើបានដើម្បីដោះស្រាយបញ្ហាទាំងនេះដោយអន្ទើ។ ផ្លូវមួយគឺ <u>សម្រាប់ចៅក្រមប្រជុំគ្នាជាមួយព្រះរាជអាជ្ញានិងចៅក្រមស៊ើបអង្កេតភ្លាម បន្ទាប់ពីត្រូវបានតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងរកមធ្យោបាយដោះស្រាយឱ្យបានច្បាស់លាស់ទៅលើនីតិវិធីអ្វីដែលត្រូវយកមកអនុវត្តសម្រាប់តុលាការនេះ</u>។ ពួកគាត់មិនអាចផ្លាស់ប្តូរច្បាប់បានទេ ប៉ុន្តែពួកគាត់អាចរកមធ្យោបាយដោះស្រាយ ថាតើច្បាប់មានន័យយ៉ាងម៉េច"[116]។

៦៥. សេចក្តីថ្លែងការណ៍នេះ បានបង្ហាញច្បាស់លាស់អំពីការជឿជាក់ដែលនាំទៅរកផ្លូវខុសរបស់ លោក Boyle ដែលក្រុមមេធាវីការពារក្តីគួរតែបដិសេធថាបានជួយដល់តុលាការ នៅក្នុងការសម្រេចលើបញ្ហាណាមួយដែលពាក់ព័ន្ធនឹង "ការអភ័យទោសនិងការលើកលែងទោសដែលមានសុពលភាពតាមរដ្ឋធម្មនុញ្ញ" របស់លោក អៀង សារី។ ប្រសិនបើគាត់មិនគូសបញ្ជាក់អំពីរឿងនោះទេ ក្រុមមេធាវីការពារក្តីនឹងគ្មានអ្វីដើម្បីចែករំលែក ឬនឹងគ្រាន់តែប៉ុនប៉ងបង្អាក់ដំណើរការនីតិវិធីនោះទេ ប៉ុន្តែគាត់បានបន្តតស៊ូមតិរបៀបជា *Star Chamber* ដូចជានីតិវិធីដែលភាគីម្ខាងទៀតមិនបានចូលរួម (*ex parte*) ជាដើម: ចំពោះចៅក្រម ការដោះស្រាយបញ្ហាដោយផ្ទុយទៅនឹងច្បាប់នៅចំពោះមុខក្រុមមេធាវីការពារក្តី ជាមួយនឹងក.ស.ព (ជាភាគីមួយ) និងក.ស.ច.ស (ដែលត្រូវបានលើកឡើងថាជាស្ថាប័នមួយកិច្ចដំណើរការនីតិវិធីដែលមានភាពអនាគតិ) មានពេលវេលាដើម្បីតបត។ ជាការពិត សេចក្តីសន្និដ្ឋានរបស់ លោក Boyle ដែលថា បញ្ហាត្រូវតែមានការទាក់ទងនៅចំពោះមុខ

---

[116] របាយការណ៍ពីសន្និសិទមួយធ្វើឡើងក្នុងក្រុងភ្នំពេញ ចុះថ្ងៃទី២-៣ ខែមីនា ឆ្នាំ២០០៥ ដែលរៀបចំដោយ FIDH, LICADHO និង ADHOC, *កម្មវិធីតុលាការឧក្រិដ្ឋកម្មអន្តរជាតិ: ការភ្ជាប់រវាងតុលាការឧក្រិដ្ឋកម្មអន្តរជាតិនិងតុលាការខ្មែរក្រហម: ទឹកថ្លែងរបស់ជនរងគ្រោះ ខ* ។ ក្របខ័ណ្ឌច្បាប់នៃតុលាការខ្មែរក្រហមទំព័រ ១៨ (គូសបញ្ជាក់បន្ថែម), នៅក្នុង: http://www.vrwg.org/Publications/02/FIDHcambodge420ang.pdf. គូសបញ្ជាក់បន្ថែម ។

ក្រុមមេធាវីការពារក្តី មានឱកាសដើម្បី "ពន្យឺត សវនាការកាត់ទោស" និងបង្ហាញឱ្យឃើញនូវការពន្យល់អំពីមូលហេតុដែល ក.ស.ច.ស បានសម្រេចតាមការយល់ឃើញដោយខ្លួនឯង (*proprio motu*) ដើម្បីលើកឡើងពីបញ្ហា យុត្តាធិការនៃគោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ (*ne bis in idem*) និងការលើកលែងទោសនៅក្នុងដីកាឃុំខ្លួនបណ្តោះអាសន្ន[117]។ វាក៏បានបង្ហាញឱ្យឃើញផងដែរពីការបង្កើតនូវការណែនាំផ្លូវច្បាប់យ៉ាងច្បាស់លាស់ នៅក្នុងរឿងក្តីនេះ ដែលបង្កើតជាមូលដ្ឋាននៃការដកហូតសិទ្ធិ ស្របតាមមាត្រា៥៥៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

## VII. សន្និដ្ឋាន និងដំណោះស្រាយដែលត្រូវបានស្នើសុំ

៦៦. អ្នកស៊ើបអង្កេត Heder មន្ត្រីច្បាប់ Boyle មិនមែនជាចៅក្រមទេ។ ទោះបីជាយ៉ាងណា ក៏ដោយ ពួកគាត់បានអនុវត្តភារកិច្ចក្នុងនាមចៅក្រម ដែលកំណត់លក្ខខណ្ឌថា ពួកគាត់ត្រូវ តែមានភាពអនាគតិជាដាច់ខាត។ គួរឱ្យសោកស្តាយ Heder ក៏គ្មានភាពអនាគតិ Boyle ក៏គ្មានភាពអនាគតិ។ ការកម្រិតព្រំដែនវិធាន ៣៤ នៃវិធានផ្ទៃក្នុង ដោយក្លែងក្លាយ ដើម្បី បដិសេធនូវបណ្តឹងជំទាស់ចិត្តអ្នកស៊ើបអង្កេត Heder មន្ត្រីច្បាប់ Boyle នៅពេលដែល ចៅក្រមស៊ើបអង្កេតនឹងទទួលខុសត្រូវចំពោះការដកហូតសិទ្ធិ មិនឱ្យប្រព្រឹត្តនូវអំពើដូចគ្នា នេះ នឹងជាការបំពានទាំងស្រុង និងក្លាយជាការចំអកដល់និយាមអន្តរជាតិដែលបានគិតទុក និងដែលគេចង់បានចំពោះអង្គជំនុំជម្រះវិសាមញ្ញ។

**អាស្រ័យហេតុនេះ** យោងតាមហេតុផលដែលបានលើកឡើងខាងលើ ក្រុមមេធាវី ការពារក្តី សូមស្នើដោយក្តីគោរពដល់អង្គបុរេជំនុំជម្រះសូមមេត្តា:

ក. **ដកហូតសិទ្ធិ** អ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស Stephen Heder មិនឱ្យមានភារកិច្ចវិភាគ ឬភារកិច្ចស៊ើបអង្កេតអ្វីទាំងអស់ នៅក្នុងសំណុំរឿង លេខ០០២។ និង

ខ. **ដកហូតសិទ្ធិ** មន្ត្រីច្បាប់របស់ ក.ស.ច.ស David Boyle មិនឱ្យមានភារកិច្ចខាងផ្លូវច្បាប់ ភារកិច្ចវិភាគ ឬភារកិច្ចស៊ើបអង្កេតអ្វីទាំងអស់ នៅក្នុងសំណុំរឿងលេខ០០២។

---

[117] *រឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧- អ.វ.ត.ក/ក.ស.ច.ស, ដីកាឃុំខ្លួនបណ្តោះអាសន្ន, ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៧, កថាខ័ណ្ឌ៥-១៤ ។

00348486



1

សូមដាក់ជូនដោយក្តីគោរព

ព្រះរាជាណាចក្រកម្ពុជា មេធាវី AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

អាង ឧត្តម　　　　　　　　Michael G. KARNAVAS

សហមេធាវីការពារលោក **អៀង សារី**

ចុះហត្ថលេខានៅភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី ៨ ខែ កក្កដា ឆ្នាំ២០០៩